# ការវាយតម្លៃសមត្ថភាព និងការអភិវឌ្ឍ គំរូការអប់រំស្ទែមសម្រាប់វិទ្យាល័យ៖ ករណីសិក្សាខេត្តកំពង់ស្ពឺ


ក្រុមស្រាវជ្រាវ៖

**ជ័យ ចាន់អឿន, ស្រ៊ីវ ថារិទ្ធ, ហ៊ុល សៀងហេង, អ៊ុន លាង និង ជា មុយគីម**

ជំនួយការស្រាវជ្រាវ៖

**សុខ គុណវឌ្ឍន៍, ឡុង ប៉ូរ៉ា និង គីម ពីស្សី**



**២០២៣**

© រក្សាសិទ្ធិដោយ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ២០២៣

ការផលិតឡើងវិញទាំងស្រុង ឬផ្នែកខ្លះនៃរបាយការណ៍ស្រាវជ្រាវនេះ ទោះក្នុងទម្រង់ណាក៏ដោយ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា រាប់បញ្ចូលតែមិនកំណត់ចំពោះ ឯកសាររូបវ័ន្ត ឯកសារអ៊ីនធឺណិត និងឯកសារជាសំឡេង លើកលែងតែក្នុងករណីសម្រង់ឃ្លាសម្រាប់ប្រើប្រាស់ជាឯកសារយោងនៅក្នុងអត្ថបទស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ដោយមានការបញ្ជាក់ត្រឹមត្រូវពីប្រភពដើមនៃឯកសារ។

ទស្សនៈនៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ គឺជាទស្សនៈរបស់អ្នកស្រាវជ្រាវ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈ ឬនិន្នាការរបស់ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ឡើយ។ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា មិនធានាលើភាពជាក់លាក់ ឬភាពពេញលេញនៃទិន្នន័យដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ និងមិនទទួលខុសត្រូវលើវិបាកដែលកើតចេញពីការប្រើប្រាស់ទិន្នន័យទាំងនោះឡើយ។ ការលើកឡើងអំពីឈ្មោះជាក់លាក់ណាមួយនៅក្នុងរបាយការណ៍នេះ មិនបង្ហាញអំពីការគាំទ្រ ឬទំនោរ របស់ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ទៅលើម្ខាងណាឡើយ។

សូមយោងរបាយការណ៍ស្រាវជ្រាវនេះ តាមគំរូដូចខាងក្រោម៖

Chey, C., Sriv, T., Hul, S., Un, L., & Chea, M. (2023). *Capacity Assessment and Development of STEM High School Model: The Case of Kampong Speu Province*. Cambodia Development Center. https://www.cd-center.org/capacity-assessment-and-development-of-stem-high-school-model-the-case-of-kampong-speu-province

រចនាគម្របដោយ៖ ម៉ែន សុទ្ធាពិសិដ្ឋ

# អំពីមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា គឺជាស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញ មានចក្ខុវិស័យជា "ស្ថាបនិកចូលរួម ប្រកបដោយមូលដ្ឋានពិត វិទ្យាសាស្ត្រ និងវិជ្ជាជីវៈ សម្រាប់កម្ពុជា ជាប្រទេសអភិវឌ្ឍន៍"។ ដើម្បីសម្រេចបាន ចក្ខុវិស័យនេះ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ផ្តោតលើសកម្មភាពការងារធំៗចំនួនបី រួមមាន៖ ១-ការស្រាវជ្រាវ និងបោះពុម្ពផ្សាយ ២-ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ និង ៣-ការចូលរួមការអភិវឌ្ឍគោលនយោបាយ។

ក្នុងសកម្មភាពស្រាវជ្រាវ និងបោះពុម្ពផ្សាយ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា មានទិសដៅបង្កើតសហគមន៍ស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រនៅក្នុងសង្គមកម្ពុជា ដោយឈរលើមូលដ្ឋានលើកកម្ពស់ការសិក្សាស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីចូលរួមផ្តល់ជាអនុសាសន៍គោលនយោបាយជូនរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍគោលនយោបាយ និងយុទ្ធសាស្ត្រនានា ក៏ដូចជាការជំរុញ និងការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនលើគ្រប់វិស័យ រួមមានវិស័យអប់រំ សេដ្ឋកិច្ចសង្គម គោលនយោបាយការបរទេស បច្ចេកវិទ្យា និងប្រធានបទនានាដែលទាក់ទងនឹងដំណើរអភិវឌ្ឍន៍កម្ពុជា។

ក្នុងសកម្មភាពបណ្តុះបណ្តាល និងការផ្សព្វផ្សាយ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ខិតខំយ៉ាងស្វាហាប់ក្នុងការលើកកម្ពស់វិជ្ជាជីវៈ និងការកសាងសមត្ថភាពរបស់ប្រជាជនសកម្ម ក្នុងស្មារតីឆ្លើយតបទៅនឹងភាពបត់បែននៃបរិការណ៍សាកល និងតំបន់ តាមរយៈការបង្កើតវេទិកាសាធារណៈ ដូចជា បាឋកថាសាធារណៈ សិក្ខាសាលាក្នុងកម្រិតជាតិ និងអន្តរជាតិ កិច្ចសន្ទនារវាងអ្នកជំនាញ និងវេទិកាប្រកួតប្រជែងសម្រាប់សិស្ស និស្សិត និងអ្នកស្រាវជ្រាវវ័យក្មេង បញ្ចេញសមត្ថភាព និងទស្សនៈជាសាធារណៈ ព្រមទាំងតាមរយៈសកម្មភាពអភិវឌ្ឍន៍ជំនាញ និងបណ្តុះបណ្តាលសមត្ថភាពផ្ទៃក្នុងរបស់បុគ្គលិក អ្នកហាត់ការ និងយុវជនស្ម័គ្រចិត្ត។

ក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍគោលនយោបាយ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ជឿជាក់យ៉ាងមុតមាំថាបេសកកម្មការងារទាំងនៅក្នុងវិសាលភាពនៃការស្រាវជ្រាវ និងបោះពុម្ពផ្សាយ និងវិសាលភាពនៃការបណ្តុះបណ្តាល និងផ្សព្វផ្សាយ នឹងត្រូវបានបំប្លែងជាធាតុចូល និងអនុសាសន៍គោលនយោបាយដ៏មានអត្ថន័យ និងមានសារៈសំខាន់នានាជូនរាជរដ្ឋាភិបាលកម្ពុជា អ្នកបង្កើតគោលនយោបាយ និងគ្រប់ភាគីពាក់ព័ន្ធ ដើម្បីរៀបចំជាយុទ្ធសាស្ត្រប្រកបដោយបរិយាប័ន្នក្នុងដំណើរអភិវឌ្ឍន៍ប្រទេសកម្ពុជា ឆ្ពោះទៅកាន់ចក្ខុវិស័យឆ្នាំ ២០៣០ និង២០៥០។

# មាតិកា


អំពីអ្នកស្រាវជ្រាវ ........ 1

ជំនួយការស្រាវជ្រាវ ........ 3

សេចក្តីថ្លែងអំណរគុណ ........ 4

បញ្ជីពាក្យកាត់ ........ 5

សេចក្តីសង្ខេប ........ 6

១. សេចក្តីផ្តើម ........ 9

១.១. បរិបទ ........ 9

១.២. ការអប់រំស្ទែមៈ បរិបទសាកល និងកម្ពុជា ........ 10

១.៣. ហេតុអ្វីវិទ្យាល័យស្ទែមនៅក្នុងខេត្តកំពង់ស្ពឺ? ........ 19

១.៣.១. សនិទាន ........ 19

១.៣.២. មូលធនមនុស្សក្នុងខេត្តកំពង់ស្ពឺ ........ 21

១.៤. គោលបំណង និងវត្ថុបំណង ........ 23

១.៥. ទំហំនៃការសិក្សា ........ 23

២. វិធីសាស្ត្រស្រាវជ្រាវ ........ 24

២.១. សំណាក និងការជ្រើសរើស ........ 24

២.២. ការប្រមូលទិន្នន័យ ........ 25

២.២.១. ការស្ទង់មតិដោយប៊ិក-ក្រដាស ........ 25

២.២.២. ការវិភាគគោលនយោបាយ និងឯកសារសិក្សាដែលមានស្រាប់ ........ 25

២.២.៣. ការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ ........ 26

២.២.៤. ការសង្កេតតាមរយៈការចុះដល់ទីតាំងផ្ទាល់ ........ 26

២.៣. វិធីសាស្ត្រវិភាគទិន្នន័យ ........ 26

៣. ការវាយតម្លៃលើវិទ្យាល័យដែលត្រូវបានជ្រើសរើសក្នុងខេត្តកំពង់ស្ពឺ ........ 28

៣.១. រចនាសម្ព័ន្ធជាមូលដ្ឋានដែលទ្រទ្រង់ដល់ការបង្រៀន និងរៀន ........ 28

៣.២. រចនាសម្ព័ន្ធជាមូលដ្ឋានដែលគាំទ្រដល់ទំនាក់ទំនងសាលារៀន-សហគមន៍ ....30
៣.៣. អភិបាលកិច្ចសាលារៀន....32
៣.៤. បុគ្គលិកគ្រប់គ្រង និងគាំទ្រ....32
៣.៥. ធនធានហិរញ្ញប្បទាន/ហិរញ្ញវត្ថុ ....36
៣.៦. គ្រូបង្រៀនស្នេម និងគុណវុឌ្ឍិរបស់គ្រូបង្រៀន ....36
៣.៧. ចំណេះដឹង និងជំនាញរបស់គ្រូបង្រៀន ....38
៣.៨. កម្មវិធីសិក្សា ....39
៤. គំរូវិទ្យាល័យស្នេម....42
៤.១. គ្រូបង្រៀនស្នេម គុណវុឌ្ឍិ និងទំហំការងាររបស់គ្រូបង្រៀន ....47
៤.២. ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលគាំទ្រដល់ការបង្រៀន និងរៀនស្នេម48
៤.៣. ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលជំរុញបរិយាកាសសាលារៀនមួយដែលមានលក្ខណៈគាំទ្រ ....49
៤.៤. បុគ្គលិកផ្នែកគ្រប់គ្រង និងគាំទ្រ ....51
៤.៥. អភិបាលកិច្ច និងភារកិច្ចសម្រាប់ក្រុមប្រឹក្សាភិបាលសាលារៀន ....52
៤.៦. ធនធានហិរញ្ញប្បទាន/ហិរញ្ញវត្ថុ....53
៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ....54
៥.១. សនិទានចម្បងសម្រាប់ការជ្រើសរើសវិទ្យាល័យដើម្បីអនុវត្តគំរូស្នេមដែលស្មើឡើងថ្មី....54
៥.២. អនុសាសន៍ដើម្បីប្រែក្លាយវិទ្យាល័យកំពង់ស្ពឺទៅជាវិទ្យាល័យស្នេម.55
៥.២.១. ដំណាក់កាលការរៀបចំ ....55
៥.២.២. ដំណាក់កាលអនុវត្ត....64
ឯកសារយោង....65

# អំពីអ្នកស្រាវជ្រាវ

**បណ្ឌិត ជ័យ ចាន់អឿន** ជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ លោក បានទទួលបណ្ឌិតពីដេប៉ាតឺម៉ង់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃវិទ្យាស្ថានបច្ចេកវិទ្យា សាកលវិទ្យាល័យ Linköping ប្រទេសស៊ុយអែត។ បច្ចុប្បន្ន លោកជាអ្នកទទួលបន្ទុកសាលាក្រោយបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ បណ្ឌិត ជ័យ ចាន់អឿន ក៏ជាព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យវិទ្យាសាស្ត្រ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ទទួលបន្ទុកស្រាវជ្រាវ និងទំនាក់ទំនងអន្តរជាតិ ផងដែរ។ បន្ថែមពីនេះ លោកក៏ជាគ្រូឧទ្ទេស និងជាប្រធានក្រុមតំណាងកម្ពុជាសម្រាប់ការប្រកួតប្រជែងរូបវិទ្យាអូឡាំព្យាដទ្វីបអាស៊ី (APhO), ការប្រកួតប្រជែងរូបវិទ្យាអូឡាំព្យាដអន្តរជាតិ (IPhO), កម្មវិធីជ្រើសរើសអ្នកវិទ្យាសាស្ត្រវ័យក្មេង SEAMEO (SSYS), ការប្រកួត APT-JSO និងទិវាប្រវត្តិសាស្ត្រធម្មជាតិសាកល (GNHD)។ បច្ចុប្បន្ន បណ្ឌិត ជ័យ ចាន់អឿន គឺជាអ្នកសម្របសម្រួលគម្រោងស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រនៃកម្មវិធី Sweden-RUPP Bilateral (2019-2023) និងជាអ្នកសម្របសម្រួលគម្រោងស្រាវជ្រាវសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីពង្រឹងគុណភាពឧត្តមសិក្សា (HEIP 2018-2024)។

**បណ្ឌិត ស្រ៊ុយ ថារិទ្ធ** ជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ លោកបណ្ឌិត បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិស្វកម្មអគ្គិសនី និងព័ត៌មាននៅក្នុងឆ្នាំ២០០៥ ពី King Mongkut's University of Technology Thonburi នៅទីក្រុងបាងកក ប្រទេសថៃ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតផ្នែករូបវិទ្យាពីសាកលវិទ្យាល័យសហ្គាំង នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ។ មុនពេលលោកបន្តការសិក្សាថ្នាក់បណ្ឌិត លោកបណ្ឌិត ត្រូវបានក្រសួងអប់រំ យុវជន និងកីឡា តែងតាំងជាគ្រូឧទ្ទេស អ្នកណែនាំស្រាវជ្រាវ និងជាអ្នកដឹកនាំសិស្សវិទ្យាល័យឆ្នើមថ្នាក់ជាតិសម្រាប់ការប្រកួតប្រជែងក្នុងតំបន់ និងអន្តរជាតិរួមមាន កម្មវិធីជ្រើសរើសអ្នកវិទ្យាសាស្ត្រវ័យ ក្មេង SEAMEO (SSYS), ការប្រកួតប្រជែងរូបវិទ្យាអូឡាំព្យាដអន្តរជាតិ (IPhO), ការប្រកួតប្រជែងរូបវិទ្យាអូឡាំព្យាដទ្វីបអាស៊ី (APhO), និងការប្រកួតអូឡាំព្យាដអន្តរជាតិផ្នែកតារាវិទ្យា និងតារាសាស្ត្រ (IOAA)។ បច្ចុប្បន្ន លោកបណ្ឌិត កំពុងបំពេញការងារនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលក្នុងនោះ លោកបានបង្រៀនមុខវិជ្ជាកម្រិតជាន់ខ្ពស់ជាច្រើន ហើយថ្មីៗនេះលោកបានចាប់ផ្តើមការងារជាអ្នកសម្របសម្រួលកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់រូបវិទ្យា នៃសាលាក្រោយបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ។ បណ្ឌិត ថារិទ្ធ មានចំណាប់អារម្មណ៍ក្នុងការសិក្សាស្រាវជ្រាវក្នុងវិស័យ Condensed Matter Experiment។ បណ្ឌិត ថារិទ្ធ ជាអ្នកនិពន្ធ និងជាសហនិពន្ធឯកសារនិងអត្ថបទស្រាវជ្រាវជាច្រើននៅក្នុងទិនានុប្បវត្តិ នៅក្នុងវិស័យ Condensed Matter Experiment ថាមពលកកើតឡើងវិញ និងបច្ចេកវិទ្យាទំនាក់ទំនងរវាងឧបករណ៍ឥតខ្សែ និងកុំព្យូទ័រចល័ត។

**បណ្ឌិត ហ៊ុល សៀងហេង** ជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ លោកបណ្ឌិត ធ្លាប់បម្រើការងារនៅគ្រឹះស្ថានឧត្តមសិក្សាអស់រយៈពេលជាង ១០ឆ្នាំ។ ចំណង់ចំណូលចិត្តរបស់លោកបណ្ឌិតលើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានជំរុញឱ្យលោកជ្រើសរើសមុខជំនាញវិស្វកម្ម សម្រាប់ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។ អត្ថបទស្រាវជ្រាវរបស់លោកបណ្ឌិតផ្តោតលើបញ្ញាសិប្បនិម្មិត ដែលត្រូវបានប្រើប្រាស់នៅក្នុងឧស្សាហកម្មកែច្នៃ និងបច្ចេកវិទ្យាពាក់ព័ន្ធ និងការគ្រប់គ្រងទឹក។ លោកបណ្ឌិត ក៏ត្រូវបានអញ្ជើញជាវាគ្មិនកិត្តិយស ដើម្បីថ្លែងសុន្ទរកថាគន្លឹះ នៅក្នុងកម្មវិធីវិទ្យាសាស្ត្រថ្នាក់ជាតិ និងអន្តរជាតិ ជាង១០០លើកផងដែរ។ ក្រៅពីការងារគោល លោកក៏មានឆន្ទៈក្នុងការលើកកម្ពស់វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ទៅកាន់មនុស្សជំនាន់ក្រោយ ដើម្បីសំដៅសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

**បណ្ឌិត អ៊ុន លាង** ជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ លោកបណ្ឌិតបានបញ្ចប់ការសិក្សាផ្នែកវិទ្យាសាស្ត្រសង្គម និងអាកប្បកិរិយាពីសាកលវិទ្យាល័យ Amsterdam ប្រទេសហូឡង់។ លោកបណ្ឌិត ធ្លាប់ជាអនុប្រធាននាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគម្រោងការច្នៃប្រឌិត និងអភិវឌ្ឍន៍ HEQCIP ឧបត្ថម្ភដោយធនាគារពិភពលោក និងជាអគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ នៃក្រសួងអប់រំ យុវជន និងកីឡា ចន្លោះឆ្នាំ ២០១២ និង ២០១៦។ លោកបណ្ឌិត ក៏ធ្លាប់ជាអ្នកស្រាវជ្រាវ និង Visiting Scholar នៅសាកលវិទ្យាល័យ Makerere (ប្រទេសអ៊ូហ្គង់ដា) ក្នុងឆ្នាំ២០០៩ នៅសាកលវិទ្យាល័យ Northern Illinois (សហរដ្ឋអាមេរិក) ក្នុងឆ្នាំ២០១១ និងជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៅមជ្ឈមណ្ឌលខេមរសិក្សាក្នុងឆ្នាំ២០១៤។ បច្ចុប្បន្ន លោកបណ្ឌិត ជាព្រឹទ្ធបុរសនៃមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ បន្ថែមពីលើការងារស្នូល ចំណាប់អារម្មណ៍ស្រាវជ្រាវ និងការបោះពុម្ពរបស់លោក គ្របដណ្តប់លើបញ្ហាដូចជាការអប់រំប្រៀបធៀប គោលនយោបាយអប់រំ និងការរួមចំណែករបស់ការអប់រំដល់ការអភិវឌ្ឍក្នុងអំឡុងពេលក្រោយជម្លោះ ដោយថ្មីៗនេះមានទំនោរទៅរកវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ។

**ជា មុយគីម** ជាអនុប្រធានកម្មវិធីនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ កញ្ញា បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកសិក្សាអន្តរជាតិពីដេប៉ាតឺម៉ង់សិក្សាអន្តរជាតិ វិទ្យាស្ថានភាសាបរទេស នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ បន្ថែមពីលើមុខវិជ្ជាតម្រង់ទិស ការស្រាវជ្រាវរបស់កញ្ញា ក៏ផ្តោតលើកិច្ចការបរទេស បដិវត្តន៍ឧស្សាហកម្ម ការអប់រំ យុវជន និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចផងដែរ។

# ជំនួយការស្រាវជ្រាវ

**សុខ គុណវឌ្ឍន៍** គឺជាអ្នកសម្របសម្រួលគម្រោង និងបច្ចេកទេសនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ លោក បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកទំនាក់ទំនងអន្តរជាតិ ពីដេប៉ាតឺម៉ង់សិក្សាអន្តរជាតិ វិទ្យាស្ថានភាសាបរទេស នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងបរិញ្ញាបត្រវិទ្យាសាស្ត្រកុំព្យូទ័រ និងវិស្វកម្ម ពីដេប៉ាតឺម៉ង់វិទ្យាសាស្ត្រកុំព្យូទ័រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**ឡុង បូរ៉ា** គឺជា Junior Research Fellow នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ លោក ក៏ជាសមាជិកនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងដៃគូក្រៅប្រទេស សហភាពសហព័ន្ធយុវជនកម្ពុជា ផងដែរ។ លោក ឡុង បូរ៉ា បានចំណាយពេលជាង ០២ឆ្នាំ ធ្វើការនៅក្រុមហ៊ុនផលិតភេសជ្ជៈក្នុងស្រុកមួយ បន្ទាប់ពីលោកទទួលបានបរិញ្ញាបត្រផ្នែកកសិ-ឧស្សាហកម្ម ពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ បន្ថែមពីនេះ លោកក៏ទទួលបានបរិញ្ញាបត្រជំនាញទំនាក់ទំនងអន្តរជាតិពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ផងដែរ។

**គីម ពីសុទ្ធី** បច្ចុប្បន្នជាមន្ត្រីរដ្ឋបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងអនុបណ្ឌិតផ្នែកភូមិបាល និងបេតិកភណ្ឌ ក្រោមកិច្ចសហប្រតិបត្តិការជាមួយ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យ Jean Moulin Lyon3 ( សាធារណរដ្ឋបារាំង )។

# សេចក្តីថ្លែងអំណរគុណ

ក្រុមអ្នកស្រាវជ្រាវសូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ក្រោមការដឹកនាំរបស់ **លោក ជាវ អានសាន** នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ដែលបានអនុញ្ញាតឱ្យក្រុមអ្នកស្រាវជ្រាវធ្វើការសិក្សា និងដាក់ស្នើគំរូអប់រំស្នែមថ្មីមួយសម្រាប់វិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ។ ការគាំទ្រផ្នែកហិរញ្ញវត្ថុពីមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា បូករួមទាំងការណែនាំនិងការផ្តល់អនុសាសន៍ដ៏មានតម្លៃពីលោកនាយកប្រតិបត្តិ ព្រមទាំងការគាំទ្រចំបាច់នានាពីក្រុមការងាររបស់ឯកឧត្តម នៅក្នុងដំណើរការសិក្សាស្រាវជ្រាវទាំងស្រុងនេះ គឺពិតជាគួរឱ្យកោតសរសើរ។

ក្រៅពីការប្រមូលទិន្នន័យ និងការបញ្ចូលទិន្នន័យដោយជំនួយការស្រាវជ្រាវ ក្រុមការងារក៏សូមកោតសរសើរ ចំពោះការចូលរួមដ៏មានសារសំខាន់របស់អ្នកចូលរួមទាំងអស់ដែលបានផ្តល់ព័ត៌មានដ៏មានតម្លៃ ឈានទៅដល់ការសម្រេចបានរបាយការណ៍ស្រាវជ្រាវមួយនេះ។

ជាចុងក្រោយ ក្រុមអ្នកស្រាវជ្រាវសូមថ្លែងអំណរគុណដល់ **លោក ព្រីង មរកត** ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅនៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការជួយសម្របសម្រួលក្នុងដំណើរការប្រមូលទិន្នន័យ ព្រមទាំង **បណ្ឌិត សាផន សុមោលីរស្មី** និង **បណ្ឌិត ហេង គ្រេង** សម្រាប់ការពិនិត្យឡើងវិញ និងការផ្តល់មតិដ៏មានតម្លៃសម្រាប់របាយការណ៍មួយនេះ។

# បញ្ជីពាក្យកាត់

| | |
|---|---|
| APho | ការប្រកួតប្រជែងរូបវិទ្យាអូឡាំពិចអាស៊ី |
| APMO | ការប្រកួតប្រជែងគណិតវិទ្យាអូឡាំពិចអាស៊ីប៉ាស៊ីហ្វិក |
| APT-JSO | ការប្រកួតប្រជែងអ្នកវិទ្យាសាស្ត្រវ័យក្មេងអាស៊ានបូកបី |
| ESP | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| HEIs | គ្រឹះស្ថានអប់រំឧត្តមសិក្សា |
| IBL | វិធីសាស្ត្ររៀនតាមបែបរិះរក |
| ICT | បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន |
| IMO | ការប្រលងគណិតវិទ្យាអូឡាំពិចអន្តរជាតិ |
| IOAA | ការប្រកួតប្រជែងអូឡាំពិចអន្តរជាតិអំពីតារាវិទ្យា និងរូបវិទ្យាតារា |
| IPhO | ការប្រកួតប្រជែងរូបវិទ្យាអូឡាំពិចអន្តរជាតិ |
| IJSO | ការប្រកួតប្រជែងអ្នកវិទ្យាសាស្ត្រវ័យក្មេងអូឡាំពិច |
| IR 4.0 | បដិវត្តន៍ឧស្សាហកម្មទី៤ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| NEA | ទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| NGS | សាលារៀនជំនាន់ថ្មី |
| PISA | កម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស |
| SDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SEAMEO | អង្គការរដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍ |
| SEIP | គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា |
| SMC | គណៈកម្មការគ្រប់គ្រងសាលា |
| SMET | វិទ្យាសាស្ត្រ គណិតវិទ្យា វិស្វកម្ម និងបច្ចេកវិទ្យា |
| SSYS | ការស្វែងរកអ្នកវិទ្យាសាស្ត្រវ័យក្មេងរបស់អង្គការរដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍ |
| STEM | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា |
| TIMSS | និន្នាការក្នុងការសិក្សាគណិតវិទ្យា និងវិទ្យាសាស្ត្រអន្តរជាតិ |

# សេចក្តីសង្ខេប


នៅក្នុងប្រវត្តិសាស្ត្រនៃការវិវត្តរបស់មនុស្សជាតិ ជាពិសេសនៅក្នុងគ្រប់ទម្រង់នៃការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ការអប់រំ គឺ ជាសសរស្តម្ភដ៏សំខាន់បំផុត។ បើគ្មានការអប់រំត្រឹមត្រូវសម្រាប់ទាំងអស់គ្នាទេនោះ វានឹងពិបាកក្នុងការសម្រេចបាននូវគោលដៅទាំង ១៧ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ជាឧត្តមគតិប្រកបដោយមហិច្ឆតា ធំមួយដែលត្រូវបានកំណត់ដោយអង្គការសហប្រជាជាតិក្នុងឆ្នាំ២០១៥។ ប្រព័ន្ធអប់រំដ៏សមស្របរបស់ប្រទេសមួយនឹងត្រួសត្រាយផ្លូវឆ្ពោះទៅរកភាពរីកចម្រើនប្រកបដោយចីរភាព និងបរិយាប័ន្នក៏ដូចជាការអភិវឌ្ឍសង្គម-នយោបាយ និងសេដ្ឋកិច្ច។ ការវិនិយោគលើកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍវិស័យអប់រំត្រូវការការប្តេជ្ញាចិត្ត និងការរៀបចំផែនការរយៈពេលវែង ពីកម្រិតជាតិ ស្ថាប័ន និងបុគ្គល។ ការយល់ឃើញទូទៅយល់ស្របថា ការអភិវឌ្ឍប្រទេសជាតិមួយ គឺប្រៀបបានទៅនឹងការដើរលើគន្លងដ៏ងងឹតមួយ ប្រសិនបើការអប់រំសម្រាប់មនុស្សជំនាន់ក្រោយមិនមាននៅក្នុងរបៀបវារៈអាទិភាពរបស់ប្រទេសទេនោះ។ តាមទ្រឹស្តី ការអប់រំទូទៅចាប់ពីកម្រិតមត្តេយ្យដល់មធ្យមសិក្សា ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីតម្រង់ទិសប្រជាពលរដ្ឋ នៅក្នុងសហគមន៍ណាមួយស្របពេលដែលការអប់រំកម្រិតឧត្តមសិក្សា ត្រូវបានបង្កើតឡើងដើម្បីបម្រើដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ យ៉ាងណាក៏ដោយ ការតភ្ជាប់កម្រិតទាំងពីរ នៅតែជាកិច្ចការគន្លឹះមួយសម្រាប់អ្នកបង្កើតគោលនយោបាយក្នុងវិស័យអប់រំ ដោយសារតែបរិបទអាចមានភាពខុសគ្នាពីមួយទៅមួយ។ និន្នាការនាពេលថ្មីៗនេះ ហាក់ដូចជាផ្តល់តម្លៃលើសារ-សំខាន់នៃការអប់រំលើវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM ឬស្ទែម)។ ការយល់ដឹងទូទៅក្នុងចំណោមអ្នកបង្កើតគោលនយោបាយ មើលឃើញពីតម្រូវការក្នុងការរួមបញ្ចូលស្ទែមទៅក្នុងរបៀបវារៈនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

ទស្សនវិជ្ជាដ៏សមប្រកបនៃការអប់រំ ត្រូវបានបង្កើតឡើងដើម្បីបម្រើដល់ផលប្រយោជន៍ និងសន្តិ-សុខជាតិ។ ដូច្នេះ ការអប់រំស្ទែមទទួលបានការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកចម្រើន ដូចជា កម្ពុជា ជាដើម។ ទោះបីទំនាក់ទំនងដ៏ស្មុគស្មាញរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងការអប់រំស្ទែម ពិបាកយល់យ៉ាងណាក៏ដោយ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ជាទូទៅមើលឃើញពីភាពចាំបាច់សម្រាប់ការវិនិយោគលើមុខវិជ្ជាដែលទាក់ទងនឹងវិទ្យាសាស្ត្រ ក្នុងចំណោមសាលាអប់រំទូទៅ។ ជាក់ស្តែង កម្រិតមធ្យមសិក្សាទុតិយភូមិ ដែលស្មើនឹងថ្នាក់ទី១០-១២ នៅកម្ពុជា ជាកម្រិតគោលដៅចម្បងដែលអ្នកបង្កើតគោលនយោបាយយកចិត្តទុកដាក់។ ជាទូទៅ សិស្សានុសិស្សនៅកម្រិតនេះមានសមត្ថភាពត្រិះរិះពិចារណាគ្រប់គ្រាន់ ដើម្បីត្រៀមខ្លួនសម្រាប់ជីវិតរបស់ពួកគេនាពេលអនាគត មិនថាចូលទៅក្នុងទីផ្សារការងារ ឬបន្តការសិក្សាដល់កម្រិតឧត្តមនោះទេ នៅពេលដែលមានការណែនាំត្រឹមត្រូវពីគ្រូរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ការណែនាំតម្រង់ទិសដោយផ្ទាល់ អមដោយខ្លឹមសារគំរូអប់រំស្ទែមដែលត្រូវបានរៀបចំយ៉ាងល្អ នៅតែជាឆ្អឹងខ្នងយ៉ាងសំខាន់ដើម្បីធានាបាននូវការផ្សារភ្ជាប់ដ៏ត្រឹមត្រូវរវាងការអប់រំ និងវិថីជីវិតនាពេលអនាគត សម្រាប់ការអភិវឌ្ឍប្រទេសជាតិរយៈពេលយូរ។

ចក្ខុវិស័យរបស់កម្ពុជាសម្រាប់ការអប់រំស្ទែម ត្រូវបានបំផុសគំនិតដោយហេតុផលដែលបានលើកឡើងខាងលើនេះ។ គោលនយោបាយអប់រំស្ទែម ត្រូវបានដាក់ចេញដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០១៦ ក្នុងគោលបំណងសំខាន់ដើម្បីកែលម្អប្រព័ន្ធអប់រំឱ្យកាន់តែប្រសើរឡើង ដើម្បីអាចសម្រេចរបៀបវារៈនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា ពោលគឺក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ នៅទូទាំងប្រទេស គំរូអប់រំស្ទែមជាច្រើនត្រូវបានអនុវត្តសាកល្បងរួមមាន សាលារៀនជំនាន់ថ្មី (NGS) និងសាលាអ៊ីធូស្ទែម (E2STEM) ក្នុងចំណោមគំរូផ្សេងៗទៀត។ ជាទូទៅ គំរូអប់រំថ្មីទាំងនេះទទួលបានការសាទរពីសំណាក់សាធារណជន។ យ៉ាងណាក្តី អ្នកបង្កើតគោលនយោបាយអប់រំ ក៏ដូចជាទស្សនវិទូផ្នែកអប់រំជឿថា គំរូអប់រំមួយដែលមានលក្ខណៈសមរម្យ ស្របទៅតាមបរិបទក្នុងស្រុក គឺមានសារសំខាន់សម្រាប់កម្ពុជា។ ហេតុដូច្នេះហើយ ខេត្តកំពង់ស្ពឺ ដែលជាខេត្តមួយមានស្ថានភាពភូមិសាស្ត្រអំណោយផលសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម ត្រូវបានមើលឃើញថាជាជម្រើសដ៏សមស្របនៃការសិក្សាសម្រាប់ស្វែងរកគំរូអប់រំស្ទែម ដើម្បីជួយដោះស្រាយតម្រូវការក្នុងស្រុក ជាពិសេសនៅក្នុងវិស័យឧស្សាហកម្ម។

វត្ថុបំណងនៃការសិក្សា គឺដើម្បីស្វែងរកគំរូអប់រំស្ទែមដែលសមស្របបំផុតសម្រាប់ខេត្តកំពង់ស្ពឺ ដែលជាខេត្តមួយមានលក្ខខណ្ឌគ្រប់គ្រាន់ ដើម្បីស្នើគំរូអប់រំមួយដែលមានសក្តានុពលអាចពង្រីកជាក្របខ័ណ្ឌទូទាំងប្រទេស។ ជាគោលគំនិត ការសិក្សានេះ មានគោលបំណងសំដៅក្នុងការរៀបចំជំនាញរបស់សិស្សបញ្ចប់ការសិក្សា សម្រាប់កម្លាំងពលកម្មដែលពោរពេញដោយជំនាញ ជាពិសេសសម្រាប់តំបន់ឧស្សាហកម្ម និងសម្រាប់ការអប់រំក្រោយមធ្យមសិក្សា ជាមួយនឹងមូលដ្ឋានរឹងមាំក្នុងវិស័យស្ទែម ដើម្បីការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នាពេលអនាគត។ ចំណុចសំខាន់នៃរបាយការណ៍នេះ គឺដើម្បីផ្តល់ជាគំរូសម្រាប់វិទ្យាល័យស្ទែម ដែលសមស្របសម្រាប់ខេត្តកំពង់ស្ពឺ ដើម្បីស្នើវិទ្យាល័យមួយក្នុងខេត្តកំពង់ស្ពឺ ឱ្យប្រែក្លាយទៅជាវិទ្យាល័យស្ទែម ដើម្បីអាចក្លាយខ្លួនជាសាលាស្ទែមឈានមុខគេមួយក្នុងប្រទេស និងដើម្បីផ្តល់អនុសាសន៍សម្រាប់ដំណើរការផ្លាស់ប្តូរ ទាក់ទងនឹងការរៀបចំនិងការអនុវត្តគំរូនេះ។ ការសិក្សានេះប្រើវិធីសាស្ត្រចម្រុះ ដូចជា ការពិនិត្យឯកសារពាក់ព័ន្ធនានា កម្រងសំណួរសម្រាប់គ្រូបង្រៀន ការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធសម្រាប់នាយក នាយករងនិងគណៈគ្រប់គ្រងសាលា និងការចុះវាយតម្លៃនៅទីតាំងផ្ទាល់ ដែលរួមមានបញ្ជីវាយតម្លៃនិងសង្កេត សម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តទូទៅនៅក្នុងសាលារៀនចំនួន ០៥ ដែលបានជ្រើសរើសនៅក្នុងខេត្តកំពង់ស្ពឺ។

ទស្សនាទាននៃ ការអប់រំស្ទែមបែបរួមបញ្ចូល គឺត្រូវបានស្នើជាគំរូមួយសម្រាប់បរិបទនៅក្នុងខេត្តកំពង់ស្ពឺផ្ទាល់។ គោលដៅធំបំផុតនៃគំរូនេះ គឺដើម្បីទទួលបានធនធានមនុស្សដែលមានជំនាញ ដើម្បីបំពេញតម្រូវការកម្លាំងពលកម្មនាពេលអនាគត សម្រាប់ឧស្សាហកម្មប្រកបដោយនវានុវត្តន៍នៅក្នុងបរិបទបដិវត្តន៍ឧស្សាហកម្មទី៤ (IR 4.0)។ គំរូអប់រំមួយនេះតម្រូវឱ្យមានការបញ្ចូលគ្នានៃវិធីសាស្ត្របង្រៀន និងរៀន ដែលបានមកពីគោលគំនិតទូទៅនៃវិធីសាស្ត្ររៀនតាមបែបរិះរក វិធីសាស្ត្ររៀនផ្អែកលើគម្រោង និងវិធីសាស្ត្ររៀនតាមបែបដោះស្រាយបញ្ហា។ លើសពីនេះ មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ត្រូវបាន

មើលឃើញថាជាមុខវិជ្ជាដែលមានខ្លឹមសារ និងប្រើជាឧបករណ៍សម្រាប់ដោះស្រាយបញ្ហាដែលប្រឈមនឹងតម្រូវការក្នុងវិស័យឧស្សាហកម្ម ក៏ដូចជាការប្រមូលផ្តុំជំនាញខ្ពស់នាពេលអនាគត។ លើសពីនេះ ការផ្តោតលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រគឺដោយសារតែគុណភាពនៃការបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាសម្រាប់បន្តទៅកម្រិតឧត្តមសិក្សា ជាសរសរស្តម្ភ យ៉ាងសំខាន់មួយបន្ថែមទៀតនៅក្នុងគំរូដែលបានស្នើឡើងនេះ។ កំណែទម្រង់នៃខ្លឹមសារ ការបង្រៀន និងរៀន គុណវុឌ្ឍិរបស់គ្រូ ហេដ្ឋារចនាសម្ព័ន្ធ រចនាសម្ព័ន្ធអភិបាលកិច្ច រចនាសម្ព័ន្ធគ្រប់គ្រង និងហិរញ្ញប្បទាន គឺជាមូលដ្ឋានគ្រឹះនៃការអប់រំស្នែមបែបរួមបញ្ចូលនេះ។ ជាតុសំខាន់ៗលម្អិតនៃកំណែទម្រង់ ត្រូវបានស្នើឡើងនៅក្នុងការសិក្សាមួយនេះ។

ការសិក្សានេះសន្និដ្ឋានថា ការអប់រំស្នែមបែបរួមបញ្ចូល គឺជាវិធីសាស្ត្រមួយដែលសមស្របបំផុតសម្រាប់បរិបទ ខេត្តកំពង់ស្ពឺ។ វាទំនងជាអាចនិយាយបានថា គំរូស្នែមបច្ចុប្បន្នអាចមានការចំណាយច្រើន ហេតុនេះមិនអាចពង្រីកខ្លួនក្នុងទ្រង់ទ្រាយធំទូលាយបាន ដែលបង្កជាការព្រួយបារម្ភអំពីសមភាពនៃការទទួលបានការអប់រំស្នែមដែលមានគុណភាព។ បញ្ហាប្រឈមផ្សេងទៀត ដែលគំរូស្នែមសព្វថ្ងៃកំពុងប្រឈម គឺការផ្សារភ្ជាប់គំរូអប់រំនោះទៅនឹងបរិបទក្នុងស្រុក។ គំរូអប់រំដែលបានស្នើឡើងនេះ ត្រូវបានមើលឃើញថាមានភាពបត់បែនជាងគំរូបច្ចុប្បន្ន ទាក់ទងនឹងការអនុវត្តរបស់វាសម្រាប់បរិបទក្នុងស្រុក។ ការសិក្សាក៏រកឃើញផងដែរថា វិទ្យាល័យកំពង់ស្ពឺ គឺជាជម្រើសដ៏ល្អបំផុតសម្រាប់ការសាកល្បងគំរូស្នែមថ្មីនេះ ដោយសារតែវាមានរួចជាស្រេចនូវបុរេលក្ខខណ្ឌសម្រាប់ការអនុវត្ត។

# ១. សេចក្ដីផ្ដើម

## ១.១. បរិបទ

ដូចដែលប្រវត្តិសាស្ត្រដ៏យូរលង់បានបង្ហាញ មនុស្សជាតិបានព្យាយាមឥតឈប់ឈរដើម្បីធ្វើឱ្យជីវភាពរស់នៅរបស់គេកាន់តែល្អប្រសើរឡើង។ យ៉ាងណាក្ដី ការសិក្សាជាប្រព័ន្ធលើការប្រឹងប្រែងទាំងនេះបានក្លាយជាជំនាញនៃការសិក្សាកម្រិតឧត្តមមួយដែលគេហៅថា "ការសិក្សាអំពីការអភិវឌ្ឍ" បានលេចឡើងត្រឹមប្រាំពីរទសវត្សរ៍មុននេះតែប៉ុណ្ណោះ ពេលគឺក្រោយសង្គ្រាមលោកលើកទីពីរបានបញ្ចប់។ ទោះបីជា ការអភិវឌ្ឍពាក់ព័ន្ធនឹងទិដ្ឋភាពជាច្រើនដូចជាសង្គម នយោបាយ និងវប្បធម៌ក៏ដោយ កំណើនសេដ្ឋកិច្ចត្រូវបានចាត់ទុកថាជាគន្លឹះដ៏សំខាន់ ដោយសារវាផ្ដល់នូវធនធានសម្រាប់ពន្លឿនការអភិវឌ្ឍនៅក្នុងទិដ្ឋភាពផ្សេងៗទៀត។ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០ មក ការសិក្សាច្រើនរាប់មិនអស់បានព្យាយាមស៊ើបអង្កេតពីមូលហេតុនៃការអភិវឌ្ឍសេដ្ឋកិច្ចក្នុងប្រទេសជាក់លាក់មួយចំនួន និងសិក្សាប្រៀបធៀបរវាងប្រទេសនៅក្នុងទ្វីបដូចគ្នា និងរវាងប្រទេសដទៃទៀតទូទាំងទ្វីបនានា ដើម្បីស្វែងរកមូលហេតុដែលធ្វើឱ្យប្រទេសមួយចំនួនមានដំណើរអភិវឌ្ឍន៍សេដ្ឋកិច្ចប្រសើរជាងប្រទេសដទៃទៀតក្នុងរយៈពេលវែង។

ជំនាញនៃការសិក្សាកម្រិតឧត្តមជាច្រើនផ្សេងគ្នា ផ្ដល់នូវការពន្យល់យ៉ាងទូលំទូលាយអំពីមូលហេតុនៃការអភិវឌ្ឍសេដ្ឋកិច្ច។ យ៉ាងណាក្ដី ការសិក្សាដែលលេចធ្លោបំផុតបានផ្ដោតទៅលើតួនាទីរបស់ស្ថាប័នហិរញ្ញវត្ថុ (ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាប្រព័ន្ធដែលបានកំណត់យ៉ាងច្បាស់អំពីសិទ្ធិអចលនទ្រព្យ, និងការបើកចំហសេដ្ឋកិច្ច) និងបរិយាកាសសមប្រកបសម្រាប់អាជីវកម្ម ដូចជាការលើកទឹកចិត្តដល់អ្នកវិនិយោគ និងអភិបាលកិច្ចល្អ ថាជាហេតុផលមូលដ្ឋាននៃភាពខុសគ្នានៅក្នុងដំណើរអភិវឌ្ឍន៍សេដ្ឋកិច្ច (Benhabib and Spiegel, 1994; López et al., 1998; Easterly, 2001)។ ទោះបីជាកត្តាទាំងនេះចាំបាច់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក៏ដោយ ក៏វាមិនមែនជាលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីធានាបាននូវសេដ្ឋកិច្ចមួយដែលមានភាពរីកចម្រើនដែរ។

ជាការសន្និដ្ឋាន ការវិនិយោគលើមូលធនមនុស្សក្នុងការអប់រំ គឺជាកត្តាមូលដ្ឋានគ្រឹះមួយសម្រាប់ការរីកចម្រើនសេដ្ឋកិច្ច។ តួនាទីការអប់រំ ត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងបទពិសោធន៍ជោគជ័យនៅបណ្ដាប្រទេសអាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍មួយចំនួនដូចជាចិន សិង្ហបុរី កូរ៉េខាងត្បូង ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងវៀតណាម។ ទោះបីប្រទេសទាំងនេះមានកម្រិតផ្សេងៗគ្នានៃស្ថាប័នសេដ្ឋកិច្ច បរិយាកាសសម្រាប់អាជីវកម្ម និងអភិបាលកិច្ចល្អក៏ដោយ ពួកគេមានកត្តារួមមួយដែលរួមចំណែកដល់ការរីកចម្រើននៃសេដ្ឋកិច្ចរបស់ពួកគេ គឺចំណាប់អារម្មណ៍យ៉ាងខ្លាំងលើការវិនិយោគក្នុងវិស័យអប់រំ (Economist, 1991; Morris, 1996)។

យ៉ាងនេះក៏ដោយ ការអភិវឌ្ឍវិស័យអប់រំ គឺជាបញ្ហាស្មុគស្មាញ ជាពិសេសនៅពេលដែលវាត្រូវបានធ្វើឡើងជាមួយនឹងគោលបំណងសំខាន់បំផុតក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជារួម។ វារួមមាន អនុវិស័យជាច្រើនដូចជាបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា និងការតម្រង់ទិសផ្សេងៗ

ទៀត។ ជាបរិបទ ការអប់រំកម្រិតមធ្យមសិក្សាកាន់តែមានសារសំខាន់ឡើង ដោយសារតែវាជាចំណុចនៃកម្រិតអប់រំដែលសិស្សភាគច្រើនត្រូវចូលក្នុងទីផ្សារការងារភ្លាមៗ ឬប្រើប្រាស់វាជាមូលដ្ឋានគ្រឹះសម្រាប់ថ្នាក់ឧត្តមសិក្សា ដែលជាកន្លែងដែលកម្លាំងពលកម្មមានជំនាញខ្ពស់ អាចទទួលបានការបណ្តុះបណ្តាលប្រកប ដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

Un et al. (2014) រកឃើញថា នៅកម្ពុជា ប្រហែល ២០% នៃសិស្សវិទ្យាល័យ បានសម្រេចចិត្តចូលធ្វើការភ្លាមៗ បន្ទាប់ពីបានបញ្ចប់ថ្នាក់វិទ្យាល័យ។ ការស្ទង់មតិដែលធ្វើឡើងដោយ ទីភ្នាក់ងារជាតិមុខរបរ និងការងារ (2014) ក៏បានបង្ហាញ ផងដែរថា ទីផ្សារការងារភាគច្រើននៅកម្ពុជា ទាមទារការអប់រំត្រឹមតែកម្រិតមធ្យមសិក្សាប៉ុណ្ណោះ ហើយទីផ្សារការងារ ត្រូវបានចាត់ថ្នាក់ជាក្រុមធំៗចំនួន ០៤ គឺជំនាញខ្ពស់ ជំនាញមិនមែនហត្ថកម្ម ជំនាញហត្ថកម្ម និងការងារមិនត្រូវការជំនាញ។ លើសពីនេះ ការវិភាគប្រៀបធៀបនៅតាមប្រទេស និងតំបន់ជាច្រើន បង្ហាញថាគុណភាពនៃការអប់រំ ឬការសិក្សាមានការឆ្លើយតបគ្នាទៅនឹងកំណើនសេដ្ឋកិច្ចរយៈពេលវែង (Burnett, 2013; Hanushek and Kimbo, 2000; Hanushek and Wößmann, 2007)។ នៅចំណុចរបត់នៃសហស្សវត្សរ៍នេះ ជំនាញយល់ដឹងដ៏សំខាន់បំផុតដែលចាំបាច់សម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច គឺជាជំនាញទាំងឡាយណាដែលទាក់ទងនឹងវិទ្យា-សាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម) ដូចដែលបានរកឃើញនៅក្នុងបណ្តាប្រទេសអាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍មួយចំនួន។

## ១.២. ការអប់រំស្ទែម៖ បរិបទសាកល និងកម្ពុជា

នៅឆ្នាំ១៩៥៧ អតីតសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតបានទទួលជោគជ័យក្នុងការបាញ់បង្ហោះ ស្ពុតនិក ១ (Sputnik 1) ដែលជាផ្កាយរណបភពផែនដីសិប្បនិម្មិតដំបូងគេ។ នេះគឺជាព្រឹត្តិការណ៍បច្ចេកវិទ្យាជាប្រវត្តិសាស្ត្រមួយដែលបានបង្កើតឱ្យមាន "ការប្រណាំងប្រជែងផ្នែកអវកាស" រវាងសហរដ្ឋអាមេរិក និងអតីតសហភាពសូវៀត។ ដើម្បីតាមទាន់អតីតសហភាពសូវៀត ប្រធានាធិបតី John F. Kennedy ក្នុងឆ្នាំ១៩៦១ បានកំណត់គោលដៅក្នុងការ "បញ្ជូនមនុស្សទៅឋានព្រះច័ន្ទ ហើយនាំយកគាត់ត្រឡប់មកផែនដីវិញដោយសុវត្ថិភាព"។ ហេតុដូច្នេះ មូលនិធិវិទ្យាសាស្ត្រជាតិត្រូវបានផ្តល់ភារកិច្ចក្នុងការលើកកម្ពស់ការអប់រំ និងការស្រាវជ្រាវក្នុងវិស័យវិទ្យាសាស្ត្រ គណិតវិទ្យា វិស្វកម្ម និងបច្ចេកវិទ្យា ដែលត្រូវបានគេស្គាល់ថា SMET (Science, Mathematics, Engineering and Technology)។ ពាក្យថាការអប់រំ SMET ជាធម្មតាត្រូវបានប្រើ ដើម្បីឆ្លើយតបនឹងគោលនយោបាយអប់រំ ឬជម្រើសកម្មវិធីសិក្សានៅសាលារៀន។

នៅឆ្នាំ២០០១ ពាក្យ ស្ទែម (STEM - Science, Technology, Engineering and Mathematcis) ដែលជាការរៀបចំឡើងវិញចេញពីពាក្យ SMET ត្រូវបានបង្កើតឡើង។ ក្នុងពេលនោះ សហរដ្ឋអាមេរិក បានមើលឃើញបរិបទថ្មីសម្រាប់កែទម្រង់ប្រព័ន្ធអប់រំ និងការអប់រំស្ទែមដើម្បីប្រជែងនឹងមហាអំណាចអាស៊ីដែលកំពុងរីកចម្រើន។ គេជឿថា ការលេចឡើងនៃមហាអំណាចអាស៊ី គឺដោយសារ

តែការកើនឡើងនៃតួនាទីការអប់រំស្វែម ក្នុងការលើកកម្ពស់អំណាចសេដ្ឋកិច្ចរបស់ប្រទេសទាំងនោះ ជាពិសេសចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០។ វាត្រូវបានឆ្លុះបញ្ចាំងនៅក្នុងលំដាប់ថ្នាក់របស់សហរដ្ឋអាមេរិកក្នុងការប្រឡងអន្តរជាតិនានា ដែលស្ថិតនៅលំដាប់ទាបជាងបណ្ដាប្រទេសអាស៊ីដែលកំពុងរីកចម្រើនដូចជាក្នុងប្រលងតេស្ត និន្នាការក្នុងការសិក្សាគណិតវិទ្យា និងវិទ្យាសាស្ត្រអន្តរជាតិ (TIMSS)[1] និងកម្មវិធីអន្តរជាតិស្ដីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស (PISA)[2] ដែលជាការវាយតម្លៃ រយៈពេល ៣ឆ្នាំម្ដងទៅលើចំណេះដឹង និងជំនាញរបស់សិស្សដែលមានអាយុ ១៥ឆ្នាំ ដូចបានឃើញក្នុងតារាងទី១ និងតារាងទី២។

**តារាងទី ១៖** ចំណាត់ថ្នាក់ប្រទេសទាំង ១០ ក្នុងមុខវិជ្ជាគណិតវិទ្យា (ពិន្ទុបង្ហាញ បន្ទាប់ពីឈ្មោះប្រទេសនីមួយៗ)

| ល.រ. | ២០០៣ | ២០០៦ | ២០០៩ | ២០១២ | ២០១៥ | ២០១៨ |
|---|---|---|---|---|---|---|
| ១ | ហុងកុង ៥៥០ | តៃវ៉ាន់ ៥៤៩ | សិង្ហបុរី ៥៦២ | សិង្ហបុរី ៥៧៣ | សិង្ហបុរី ៥៦៤ | ចិន (BSJ-G) ៥៩១ |
| ២ | ហ្វាំងឡង់ ៥៤៤ | ហ្វាំងឡង់ ៥៤៨ | ហុងកុង ៥៥៥ | ហុងកុង ៥៦១ | ហុងកុង ៥៤៨ | សិង្ហបុរី ៥៦៩ |
| ៣ | កូរ៉េខាងត្បូង ៥៤២ | ហុងកុង ៥៤៧ | កូរ៉េខាងត្បូង ៥៤៦ | តៃវ៉ាន់ ៥៦០ | ម៉ាកាវ ៥៤៤ | ម៉ាកាវ (ចិន) ៥៥៨ |
| ៤ | ហូឡង់ ៥៣៨ | កូរ៉េខាងត្បូង ៥៤៧ | តៃវ៉ាន់ ៥៤៣ | កូរ៉េខាងត្បូង ៥៥៤ | តៃវ៉ាន់ ៥៤២ | ហុងកុង (ចិន) ៥៥១ |
| ៥ | ជប៉ុន ៥៣៤ | ហូឡង់ ៥៣១ | ហ្វាំងឡង់ ៥៤១ | ម៉ាកាវ ៥៣៨ | ជប៉ុន ៥៣២ | តៃវ៉ាន់ ៥៣១ |
| ៦ | កាណាដា ៥៣២ | ស្វីស ៥៣០ | ស្វីស ៥៣៤ | ជប៉ុន ៥៣៦ | ចិន (BSJ-G) ៥៣១ | ជប៉ុន ៥២៧ |
| ៧ | បែលហ្ស៊ិក ៥២៩ | កាណាដា ៥២៧ | ជប៉ុន ៥២៩ | ស្វីស ៥៣១ | កូរ៉េខាងត្បូង ៥២៤ | កូរ៉េខាងត្បូង ៥២៦ |
| ៨ | ស្វីស ៥២៧ | ម៉ាកាវ ៥២៥ | កាណាដា ៥២៧ | ហូឡង់ ៥២៣ | ស្វីស ៥២១ | អេស្តូនី ៥២៣ |
| ៩ | ម៉ាកាវ ៥២៧ | ជប៉ុន ៥២៣ | ហូឡង់ ៥២៦ | អេស្តូនី ៥២១ | អេស្តូនី ៥២០ | ហូឡង់ ៥១៩ |
| ១០ | អូស្ត្រាលី ៥២៤ | នូវែលសេឡង់ ៥២២ | ម៉ាកាវ ៥២៥ | ហ្វាំងឡង់ ៥១៩ | កាណាដា ៥១៦ | ប៉ូឡូញ ៥១៦ |

__ប្រភព៖__ ចងក្រងពីឆ្នាំផ្សេងៗគ្នា

---

1 រួមជាមួយនឹងទិន្នន័យសមិទ្ធផលរបស់សិស្សជារួម ការវាយតម្លៃដ៏ទូលំទូលាយរបស់និន្នាការក្នុងការសិក្សាគណិតវិទ្យា និងវិទ្យាសាស្ត្រអន្តរជាតិ (TIMSS) មានទិន្នន័យអំពីការសិក្សារបស់សិស្សក្នុងផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រផ្សេងៗ (ពិជគណិត ធរណីមាត្រ ជីវវិទ្យា គីមីវិទ្យា ។ល។) និងការអនុវត្តក្នុងបញ្ហាប្រឈមដែលតម្រូវឱ្យមានការដោះស្រាយបញ្ហា នៅក្នុងបរិបទនីមួយៗទាំងនេះ។

2 កម្មវិធីអន្តរជាតិស្ដីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស (PISA) គឺជាការសិក្សាទូទាំងពិភពលោកដោយអង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍសេដ្ឋកិច្ច (OECD) នៅក្នុងប្រទេសជាសមាជិក និងមិនមែនសមាជិក ដោយមានគោលបំណងវាយតម្លៃប្រព័ន្ធអប់រំ តាមរយៈការវាស់ស្ទង់សមត្ថភាពសិក្សារបស់សិស្សអាយុ ១៥ឆ្នាំ លើមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ និងការអាន។

**តារាងទី ២៖** ចំណាត់ថ្នាក់ប្រទេសទាំង ១០ ក្នុងមុខវិជ្ជាវិទ្យាសាស្ត្រលើកម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស (PISA) (ពិន្ទុត្រូវបានបង្ហាញ បន្ទាប់ពីឈ្មោះប្រទេសនីមួយៗ)

| ល.រ. | ២០០៦ | ២០០៩ | ២០១២ | ២០១៥ | ២០១៨ |
|---|---|---|---|---|---|
| ១ | ហ្វាំងឡង់ ៥៦៣ | ហ្វាំងឡង់ ៥៥៤ | ហុងកុង ៥៥៥ | សិង្ហបុរី ៥៥៦ | ចិន (B-S-J-G) ៥៩០ |
| ២ | ហុងកុង ៥៤២ | ហុងកុង ៥៤៩ | សិង្ហបុរី ៥៥១ | ជប៉ុន ៥៣៨ | សិង្ហបុរី ៥៥១ |
| ៣ | កាណាដា ៥៣៤ | សិង្ហបុរី ៥៤២ | ជប៉ុន ៥៤៧ | អេស្តូនី ៥៣៤ | ម៉ាកាវ (ចិន) ៥៤៤ |
| ៤ | តៃវ៉ាន់ ៥៣២ | ជប៉ុន ៥៣៩ | ហ្វាំងឡង់ ៥៤៥ | តៃវ៉ាន់ ៥៣២ | វៀតណាម ៥៤៣ |
| ៥ | ជប៉ុន ៥៣១ | កូរ៉េខាងត្បូង ៥៣៨ | អេស្តូនី ៥៤១ | ហ្វាំងឡង់ ៥៣១ | អេស្តូនី ៥៣០ |
| ៦ | អេស្តូនី ៥៣១ | នូវែលសេឡង់ ៥៣២ | កូរ៉េខាងត្បូង ៥៣៨ | ម៉ាកាវ ៥២៩ | ជប៉ុន ៥២៩ |
| ៧ | នូវែលសេឡង់ ៥៣០ | កាណាដា ៥២៩ | វៀតណាម ៥២៨ | កាណាដា ៥២៨ | ហ្វាំងឡង់ ៥២២ |
| ៨ | អូស្ត្រាលី ៥២៧ | អេស្តូនី ៥២៨ | ប៉ូឡូញ ៥២៦ | វៀតណាម ៥២៥ | កូរ៉េខាងត្បូង ៥១៩ |
| ៩ | ហូឡង់ ៥២៥ | អូស្ត្រាលី ៥២៧ | កាណាដា ៥២៥ | ហុងកុង ៥២៣ | កាណាដា ៥១៨ |
| ១០ | កូរ៉េខាងត្បូង ៥២២ | ហូឡង់ ៥២២ | អាល្លឺម៉ង់ ៥២៤ | ចិន (B-S-J-G) ៥១៨ | ហុងកុង (ចិន) ៥១៧ |

ប្រភព៖ ចងក្រងពីឆ្នាំផ្សេងៗគ្នា

មកទល់នឹងពេលនេះ កម្ពុជានៅមិនទាន់បានចូលរួមជាផ្លូវការក្នុងការវាយតម្លៃអន្តរជាតិទាំងនេះទេ ទោះបីជា នាពេលថ្មីៗនេះ កម្ពុជា បានចូលរួមនៅក្នុង PISA-D ឆ្នាំ២០១៨ ដែលជាការធ្វើតេស្តរបស់ PISA លើការអភិវឌ្ឍក៏ដោយ។ គួរកត់សម្គាល់ថា ប្រទេសដែលមានលំដាប់ពិន្ទុខ្ពស់ជាងគេក្នុងតារាងវង្វាយតម្លៃខាងលើ គឺស្ថិតក្នុងចំណោមប្រទេសអភិវឌ្ឍន៍កម្រិតខ្ពស់។ សម្រាប់កម្ពុជា លទ្ធផលពី PISA-D ឆ្នាំ២០១៨ បង្ហាញថាមានតែ ៨% នៃសិស្សអាយុ ១៥ឆ្នាំប៉ុណ្ណោះ ដែលមានសមត្ថភាពកម្រិត២[3] អប្បបរមា ឬកម្រិតខ្ពស់ជាងនេះក្នុងជំនាញអាន ហើយប្រហែល ១០% មានសមត្ថភាពអប្បបរមា ឬខ្ពស់ជាងនេះក្នុងមុខវិជ្ជាគណិតវិទ្យា។ នៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ កម្ពុជាទទួលបានលទ្ធផលកាន់តែទាប ដែលមាន

[3] ពិន្ទុ ៤១០ ឬខ្ពស់ជាងនេះបង្ហាញថាសិស្សមានកម្រិតជំនាញអប្បបរមា (កម្រិត ២) ស្របតាមកម្រិតសមត្ថភាពគោលដៅនៃការអប់រំ ដែលជាគោលដៅទី៤ នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ កម្រិត ២ គឺជាកម្រិតសមត្ថភាពមូលដ្ឋាននៃកម្រិតទាំង ៦ របស់ PISA-D ឬ PISA ។

ត្រឹម ៥% ប៉ុណ្ណោះ។ ការរកឃើញទាំងនេះហាក់ដូចជាឆ្លុះបញ្ចាំងពីស្ថានការណ៍ដែលកំពុងលើកយកមកពិភាក្សាក្នុងរបាយការណ៍នេះ។ ទស្សនៈរបស់និយោជក គឺជាសូចនាករមួយនៃបញ្ហាប្រឈមជាច្រើន ដែលសិស្សទើបតែបញ្ចប់កម្រិតសិក្សាទុតិយភូមិជួបប្រទះនៅពេលចូលធ្វើការលើកដំបូង។ ជាទូទៅ និយោជកនៅកម្ពុជា ចាត់ទុកថាជំនាញដែលទទួលបានក្នុងកម្រិតមធ្យមសិក្សា មិនឆ្លើយតបនឹងតម្រូវការរបស់ពួកគេនោះទេ។ ការអប់រំនៅកម្ពុជា ផ្តោតលើអ្វីដែលប្រព័ន្ធអប់រំផ្តល់ឱ្យខ្លាំងពេក និងមិនបានផ្សារភ្ជាប់គ្រប់គ្រាន់ទៅនឹងតម្រូវការរបស់និយោជកទេ។ លទ្ធផលនៃការស្ទង់មតិដែលធ្វើឡើងដោយ Burnett (2013) បង្ហាញថា មាននិយោជកត្រឹមតែ ១៣% ប៉ុណ្ណោះ ដែលជឿថា សិស្សបញ្ចប់ការសិក្សាទុតិយភូមិមានជំនាញទាំងអស់ ឬជំនាញភាគច្រើន ដែលឆ្លើយតបនឹងតម្រូវការទីផ្សារការងារ។ ភាពមិនបន្សុីគ្នានេះភាគច្រើនបណ្តាលមកពីសមត្ថភាពនៅមានកម្រិតនៃប្រព័ន្ធអប់រំមធ្យមសិក្សា ក្នុងការផ្តល់ជំនាញដែលចាំបាច់ប្រកបដោយគុណភាពក្នុងកម្រិតគ្រប់គ្រាន់ និងដែលមានភាពពាក់ព័ន្ធទៅនឹងតម្រូវការរបស់និយោជក។ ការណ៍នេះត្រូវបានបង្ហាញដោយការសិក្សាមួយរបស់ CAMFEBA (2008) ដែលក្នុងនោះសិស្សវិទ្យាល័យជឿថា ពួកគេត្រូវការជំនាញបន្ថែមទៀតដើម្បីស្វែងរកការងារ ប្រសិនបើពួកគេចូលប្រឡូកក្នុងវិស័យការងារភ្លាមៗ បន្ទាប់ពីបញ្ចប់ថ្នាក់វិទ្យាល័យ។ ការរកឃើញនេះ ត្រូវបានផ្ទៀងផ្ទាត់បន្ថែមដោយការសិក្សារបស់ Un et al. (2014) ដែលអ្នកចូលរួមជនជាតិខ្មែរនៅក្នុងការស្ទង់មតិជាង ៥០% បានបញ្ជាក់ថា វិទ្យាល័យរបស់ពួកគេមិនទាន់ផ្តល់ឱ្យពួកគេនូវជំនាញគ្រប់គ្រាន់ដែលពួកគេត្រូវការសម្រាប់ការងារនោះទេ។

ក្រៅពីកង្វះខាតជំនាញ ក៏មានគម្លាតជំនាញផងដែរ ពោលគឺបុគ្គលិកដែលមានស្រាប់មិនអាចបំពេញដល់កម្រិតដែលជាតម្រូវការរបស់និយោជក។ ការស្ទង់មតិដែលធ្វើឡើងដោយ ទីភ្នាក់ងារជាតិមុខរបរ និងការងារ (2018) បង្ហាញថា ប្រហែលមួយភាគបី (២៩,២%) នៃគ្រឹះស្ថានដែលត្រូវបានសម្ភាសលើកឡើងថាពួកគេបានជួបប្រទះបញ្ហាគម្លាតជំនាញ (ដែលមានការថយចុះ បើប្រៀបធៀបទៅនឹងការស្ទង់មតិឆ្នាំ២០១៥ ដែលមាន ៣៩,៤%)។ អ្វីដែលកាន់តែគួរឱ្យព្រួយបារម្ភជាងនេះទៅទៀត ថ្វីត្បិតនិយោជកបង្ហាញឆន្ទៈ ក្នុងការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពបុគ្គលិក ដើម្បីបំពេញគម្លាតជំនាញក៏ដោយ ភាគច្រើនពួកគេមានភាពលំបាកក្នុងការរៀបចំវគ្គបណ្តុះបណ្តាលនេះ។ ហេតុផលនៃភាពលំបាកនេះ បង្ហាញពីវដ្តដ៏គ្រោះថ្នាក់នៃកង្វះជំនាញ និងគម្លាតជំនាញ ដែលនិយោជក ៣៥,៦% អះអាងថាមិនមាន ឬខ្វះវគ្គសិក្សា និងអ្នកបណ្តុះបណ្តាល។ ប្រហែល ២៧% នៃនិយោជកលើកឡើងពីគុណភាពទាបនៃវគ្គសិក្សា ឬអ្នកបណ្តុះបណ្តាល ដែលមានផ្តល់ជូន ហើយ ២០,៤% នៃនិយោជក រាយការណ៍ថាពួកគេមិនទទួលបានព័ត៌មានទាល់តែសោះ ឬទទួលបានព័ត៌មានតិចតួចអំពីវគ្គសិក្សា/គ្រូបណ្តុះបណ្តាល ក្នុងចំណោមហេតុផលដទៃទៀត (NEA, 2018)។

សម្រាប់បញ្ហាខាងលើ ការចុះឈ្មោះក្នុងមុខវិជ្ជាដែលទាក់ទងនឹងស្ទែមនៅគ្រឹះស្ថានឧត្តមសិក្សា ក៏ឆ្លុះបញ្ចាំងពី ការត្រៀមខ្លួននៃការសិក្សាថ្នាក់មធ្យមសិក្សាផងដែរ។ ចាប់តាំងពីឆ្នាំ២០១០ មក ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តប្រព័ន្ធមួយ ដែលតម្រូវឱ្យសិស្សថ្នាក់ទី១១ ទាំងអស់ជ្រើសរើសរវាង

វិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម។ ខណៈ ដែលវិទ្យាសាស្ត្រពិតផ្តោតលើមុខវិជ្ជាវិទ្យាសាស្ត្រ (ដូចជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា) និងគណិតវិទ្យា វិទ្យាសាស្ត្រសង្គមផ្តោតលើអក្សរសាស្ត្រខ្មែរ ប្រវត្តិសាស្ត្រ ភូមិវិទ្យា និងសីលធម៌-ពលរដ្ឋ។ ការសិក្សារបស់ Kao និង Shimizu (2020) បង្ហាញថា មានការថយចុះនៃចំនួនសិស្សដែលជ្រើសយកវិទ្យាសាស្ត្រពិត បើទោះបីជាវានៅតែស្ថិតក្នុងតួលេខមួយខ្ពស់ជាងអ្នកដែលជ្រើសយកវិទ្យាសាស្ត្រសង្គមក៏ដោយ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ជាងនេះទៅទៀតនោះគឺថា ទោះបីជាសិស្សថ្នាក់វិទ្យាសាស្ត្រមានភាគរយខ្ពស់នៅកម្រិតមធ្យមសិក្សាក៏ដោយ គេឃើញថាមាននិន្នាការផ្ទុយគ្នា ទាំងស្រុងនៅកម្រិតឧត្តមសិក្សា ដូចដែលបានបង្ហាញក្នុង **រូបភាព ១**។ ការណ៍នេះបង្ហាញពីគុណភាពមិនល្អ ក៏ដូចជាធ្វើឱ្យស្ទែមមិនសូវទទួលបានចំណាប់អារម្មណ៍។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ និងព្រួយបារម្ភខ្លាំងជាងនេះទៅទៀតនោះគឺ ទោះបីជាមានការដាក់ចេញនូវគោលនយោបាយស្ទែម និងគំរូអប់រំស្ទែមតាំងពីឆ្នាំ២០១៦ មកក៏ដោយ ភាគរយនៃសិស្សវិទ្យាល័យជ្រើសយកវិទ្យាសាស្ត្រសង្គមនៅតែបន្តកើនឡើង ហើយនៅឆ្នាំសិក្សា២០១៩-២០២០ ចំនួនសិស្ស ដែលជ្រើសយកវិទ្យាសាស្ត្រសង្គមកើនឡើងស្មើរស្មើនឹងចំនួនសិស្សដែលជ្រើសយកវិទ្យាសាស្ត្រពិត ដូចបានឃើញក្នុង **រូបភាព ១**។




**រូបភាព ១៖** ភាគរយសិស្សក្នុងការបែងចែករវាងវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម
**ប្រភព៖** ការតាក់តែងរបស់អ្នកនិពន្ធ

ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ មក មានការកើនឡើងជាបន្តបន្ទាប់នៃចំនួនគ្រឹះស្ថានឧត្តមសិក្សាពោលគឺ ពីចំនួន តិចជាង ១០ រហូតដល់ចំនួន ១១៨ ហើយចំនួនសិស្សកើនឡើងពីតិចជាង ១០ ០០០ នាក់ ឡើងដល់ ២៥០ ០០០នាក់។ ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាទាំងនោះ មានគ្រឹះស្ថានចំនួន ៥២ ដែលកំពុងផ្តល់ការបង្រៀនលើមុខជំនាញទាក់ទងនឹងស្ទែម ប៉ុន្តែមាននិស្សិតតិចជាង ២០% ប៉ុណ្ណោះ ដែលសិក្សាផ្នែកវិស្វកម្ម និងវិទ្យាសាស្ត្រ (Kao & Shimizu, 2020)។

ប្រទេសកម្ពុជា មានការផ្លាស់ប្តូរផ្នែកប្រជាសាស្ត្រយ៉ាងខ្លាំង ដោយសារតែកំណើនប្រជាជនបន្ទាប់ពីរបប ប្រល័យពូជសាសន៍ខ្មែរក្រហម។ នៅក្នុងឆ្នាំ២០១៨ ប្រជាជនដែលមានអាយុក្រោម ៣៥ឆ្នាំ មានប្រមាណ ៦៨,០% នៃចំនួនប្រជាជនសរុប។ ការវិភាគដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ (2018, ទំព័រ11) ចង្អុលបង្ហាញយ៉ាងច្បាស់ថា "ចំនួនប្រជាជនវ័យក្មេង និងប្រកបដោយថាមវន្តទាំងនេះ បន្តដើរតួនាទីយ៉ាងសំខាន់សម្រាប់អនាគត និងអាចមាន ឥទ្ធិពលមកលើសង្គម-សេដ្ឋកិច្ចផ្សេងៗជាច្រើន។ វាអាចជាធនធានដ៏ល្អប្រសើរ ឬអាចជាបន្ទុកសម្រាប់ប្រទេសកម្ពុជា អាស្រ័យ លើថាតើពួកគេអាចក្លាយទៅជាមូលធនមនុស្សដែលល្អ សម្រាប់ការអភិវឌ្ឍប្រទេសដោយរបៀបណា"។ របាយការណ៍ នេះក៏បានគូសបញ្ជាក់ផងដែរថា ចាប់ពីឆ្នាំ២០៣០ យុគសម័យមាសនៃបម្លាស់ប្តូរប្រជាសាស្ត្រនេះ នឹងធ្លាក់ចុះបន្តិចម្តងៗ។ លើសពីនេះ កម្លាំងពលកម្មនឹងជួបប្រទះតុល្យភាពអវិជ្ជមាន ចាប់ពីឆ្នាំ២០៤៥ ដូចគ្នា។ ដូច្នេះហើយ ពេលវេលាសម្រាប់ពង្រីកយុគមាសនៃការផ្លាស់ប្តូរផ្នែកប្រជាសាស្ត្រនេះ គឺអាស្រ័យទាំងស្រុងលើប្រព័ន្ធអប់រំរបស់កម្ពុជា ពោលគឺកំណែទម្រង់ដ៏ត្រឹមត្រូវក្នុងចន្លោះឆ្នាំ២០២២ និងឆ្នាំ២០៣៣ មុននឹងវាយឺតពេល ជាពិសេសនៅក្នុងវិស័យ អប់រំស្វែម ដែលអាចជំរុញមិនត្រឹមតែកំណើនផលិតភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅលើការធ្វើពិពិធកម្មសេដ្ឋកិច្ចតាមរយៈនវានុវត្តន៍ និងការច្នៃប្រឌិតផងដែរ។

ជាមួយនឹងភាពជោគជ័យពាក់ព័ន្ធនឹងការរៀបចំហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងរូបវន្ត នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីលើកដំបូងរបស់រដ្ឋាភិបាលជាប់ឆ្នោតក្នុងឆ្នាំ២០០៨ នាយករដ្ឋមន្ត្រីកម្ពុជាបានកំណត់កង្វះខាតកម្លាំងពលកម្មជំនាញ និងការផ្តល់ការអប់រំដែលមានគុណភាពទាបនៅគ្រប់កម្រិតអប់រំ ថាជាបញ្ហាប្រឈមដ៏សំខាន់ ក្នុងចំណោមបញ្ហាប្រឈមទាំង១៧ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។ ដើម្បីបន្តលើកកម្ពស់ធនធានមនុស្ស នៅក្នុងឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពលើការអភិវឌ្ឍធនធានមនុស្ស ដែលជាសសរស្តម្ភមួយនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ (២០១៨-២០២៣) និងបានដាក់ចេញកម្មវិធីវិនិយោគក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិផងដែរ។ ផែនការយុទ្ធសាស្ត្រ និងអភិវឌ្ឍន៍ថ្នាក់ជាតិទាំងនេះ ជួយតម្រង់ផ្លូវដល់ការរៀបចំផែនការយុទ្ធសាស្ត្រនៅកម្រិតវិស័យនៅទូទាំងក្រសួងរបស់រដ្ឋាភិបាលទាំងអស់។

ដើម្បីឆ្លើយតបទៅនឹងការព្រួយបារម្ភ និងចក្ខុវិស័យផែនការយុទ្ធសាស្ត្រ និងអភិវឌ្ឍន៍ទាំងនេះ ចាប់តាំងពីឆ្នាំ២០០៨ មក ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញផែនការយុទ្ធសាស្ត្រវិស័យអប់រំចំនួន ៣លើក (២០០៩-២០១៣, ២០០១៤-២០១៨, ២០១៩-២០២៣) និងគោលនយោបាយពាក់ព័ន្ធ និងគម្រោងអន្តរាគមន៍ផ្សេងៗទៀតទាក់ទងនឹងការអប់រំស្វែម ដោយផ្តោតលើគោលបំណងគោលនយោបាយធំៗចំនួន ៣ មានដូចជា៖ ១. លទ្ធភាពទទួលបាន និងសមធម៌ (ការពង្រីកផ្នែកផ្គត់ផ្គង់ និងក្រុមជួបការលំបាក) ២. គុណភាព និងភាពឆ្លើយតប (ថ្នាក់តំបន់/អន្តរជាតិ និងវិស័យឯកជន) និង

៣. អភិបាលកិច្ច និងហិរញ្ញវត្ថុ (ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព) នៃប្រព័ន្ធអប់រំ។[4] អន្តរាគមន៍ទាក់ទងនឹងការអប់រំស្ទែមមានគោលបំណងជួយសម្រួលដល់បរិវត្តកម្ម ស្របតាមចក្ខុវិស័យរបស់កម្ពុជាក្នុងការប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់ត្រឹមឆ្នាំ ២០៥០ បន្ទាប់ពីបានចាកចេញពីឋានៈជាប្រទេសដែលមានចំណូលទាប ក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥។

វាពិតជាមានតម្លៃក្នុងការទាញចំណាប់អារម្មណ៍ផងដែរថា ការអប់រំស្ទែម និងសកម្មភាពពាក់ព័ន្ធនានា ត្រូវបានធ្វើឱ្យមានភាពពេញនិយមជាមួយនឹងសកម្មភាពក្រៅកម្មវិធីសិក្សាជាច្រើនដូចជា ពិព័រណ៍ស្ទែម និងរថយន្តចល័តស្ទែម។ ព្រឹត្តិការណ៍ទាំងនេះ ត្រូវបានរៀបចំឡើងដោយអង្គការពិព័រណ៍វិទ្យាសាស្ត្រកម្ពុជា ក្រោមកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា តាំងពីឆ្នាំ២០០៥ ក្នុងគោលបំណងបង្កើនចំណាប់អារម្មណ៍របស់សិស្សនិស្សិតលើមុខជំនាញពាក់ព័ន្ធនឹងស្ទែម និងការតម្រង់ទិសស្ទែមនៅថ្នាក់ឧត្តមសិក្សា។ ក្រោមកិច្ចសហការជាមួយស្ថានទូតអង់គ្លេសប្រចាំនៅកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា នាពេលថ្មីៗនេះ បានបោះពុម្ពផ្សាយសៀវភៅមគ្គុទ្ទេសក៍ «អាជីពការងារនាពេលអនាគត ក្នុងវិស័យវិទ្យាសាស្ត្រ វិស្វកម្ម បច្ចេកវិទ្យា និងនវានុវត្តន៍» ដែលមានដាក់រាយបញ្ជីអាជីពដែលមានសក្តានុពលក្នុងវិស័យស្ទែម ក៏ដូចជាគ្រឹះស្ថានឧត្តមសិក្សាដែលផ្តល់ជូនមុខជំនាញទាក់ទងនឹងស្ទែមនៅកម្ពុជា។ ទាំងអស់នេះ ផ្តល់លទ្ធភាពដល់សិស្សនៅកម្រិតវិទ្យាល័យនូវការតម្រង់ទិសមួយដែលកាន់តែប្រសើរ និងជួយពួកគេអាចធ្វើការជ្រើសរើសប្រកបដោយព័ត៌មានពេញលេញ ក្នុងការចូលរៀនក្នុងវិស័យស្ទែម។ នៅលើឆាកអន្តរជាតិ ចាប់តាំងពីឆ្នាំ២០០៥ ក្រសួងអប់រំ យុវជន និងកីឡា ក៏គាំទ្រការរៀបចំការបង្រៀន និងរៀនជាយុទ្ធសាស្ត្រសម្រាប់ការប្រកួតអន្តរជាតិដូចជា រូបវិទ្យាអូឡាំព្យាដទ្វីបអាស៊ី (APhO) រូបវិទ្យាអូឡាំព្យាដអន្តរជាតិ (IPhO) អូឡាំព្យាដអន្តរជាតិអំពីតារាវិទ្យា និងរូបវិទ្យាតារា (IOAA) ការស្វែងរកអ្នកវិទ្យាសាស្ត្រវ័យក្មេងSEAMEO (SSYS), គណិតវិទ្យាអូឡាំព្យាដអន្តរជាតិ (IMO) និង គណិតវិទ្យាអូឡាំព្យាដអាស៊ី-ប៉ាស៊ីហ្វិក (APMO) ។

រហូតដល់ឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយអប់រំស្ទែម ដែលជានវានុវត្តន៍មួយដើម្បីផ្សារភ្ជាប់ខ្លឹមសារស្ទែមទៅនឹងជីវភាពរស់នៅរបស់ពលរដ្ឋដោយផ្តោតលើការអភិវឌ្ឍជំនាញសតវត្សរ៍ទី២១។ ការរៀបចំគោលនយោបាយអប់រំស្ទែម គឺជាការចាំបាច់ និងមានភាពបន្ទាន់សម្រាប់យុទ្ធសាស្ត្រ និងផែនទីបង្ហាញផ្លូវសម្រាប់សកម្មភាពទាំងអស់ដែលទាក់ទងនឹងការអប់រំស្ទែម។ ក្នុងឆ្នាំដដែល ការធ្វើប្រតិបត្តិការគោលនយោបាយថ្មី បានចាប់ផ្តើម។ ក្រសួងអប់រំ យុវជន និងកីឡា បានសាកល្បងគំរូសាលារៀនថ្មីមួយហៅថា "សាលាក្នុងសាលា" ដែលក្នុងនោះរចនាសម្ព័ន្ធថ្មីត្រូវបានបង្កើតឡើងនៅក្នុងសាលាដែលមានស្រាប់ ដែលជាការពិសោធន៍ផ្នែកអប់រំបែបនវានុវត្តន៍ ដើម្បី

[4] ក្រសួងផ្សេងៗទៀតក៏បានដាក់ចេញគោលនយោបាយពាក់ព័ន្ធនឹងវិស័យស្ទែមផងដែរដូចជា គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០២០-២០៣០, ផែនទីបង្ហាញផ្លូវកម្ពុជាឆ្នាំ២០៣០, ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣, និងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២០១៧-២០២៥ ។

ដោះស្រាយបញ្ហាប្រឈមជាប្រព័ន្ធនៅក្រោមការសម្របសម្រួលបច្ចេកទេស របស់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយហៅកាត់ថា ខេប (KAPE) ។ ដំបូងឡើយ គំរូនេះបានចាប់ផ្តើមជាមួយនឹងកម្រិតមធ្យមសិក្សា តាមរយៈការបង្កើតប្រព័ន្ធស្វយ័តដែលមានឈ្មោះថា សាលារៀនជំនាន់ថ្មី (NGS) ដែលទទួលបានមូលនិធិច្រើនសម្រាប់ការចំណាយទៅលើការបង្រៀន និងរៀន ក៏ដូចជាកម្មវិធីគ្រប់គ្រង និងការអភិវឌ្ឍវិជ្ជាជីវៈដែលផ្សារភ្ជាប់[5] ទៅនឹងស្តង់ដារថ្មីនៃគណនេយ្យភាព និងអភិបាលកិច្ចក៏ដូចជាស្តង់ដារវិជ្ជាជីវៈ។ តាមរយៈការវិនិយោគ និងកំណែទម្រង់នេះ គោលនយោបាយក្រសួងអប់រំ យុវជន និងកីឡា លើកឡើងថា ប្រព័ន្ធអប់រំនេះនឹង "...ប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាពជាមួយនឹងប្រព័ន្ធអប់រំផ្សេងទៀតនៅក្នុងតំបន់អាស៊ាន ដែលមានតម្រូវការបន្ទាន់ផ្នែកកម្លាំងពលកម្មដែលប្រកបទៅដោយជំនាញសតវត្សរ៍ទី២១"។ នេះអាចយល់បានថា ជាតម្រូវការក្នុងការបង្កើនកម្រិតជំនាញនៅក្នុងមុខវិជ្ជាស្ទែម។

ដូច្នេះ កាន់តែច្បាស់ជាងកម្រិតមធ្យមសិក្សាធម្មតា/ប្រពៃណី សាលារៀនជំនាន់ថ្មីពង្រឹងការកសាងសមត្ថភាពក្នុងបច្ចេកវិទ្យាសម្រាប់ការអប់រំ វិធីសាស្ត្រសិក្សាផ្អែកលើបញ្ហា និងការសង្កត់ធ្ងន់លើមុខវិជ្ជាដែលទាក់ទងនឹងស្ទែម។ ជាក់ស្តែង ម៉ោងបង្រៀនសម្រាប់មុខវិជ្ជាគណិតវិទ្យា មុខវិជ្ជាវិទ្យាសាស្ត្រ (រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា) និងការអប់រំបច្ចេកទេសត្រូវបានដំឡើងពី ១៦ម៉ោង ទៅ ២០ម៉ោងក្នុងមួយសប្តាហ៍ (MoEYS, 2016)។ ការផ្លាស់ប្តូរនេះ មានគោលបំណងសំខាន់បំផុតក្នុងការផ្តល់នូវជំនាញដែលត្រូវការចាំបាច់សម្រាប់ទីផ្សារការងារ នៅពេលដែលសិស្សសម្រេចចិត្តចូលធ្វើការភ្លាមៗបន្ទាប់ពីបញ្ចប់ការសិក្សា និងសំដៅបង្កើនការចុះឈ្មោះចូលរៀននៅក្នុងវិស័យទាក់ទងនឹងស្ទែម នៅកម្រិតឧត្តមសិក្សា។ ប៉ុន្មានឆ្នាំមកនេះ សាលារៀនជំនាន់ថ្មី មិនត្រឹមតែត្រូវបានពង្រីកទៅតាមបណ្តាខេត្តផ្សេងទៀតនោះទេ តែត្រូវបានពង្រីកនៅតាមកម្រិតអប់រំផងដែរ។ មកទល់នឹងពេលថ្មីៗនេះ សាលារៀនជំនាន់ថ្មីចំនួន ១០ រួមមាន សាលាបឋមសិក្សាចំនួន ០៤ អនុវិទ្យាល័យចំនួន ០១ និងវិទ្យាល័យចំនួន ០៤ ត្រូវបានបង្កើតនៅតាមខេត្តចំនួន ៤ ដូចជា កំពង់ស្ពឺ កំពង់ចាម ស្វាយរៀង និងកណ្តាល ព្រមទាំងរាជធានីភ្នំពេញ (Thmey Thmey News, 2019)។

មួយឆ្នាំបន្ទាប់ពីការដាក់ចេញគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី ពោលគឺឆ្នាំ២០១៧ សាលាផ្អែកលើស្ទែមមួយដែលត្រូវបានស្គាល់ថា អ៊ីធូស្ទែម (E2STEM) បានលេចរូបរាងឡើង ហើយបច្ចុប្បន្នមានទីតាំងក្នុងវិទ្យាល័យព្រះយុគន្ធរ។ គំរូនេះបង្ហាញពីការផ្តោតសំខាន់ទៅលើ ការបណ្តុះបណ្តាលចំនួន ០៥ មានភាសាអង់គ្លេស ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងគណិតវិទ្យា។ អ្នកជំនាញផ្នែកអប់រំខ្លះយល់ឃើញថា ការអប់រំនៅសតវត្សរ៍ទី២១ មិនត្រូវផ្តោតសំខាន់តែទៅលើមុខវិជ្ជាស្ទែមសុទ្ធសាធនោះទេ ប៉ុន្តែក៏ត្រូវយកចិត្តទុកដាក់លើមុខវិជ្ជាដែលទាក់ទងនឹងសិល្បៈសេរី វិទ្យាសាស្ត្រសង្គម មនុស្សសាស្ត្រ ប្រវត្តិសាស្ត្រ និងការអប់រំផងដែរ ដើម្បីគិតគូរដល់បរិយាប័ន្នភាព និងនវានុវត្តន៍

[5] តម្លៃឯកតាសម្រាប់សិស្សម្នាក់ក្នុងមួយឆ្នាំ គឺប្រហែល ២៥០ ដុល្លារអាមេរិក (Chea និង Chen ២០២១) បើធៀបនឹងប្រហែល ១២០ ដុល្លារអាមេរិក សម្រាប់សិស្សម្នាក់នៅក្នុងសាលាធម្មតា នេះបើយោងតាមការសន្ទនាផ្ទាល់ខ្លួន ជាមួយបុគ្គលដែលធ្វើការយ៉ាងជិតស្និទ្ធនៅក្នុងវិស័យនេះ។

( Reiter, 2017; Radcliffe, 2015 )។ ដោយមើលឃើញពីមូលហេតុទាំងនោះ ការអប់រំស្ទែមទំនើប ដែលមានគុណភាពខ្ពស់ និងប្រសិទ្ធភាពចំណាយកាន់តែប្រសើរ គួរតែទទួលបានការយកចិត្តទុកដាក់ និងការគាំទ្រពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ព្រោះវាជាកម្លាំងចលករដែលអាចផ្លាស់ប្តូរប្រទេសកម្ពុជា ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្មទៅជា ប្រទេសដែលមានសេដ្ឋកិច្ចពឹងផ្អែកលើចំណេះដឹង។ ស្តង់ដារគុណភាពនេះ ត្រូវតែឈានដល់កម្រិតមួយដែលអាចប្រៀបធៀបជាមួយនឹងសាលាល្បីៗនៅប្រទេសជិតខាង។ យ៉ាងណាក្តី និរន្តរភាពរបស់វានៅតែជាសំណួរនៅឡើយ ដោយសារពេលថ្មីៗនេះ មានរបាយការណ៍មួយបង្ហាញថា ការកៀរគរធនធានមិនអាចបំពេញតាមថវិកាប្រតិបត្តិការដែលបានគ្រោងទុក ដោយសារតែមានការចំណាយខ្ពស់សម្រាប់ប្រតិបត្តិការ។ ការសន្ទនាក្រៅផ្លូវការមួយបង្ហាញថា សាលានេះកំពុងស្នើសុំឱ្យរដ្ឋាភិបាលបង្វែរថវិកាមួយចំនួន ពីមូលនិធិសាលារៀនជំនាន់ថ្មី ដើម្បីទ្រទ្រង់ដល់ប្រតិបត្តិការរបស់ខ្លួន។ [6]

សាលារៀនផ្សេងទៀត ដែលផ្តោតលើការអប់រំស្ទែម ក៏ត្រូវបានបង្កើតឡើងផងដែរជាមួយនឹងការវិនិយោគដែលមានតម្លៃថ្លៃ ប៉ុន្តែផ្តល់លទ្ធផលផ្សេងៗគ្នា។ ប៉ុន្តែ វាអាចនឹងលឿនពេកក្នុងការវាយតម្លៃកំណែទម្រង់ថ្មីនៅក្នុងវិស័យនេះ។ ឧទាហរណ៍ ការសិក្សាដោយ Chea និង Chen ( 2021 ) បង្ហាញពីការសង្កេតគួរឱ្យចាប់អារម្មណ៍ចំនួន ៣ ដែលទាក់ទងនឹងការដាក់ចេញនូវសាលារៀនជំនាន់ថ្មី។ ទីមួយ ពួកគេចោទសួរអំពីនិរន្តរភាព និងវិសាលភាពនៃគំរូថ្មីនេះ ដោយសារតែតម្រូវការការវិនិយោគខ្ពស់ សម្រាប់ដំណើរការសាលារៀនទាំងនេះ និងថវិការដ្ឋាភិបាលដែលនៅមានកម្រិត។ ទីពីរ គឺទីតាំងរបស់សាលារៀនជំនាន់ថ្មី ស្ថិតនៅតំបន់ទីប្រជុំជន ដែលការចូលរួមពីសហគមន៍អាចជួយកៀរគរធនធានបាន ប៉ុន្តែពួកគេមានការព្រួយបារម្ភចំពោះ ការចូលរួមវិភាគទានដោយស្ម័គ្រចិត្តរបស់គ្រួសារក្រីក្រ។ និងចុងក្រោយ ប្រសិទ្ធភាពពិតប្រាកដនៃសាលារៀនជំនាន់ថ្មី មិនទាន់ត្រូវបានគេវាយតម្លៃតាមកស្តុតាងជាក់ស្តែងនៅឡើយទេ ទោះបីជាស្ថិតិបានបង្ហាញពីសញ្ញានៃភាពជោគជ័យមួយចំនួនក៏ដោយ។ ទោះយ៉ាងនេះក្តី វិធីសាស្រ្តវាយតម្លៃមានលក្ខណៈសើៗនៅឡើយ ដោយពឹងផ្អែកទាំងស្រុងលើតែការប្រឡងថ្នាក់ជាតិ។ លើសពីនេះ វាប្រហែលជាមានភាពលំអៀង ពីព្រោះថាសិស្សដែលត្រូវបានជ្រើសរើសចូលសាលារៀនជំនាន់ថ្មី តាមរយៈគំរូដែលប្រកួតប្រជែងខ្លាំង។ ជាងនេះទៅទៀត ការផ្សារភ្ជាប់របស់វាទៅនឹងឧស្សាហកម្ម ក៏ត្រូវបានចោទជាសំណួរផងដែរ ដោយសារតែមិនសូវមានកំណែទម្រង់ និងកំណែខ្លឹមសារច្រើនទាក់ទងនឹងកម្មវិធីសិក្សា និងសកម្មភាពក្រៅកម្មវិធីសិក្សានោះទេ។ មកទល់ពេលនេះ កម្ពុជាមិនទាន់មានចក្ខុវិស័យ ច្បាស់លាស់ និងជាយុទ្ធសាស្រ្តក្នុងការបំពាក់បំប៉ន និងធ្វើឱ្យលូតលាស់នូវទេពកោសល្យក្នុងវិស័យស្ទែមនោះទេ។ ក្នុងន័យនេះ របាយការណ៍នេះ មានបំណងបង្កើតគំរូវិទ្យាល័យស្ទែមមួយសម្រាប់ខេត្តកំពង់ស្ពឺ ដែលអាចនាំទៅដល់ការពង្រីកវិសាលភាពកាន់តែទូលំទូលាយនៅក្នុងប្រទេសកម្ពុជា។

[6] ការប៉ុនប៉ងក្នុងការប្រមូលព័ត៌មានលម្អិតជាក់លាក់ សម្រាប់ការសិក្សានេះ គឺមិនទទួលបានជោគជ័យ ដោយកម្រងសំណួរមិនត្រូវបានស្វាគមន៍ដោយ គណៈគ្រប់គ្រងរបស់សាលាអ៊ីធូស្ទែម ( E2STEM )។

## ១.៣. ហេតុអ្វីវិទ្យាល័យស្ទែមនៅក្នុងខេត្តកំពង់ស្ពឺ?

### ១.៣.១. សនិទាន

កំពង់ស្ពឺ ជាខេត្តមួយដែលស្ថិតនៅប្រមាណជា ៥០ គីឡូម៉ែត្រពីរាជធានីភ្នំពេញ ដែលមានប្រជាជនប្រមាណ ៨៧៧ ៥២៣ នាក់ (៤៥២ ៤២១ ជាស្ត្រី) គិតត្រឹមឆ្នាំ២០១៩។ ខេត្តនេះ មានព្រំប្រទល់ជាប់នឹងខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់នៅភាគខាងជើង ជាប់នឹងខេត្តកំពត និងខេត្តតាកែវនៅភាគខាងត្បូង ជាប់នឹងរាជធានីភ្នំពេញនៅភាគខាងកើត និងខាងលិចជាប់នឹងខេត្តកោះកុង និងស្ថិតនៅតាមបណ្តោយផ្លូវល្បឿនលឿនទៅកាន់កំពង់ផែទឹកជ្រៅ និងធំជាងគេបំផុតរបស់កម្ពុជានៅខេត្តព្រះសីហនុ។ ទីតាំងយុទ្ធសាស្ត្រនេះ បានប្រែក្លាយខេត្តកំពង់ស្ពឺ ពីខេត្តមួយក្នុងចំណោមខេត្តដែលក្រីក្រជាងគេនៅកម្ពុជា ឱ្យទៅជាមជ្ឈមណ្ឌលនៃតំបន់ឧស្សាហកម្មមួយនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ នៅត្រឹមឆ្នាំ ២០២១ ខេត្តកំពង់ស្ពឺមានរោងចក្រឧស្សាហកម្មខ្នាតធំចំនួន ២២៦ និងសហគ្រាសធុនតូច និងមធ្យមចំនួន ១ ៦៤០។ ស្រដៀងគ្នាទៅនឹងកម្រិតថ្នាក់ជាតិដែរ រោងចក្រឧស្សាហកម្មខ្នាតធំនៅក្នុងខេត្តនេះត្រូវបានគ្របដណ្តប់ដោយរោងចក្រកាត់ដេរ ដែលមានចំនួនប្រហែល ៧០% នៃប្រភេទឧស្សាហកម្មសរុប ចំណែក ៣០% ទៀតអាចផ្គត់ផ្គង់កម្លាំងពលកម្មដែលផ្អែកលើស្ទែម (រូបភាពទី ២)។



**រូបភាពទី ២៖** ប្រភេទឧស្សាហកម្មនៅខេត្តកំពង់ស្ពឺ

***ប្រភព៖*** ការចងក្រង និងវិភាគរបស់អ្នកនិពន្ធ

ដោយគិតពីបរិបទបច្ចុប្បន្ននៃវត្តមានរបស់ការអប់រំស្ទែម ក្នុងនាមជាគំរូដែលកំពុងលេចធ្លោជាចំណាប់អារម្មណ៍មួយក្នុងចំណោមអ្នកពាក់ព័ន្ធ ដែលក្នុងនោះ ៣០% នៃចំនួនឧស្សាហកម្មប្រហែល ២០០ កំពុងត្រូវការនិស្សិតបញ្ចប់ការសិក្សាផ្នែកស្ទែម។ ជាពិសេស វាត្រូវបានគេមើលឃើញថា មុខជំនាញវិស្វកម្ម និងវិទ្យាសាស្ត្រ រួមមានសំណង់ បច្ចេកវិទ្យាវេចខ្ចប់ វិទ្យាសាស្ត្ររូបធាតុ ការកែច្នៃចំណីអាហារ អគ្គិសនី អេឡិចត្រូនិក និងវិស្វកម្មមេកានិច កំពុងមានសារៈសំខាន់នាពេលបច្ចុប្បន្ន ហើយនឹង

កាន់តែមានតម្រូវការខ្លាំងបន្ថែមទៀត ប្រសិនបើការពង្រីកឧស្សាហកម្មត្រូវបានធ្វើឡើងស្របតាមនិន្នាការដែលបានព្យាករណ៍រហូតដល់ឆ្នាំ២០៣០។

ពាក់ព័ន្ធទៅនឹងសហគ្រាសធុនតូច និងមធ្យម រូបភាពទី ៣ បង្ហាញពី ការព្យាករប្រកបដោយក្ដីសង្ឃឹមថាការអប់រំផ្នែកលើស្ទែម កំពុងតែមានតម្រូវការ។ ឧទាហរណ៍ រោងចក្រផលិតសម្ភារសំណង់ និងកែច្នៃម្ហូបអាហារមានភាគរយខ្ពស់ ខណៈរោងចក្រកាត់ដេរឈរនៅលំដាប់ថ្នាក់ទី៣។ ការមើលឃើញទូទៅពីសហគ្រាសធុនតូច និងមធ្យមជាង ៦០ នៅក្នុងខេត្តនេះ បង្ហាញពីតម្រូវការធនធានមនុស្សប្រកបដោយជំនាញ ចេញពីស្ថាប័នដែលតម្រង់ទិសផ្នែកស្ទែម។ រូបភាពទី ៣ បង្ហាញថា ៧៦% នៃសហគ្រាសធុនតូច និងមធ្យម ស្ថិតនៅក្នុងវិស័យសម្ភារសំណង់ ការកែច្នៃអាហារ សារធាតុគីមី ប្លាស្ទិក ក្រដាស និងសម្ភារផ្សេងៗទៀត។ ធម្មជាតិនៃសហគ្រាសធុនតូច និងមធ្យមទាំងនេះ ត្រូវការនិស្សិតបញ្ចប់ការសិក្សាផ្នែកវិស្វកម្ម និងមុខជំនាញផ្សេងទៀតដែលមានមូលដ្ឋានទាក់ទងនឹងវិទ្យាសាស្ត្រ។



**រូបភាពទី ៣៖** ប្រភេទសហគ្រាសធុនតូច និងមធ្យមក្នុងខេត្តកំពង់ស្ពឺ

<u>ប្រភព៖</u> ការចងក្រង និងវិភាគរបស់អ្នកនិពន្ធ

ក្នុងឆ្នាំ២០១៦ មានរបាយការណ៍វាយតម្លៃគួរឱ្យចាប់អារម្មណ៍មួយ ដែលចេញផ្សាយដោយមជ្ឈមណ្ឌលជ័យវរ្ម័នសម្រាប់ការអភិវឌ្ឍ (2016) ដែលមានចំណងជើងថា “ឧស្សាហូបនីយកម្មកម្ពុជា៖ ការធ្វើផែនទីបង្ហាញផ្លូវដើម្បីកសាងកម្រងឧស្សាហកម្មស្នូលនៅខេត្តកំពង់ស្ពឺ។ របាយការណ៍នេះ ស្នើនូវកម្រងឧស្សាហកម្ម សម្រាប់ខេត្តកំពង់ស្ពឺដូចជា៖ កសិ-ឧស្សាហកម្ម ឧស្សាហកម្មសីមីកុងឌុចទ័រ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធ ជាមួយនឹងគំរូវិនិយោគសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គម និងរូបវន្ត។ ជាមួយនឹងការរកឃើញទាំងអស់នេះ ការអប់រំស្ទែមនឹងធ្វើឱ្យផលិតភាពនៃឧស្សាហកម្មដែលមានស្រាប់កាន់តែប្រសើរឡើង ក៏ដូចជាធ្វើឱ្យការសាងសង់កម្រងឧស្សាហកម្មស្នូលនៅក្នុងខេត្តកំពង់ស្ពឺ ក្លាយជាការពិត។ នេះមិនមែនជា ការយល់ឃើញដែលមិនអាចទៅរួចនោះទេ។ ឧទាហរណ៍ គិតតែក្នុងឆ្នាំ២០១៩ ក្រុមហ៊ុនចិនធំៗចំនួន ៣៥ ចាប់អារម្មណ៍

មកបណ្ដាក់ទុននៅខេត្តកំពង់ស្ពឺ ហើយក្រុមហ៊ុនអន្តរជាតិចំនួន ០៣ គ្រោងចំណាយថវិកាសរុបប្រមាណ ៥០០ លានដុល្លារអាមេរិក សម្រាប់សួនអន្តរជាតិក្នុងខេត្តកំពង់ស្ពឺ[7] ដែលធ្វើអោយខេត្តនេះក្លាយជាខេត្តដែលសមស្របបំផុតសម្រាប់អនុវត្តគំរូស្ទែមថ្មី។

## ១.៣.២. មូលធនមនុស្សក្នុងខេត្តកំពង់ស្ពឺ

ទោះបីជា ចំនួនប្រជាជនដែលមានអាយុលើសពី ១៥ ឆ្នាំ មានកម្រិតខ្ពស់ក៏ដោយ មានប្រមាណ ៨៩,៣% (ជំរឿនជាតិឆ្នាំ២០១៩) ប៉ុន្តែអត្រាអក្ខរកម្មដែលសម្រេចបានលើសកម្រិតអនុវិទ្យាល័យ គឺមានចំនួនតិចតួចនៅឡើយ។ ឧទាហរណ៍ ៣៥,៩% ចូលរៀនថ្នាក់បឋមសិក្សា, ៣៧,៣% បានបញ្ចប់បឋមសិក្សា, និង ២៣,៤% បានបញ្ចប់កម្រិតអនុវិទ្យាល័យ។ ក្នុងចំណោមនោះ មានតែ ២% ប៉ុណ្ណោះបានចូលរៀនកម្រិតមធ្យមសិក្សា និង ១,៤% ទៀតបានចូលរៀនកម្រិតក្រោយមធ្យមសិក្សា។ តួលេខនេះបានឆ្លុះបញ្ចាំងពីអត្រាចុះឈ្មោះចូលរៀនសរុបដ៏ទាបនៅវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ ដែលមានប្រហែល ២៥,៥%។[8] ចំពោះគុណភាពអប់រំ ដែលវាស់វែងផ្អែកលើអត្រាប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ ក្នុងចំណោមសិស្សសរុប ៣ ១៩៧ នាក់ មានតែសិស្សមួយចំនួនតូចប៉ុណ្ណោះ ពោលគឺ ០៦នាក់, ៥៣នាក់, និង ១៨៨នាក់ ទទួលបាននិទ្ទេស A, B, និង C។ ក្រៅពីនេះ សិស្សផ្សេងទៀតទទួលបាននិទ្ទេស D និង E។

ត្រឹមឆ្នាំ២០២០ ខេត្តកំពង់ស្ពឺមានវិទ្យាល័យចំនួន ២៤ ជាមួយនឹងសាលាធនធានចំនួន ០២។ ខេត្តនេះ ក៏មានវិទ្យាល័យឯកជនចំនួន ០៥ ផងដែរ ដែលនេះបង្ហាញពីការទាមទារឱ្យមានការអប់រំប្រកបដោយគុណភាពនៅកម្រិតវិទ្យាល័យនៅក្នុងខេត្តនេះ ខណៈមាតាបិតាសិស្សជឿថា សាលាឯកជនអាចផ្ដល់គុណភាពអប់រំប្រសើរជាងគ្រឹះស្ថានរដ្ឋ។ ចំនួនសិស្សចុះឈ្មោះចូលរៀនសរុបនៅកម្រិតវិទ្យាល័យពីថ្នាក់ទី១០ ដល់ ទី១២ មាន ១៥ ៦១៥ នាក់ ក្នុងនោះ ៨ ៣៤១នាក់ ជាសិស្សស្រី។ គេមិនឃើញមានវត្តមានសាលាបច្ចេកទេសនៅក្នុងខេត្តនេះ លើកលែងដេប៉ាតឺម៉ង់មួយនៃសាកលវិទ្យាល័យឯកជនមួយក្នុងខេត្តនេះ។

យោងតាមរបាយការណ៍សន្និបាតឆ្នាំ២០២០ ធ្វើឡើងដោយមន្ទីរអប់រំ យុវជន និងកីឡា មានកម្មវិធីបង្រៀនមួយដែលផ្ដោតលើស្ទែម ប៉ុន្តែវាប្រមូលផ្តុំនៅតាមសាលាមួយចំនួននៅទីប្រជុំជន។ កម្មវិធីនោះសំដៅលើវត្តមាននៃបន្ទប់ពិសោធន៍សម្រាប់បង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រចំនួន ០៤ គឺគីមីវិទ្យា ជីវវិទ្យា រូបវិទ្យា និងផែនដីវិទ្យា។ វាក៏មានផងដែរ នូវកម្មវិធីបំណិនជីវិតដែលផ្ដោតលើកុំព្យូទ័រ និងសហគ្រិនភាព។

[7] Sen David, “ក្រសួងអប់រំ គ្រោងនឹងបើកសាលារៀនជំនាន់ថ្មីបន្ថែមទៀត”, ទាញយកពី https://www.khmertimeskh.com/670675/education-ministry-to-create-more-new-generation-schools/, ចូលមើល ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១

[8] ការសង្ខេបត្រូវបានបកប្រែចេញពី សន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៨-២០១៩ និងលើកទិសដៅឆ្នាំសិក្សា ២០១៩-២០២០ របស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ។

បញ្ហាប្រឈមដែលបានរៀបរាប់នៅក្នុងរបាយការណ៍សន្និបាតរួមមាន អត្រាទាបនៃការឡើងថ្នាក់អនុវិទ្យាល័យទៅវិទ្យាល័យ ដែលមានប្រហែល ៦៨% និងអត្រាខ្ពស់នៃការបោះបង់ការសិក្សានៅកម្រិតវិទ្យាល័យ។ ទោះបីជា អត្រាបោះបង់ការសិក្សាខ្ពស់ ទំនងជាបណ្តាលមកពីភាពក្រីក្រក៏ដោយ ការសិក្សាមួយចំនួនបង្ហាញថា គុណភាពទាប និងភាពមិនឆ្លើយតបនៃខ្លឹមសារអប់រំទៅនឹងតម្រូវការទីផ្សារការងារបច្ចុប្បន្ននោះទេ ដែលបណ្តាលឱ្យមានការបោះបង់ការសិក្សាយ៉ាងច្រើន ជាពិសេសសម្រាប់តំបន់ជនបទ និងដាច់ស្រយាល។ ពាក់ព័ន្ធទៅនឹងការរកឃើញនេះ Bredenberg (2013) រកឃើញថា សិស្សអនុវិទ្យាល័យបានសម្តែងភាពមិនទុកចិត្ត អំពីគុណតម្លៃនៃការអប់រំដែលពួកគេបានទទួលទាក់ទងនឹងភាពពាក់ព័ន្ធនៃការអប់រំទៅនឹងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ទស្សនៈស្រដៀងគ្នានេះ ក៏ត្រូវបានបង្ហាញដោយមាតាបិតាសិស្ស “ដែលមិនទទួលស្គាល់ថា វាពិតជាមានសារប្រយោជន៍ពិតប្រាកដសម្រាប់កូនៗរបស់ពួកគេ ឬសម្រាប់ពួកគេផ្ទាល់ ក្នុងការវិនិយោគពេលវេលា និងថវិកាដ៏មានតម្លៃលើអប់រំ។ ពួកគេឃើញពីភស្តុតាងតិចតួច ដែលថា ការអប់រំនឹងផ្តល់ឱកាសការងារជាច្រើន ផ្ទុយទៅនឹងឱកាសការងារតិចតួចប្រសិនបើកូនរបស់គេមិនទទួលបានការអប់រំ” (Nock and Bishop (Eds.), 2018, pp. 58-59)។

បញ្ហាមួយទៀតដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍សន្និបាតឆ្នាំ២០២០ គឺទាក់ទងទៅនឹងសមត្ថភាពរបស់គ្រូបង្រៀនដោយមានតែប្រហែល ៧២% ប៉ុណ្ណោះដែលមានគុណវុឌ្ឍិស្របតាមស្តង់ដារគុណវុឌ្ឍិជាតិ (១២+២) (នេះដោយ មិននិយាយដល់កម្រិត បរិញ្ញាបត្រ+១ ដូចមានចែងក្នុងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា) ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីអនុវត្តកម្មវិធីសិក្សាកំណែទម្រង់ថ្មី ជាពិសេសសម្រាប់ការអប់រំស្តែម ដែលវិទ្យាល័យត្រឹមតែ ២% ប៉ុណ្ណោះមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ដើម្បីគាំទ្រដល់ការបង្រៀន និងរៀន។ ក្រៅពីនេះក៏មានរបាយការណ៍ផ្សេងៗទៀតស្តីពី កង្វះខាតគ្រូក្នុងមុខវិជ្ជាមួយចំនួន ព្រមទាំងអ្នកប្រឹក្សាយោបល់ និងគ្រូឧទ្ទេសនៅក្នុងកម្មវិធីបំណិនជីវិតផងដែរ។ ការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយចំពោះវិស័យអប់រំក្នុងខេត្តកំពង់ស្ពឺក៏នៅមានកម្រិតដូចគ្នា ដោយគម្រោងកែលម្អការអប់រំមធ្យមសិក្សាដែលមានស្រាប់គាំទ្រតែសាលារៀនចំនួន ០៥ ប៉ុណ្ណោះនៅក្នុងខេត្តនេះ។

បច្ចុប្បន្ននេះមានបឋមសិក្សាស្តែមតែមួយប៉ុណ្ណោះគឺ «សាលាបឋមសិក្សាព្រះរាជអគ្គមហេសី» នៅក្នុងស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ។ ទោះបីជាក្រសួងអប់រំ យុវជន និងកីឡា គ្រោងនឹងបង្កើនចំនួនសាលារៀនជំនាន់ថ្មីរហូតដល់ ១៥០ ទូទាំងប្រទេសក៏ដោយ ក៏គេមិនច្បាស់ថាក្នុងចំណោមសាលាដែលគ្រោងទុកទាំង ១៥០ នោះ តើនឹងមានសាលារៀនជំនាន់ថ្មីបន្ថែមនៅខេត្តកំពង់ស្ពឺឬទេ។ គុណវិបត្តិ ដែលគេអាចរៀនសូត្របានពីការអនុវត្តសាលារៀនជំនាន់ថ្មីកន្លងមក គឺស្ថានភាពលំបាកសម្រាប់គ្រូបង្រៀនដែលត្រូវជ្រើសរើសវិធីសាស្ត្រ បណ្តុះបណ្តាលសិស្ស “រៀនដើម្បីគិត” ឬ “រៀនដើម្បីប្រឡង”(Reimers, 2020)។ សំខាន់ជាងនេះទៅទៀត ទោះជានៅក្នុងគំរូការអប់រំស្តែមបច្ចុប្បន្នក៏ដោយ ក៏គុណភាពអប់រំទាក់ទងនឹងស្តែម និងការផ្សារភ្ជាប់របស់វាទៅនឹងឧស្សាហកម្មក្នុងស្រុកនៅកម្ពុជា នៅតែមានកម្រិតនៅ

ឡើយ ធៀបជាមួយនឹងសាលាគំរូផ្សេងៗនៅក្នុងតំបន់ (Bo, 2020)។ ដោយសារហេតុនេះហើយ បានជាការសិក្សានេះត្រូវបានធ្វើឡើងផ្តោតលើខេត្តកំពង់ស្ពឺ។

## ១.៤. គោលបំណង និងវត្ថុបំណង

ទស្សនាទានគំរូស្ទែមរបស់យើងនៅកម្រិតវិទ្យាល័យសម្រាប់ខេត្តកំពង់ស្ពឺនេះ គឺផ្អែកជាចម្បងលើលទ្ធផលនៃករណីសិក្សានៅក្នុងខេត្តនេះផ្ទាល់ ចំណេះដឹងយ៉ាងស៊ីជម្រៅនៃគំរូអប់រំវិទ្យាល័យស្ទែមដែលមានស្រាប់ និងការធ្វើសមាហរណកម្មសកម្មភាពក្រៅកម្មវិធីសិក្សាដែលសមស្រប សម្រាប់បរិបទកម្ពុជា សំដៅធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សាផ្អែកលើស្ទែម។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណងចម្បងដើម្បី៖

- ត្រៀមជាស្រេចនូវសិស្សបញ្ចប់ការសិក្សា សម្រាប់ជាកម្លាំងពលកម្ម ជាពិសេស សម្រាប់តំបន់ឧស្សាហកម្ម និង
- ត្រៀមជាស្រេចនូវសិស្សបញ្ចប់ការសិក្សា ដោយបំពាក់បំប៉នពួកគេជាមួយមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងផ្នែកស្ទែម សម្រាប់ការអប់រំក្រោយមធ្យមសិក្សា ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចនាពេលអនាគត។

វត្ថុបំណងនៃការសិក្សានេះមានចំនួន ៣ ដូចជា៖

- ផ្តល់នូវគំរូវិទ្យាល័យស្ទែមមួយដែលសមស្របសម្រាប់ខេត្តកំពង់ស្ពឺ
- ស្នើវិទ្យាល័យមួយនៅខេត្តកំពង់ស្ពឺដើម្បីប្រែក្លាយទៅជា វិទ្យាល័យស្ទែម
- ផ្តល់អនុសាសន៍សម្រាប់ដំណើរបរិវត្តកម្មទាក់ទងនឹងការរៀបចំ និងការអនុវត្ត សំដៅធ្វើឱ្យសាលានេះក្លាយជាសាលានាំមុខគេនៅក្នុងប្រទេសលើវិស័យអប់រំស្ទែម។

## ១.៥. ទំហំនៃការសិក្សា

ក្រុមអ្នកស្រាវជ្រាវបានធ្វើការពិនិត្យឡើងវិញលើឯកសារគន្លឹះៗដែលមានស្រាប់ អំពីការអប់រំនៅកម្រិតវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ ក៏ដូចជាឯកសារអំពីសាលារៀនជំនាន់ថ្មីដែលមានស្រាប់ និងដែលអាចរកបាននានា ព្រមទាំងគោលនយោបាយសាលារៀនជំនាន់ថ្មីពីក្រសួងអប់រំ យុវជន និងកីឡា។ បន្ថែមពីនេះទៅទៀត សូចនាករវាយតម្លៃនៅកម្រិតវិទ្យាល័យ និងឯកសារចាំបាច់ផ្សេងៗទៀត ក៏ត្រូវបានយកមកពិនិត្យផងដែរ។ សំខាន់ជាងនេះទៅទៀត ការប្រមូលទិន្នន័យ ត្រូវបានធ្វើឡើងដោយប្រើប្រាស់ការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ ការចុះប្រមូលទិន្នន័យតាមទីតាំងគោលដៅ និងការចុះពិនិត្យទីតាំងគោលដៅ ជាវិធីសាស្ត្រក្នុងការវាយតម្លៃសាលាតំណាងចំនួន ០៥ (ពីថ្នាក់ទី១០-១២) ក្នុងខេត្តកំពង់ស្ពឺ។

លទ្ធផលបានពីការសិក្សានេះ អាចអនុញ្ញាតឱ្យអ្នកស្រាវជ្រាវធ្វើការដាក់ស្នើនូវគំរូអប់រំស្ទែមថ្មីមួយសម្រាប់ថ្នាក់ទី១០-១២ ដែលសមស្របសម្រាប់ការអនុវត្តនៅក្នុងសាលាមួយដែលត្រូវបានជ្រើសរើសនៅក្នុងខេត្តកំពង់ស្ពឺ ព្រមទាំងសម្រាប់ការពិចារណាបន្ថែមទៀតដើម្បីប្រែក្លាយគំរូនេះឱ្យក្លាយជាគំរូសមស្របសម្រាប់សាលាជាច្រើនទៀតនៅក្នុងប្រទេសកម្ពុជានៅក្នុងរយៈពេលយូរ។

# ២. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះប្រើវិធីសាស្ត្រចម្រុះដូចជា ការពិនិត្យឯកសារពាក់ព័ន្ធនានា កម្រងសំណួរសម្រាប់គ្រូបង្រៀន, ការសម្ភាសន៍ពាក់កណ្ដាលរចនាសម្ព័ន្ធសម្រាប់នាយក-នាយករងនិងគណៈគ្រប់គ្រងសាលា និងការចុះវាយតម្លៃនៅទីតាំងផ្ទាល់ រួមទាំងបញ្ជីវាយតម្លៃ និងសង្កេត សម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តទូទៅនៅក្នុងសាលារៀនចំនួន ០៥ ដែលបានជ្រើសរើសនៅក្នុងខេត្តកំពង់ស្ពឺ។

## ២.១. សំណាក និងការជ្រើសរើស

វិទ្យាល័យចំនួន ០៥ ក្នុងចំណោមវិទ្យាល័យទាំង២៤ នៅក្នុងស្រុក-ក្រុងផ្សេងៗគ្នាក្នុងខេត្តកំពង់ស្ពឺត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ។ វិទ្យាល័យទាំងនោះមានដូចជា វិទ្យាល័យកំពង់ស្ពឺ នៅក្នុងក្រុងច្បារមន វិទ្យាល័យចាន់ថ្នាល នៅក្នុងស្រុកឧត្ដុង្គ វិទ្យាល័យឱរ៉ាល់ នៅក្នុងស្រុកឱរ៉ាល់ វិទ្យាល័យស្លាបលែង នៅក្នុងស្រុកបសេដ្ឋ និងវិទ្យាល័យទ័ពមានជ័យ នៅក្នុងស្រុកគងពិសី។ សាលាទាំងនេះ តំណាងឱ្យតំបន់ភូមិសាស្ត្រចំនួន០៣ នៅក្នុងខេត្តកំពង់ស្ពឺ ព្រមទាំងបរិបទសេដ្ឋកិច្ចរបស់សហគមន៍នៅតាមទីតាំងរបស់សាលាទាំងនោះ។ ក្នុងចំណោមសាលាទាំងនោះ មានសាលាមួយនៅក្រុងច្បារមនដែលជាបេះដូងនៃខេត្តនេះ ដែលស្ថិតនៅភាគឦសាននៃខេត្តកំពង់ស្ពឺ វិទ្យាល័យពីរទៀតស្ថិតនៅភាគអាគ្នេយ៍ និងមួយទៀតស្ថិតក្នុងតំបន់ជនបទនៅឯភាគពាយ័ព្យនៃខេត្តនេះ។ នៅក្នុងការសិក្សានេះ មានគ្រូបង្រៀនសរុបចំនួន ៦៦នាក់ បានចូលរួមឆ្លើយកម្រងសំណួរ ដែលក្នុងនោះមាន ៦៧% ជាគ្រូបង្រៀនដែលទាក់ទងនឹងមុខវិជ្ជាស្ទែម និង ៣៣% ជាគ្រូបង្រៀនមិនទាក់ទងនឹងមុខវិជ្ជាស្ទែម។ ការជ្រើសរើសគ្រូបង្រៀនចូលរួមក្នុងកម្រងសំណួរត្រូវបានធ្វើឡើងដោយប្រើវិធីសាស្ត្រជ្រើសរើសដោយចៃដន្យ និងបែបងាយស្រួល។ តារាងទី៣ បានសង្ខេបឈ្មោះសាលារៀន ស្រុក-ក្រុង ដែលជាទីតាំងសាលារៀនទាំងនោះ និងចំនួនគ្រូបង្រៀនដែលបានចូលរួមឆ្លើយសំណួរ។

**តារាងទី៣៖** ឈ្មោះវិទ្យាល័យ និងចំនួនគ្រូបង្រៀនបានចូលរួមក្នុងអំឡុងចុះសិក្សាស្រាវជ្រាវ

| ល.រ. | ឈ្មោះវិទ្យាល័យ | ទីតាំង | ចំនួនគ្រូបង្រៀនចូលរួមឆ្លើយ |
|---|---|---|---|
| ១. | វិទ្យាល័យឱរ៉ាល់ | ស្រុកឱរ៉ាល់ | ១១ |
| ២. | វិទ្យាល័យកំពង់ស្ពឺ | ក្រុងច្បារមន | ១៦ |
| ៣. | វិទ្យាល័យស្លាបលែង | ស្រុកបសេដ្ឋ | ២៤ |
| ៤. | វិទ្យាល័យចាន់ថ្នាល | ស្រុកឧត្ដុង្គ | ៨ |
| ៥. | វិទ្យាល័យទ័ពមានជ័យ | ស្រុកគងពិសី | ៧ |

នាយក និងគណៈគ្រប់គ្រងសាលាពី ០២ ទៅ ០៤នាក់ នៅសាលានីមួយៗ ត្រូវបានជ្រើសរើសសម្រាប់ការសម្ភាសន៍ទល់មុខ (តារាងទី៤)។ សមាជិកមកពីគណៈគ្រប់គ្រងរួមមាន មន្ត្រីរដ្ឋបាល និង

ហិរញ្ញវត្ថុផងដែរ។ គោលបំណងដែលរាប់បញ្ចូលវត្ថុមាននាយក និងគណៈគ្រប់គ្រងក្នុងការសិក្សានេះ គឺដើម្បីស្វែងយល់ឱ្យបានកាន់តែស៊ីជម្រៅអំពីកម្មវិធីអប់រំ និងកម្មវិធីពិសេសផ្សេងទៀតដែលកំពុងអនុវត្ត, តើសាលាកំពុងដំណើរការដោយរបៀបណា, តើអ្វីខ្លះជាចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង, អ្វីជាបញ្ហាប្រឈមដែលសាលាធ្លាប់ជួបប្រទះ ហើយតើជម្នះវាបានដោយរបៀបណា, តើអ្វីជាមេរៀនដែលបានមកពីបទពិសោធន៍ទាំងនោះ។ល។ ក្រៅពីនេះ សំណួរជាច្រើនទៀតត្រូវបានចោទសួរទៅកាន់នាយក និងគណៈគ្រប់គ្រង នៃសាលានីមួយៗ ដើម្បីទទួលបានព័ត៌មានទូទៅអំពីស្ថិតិបុគ្គលិក សម្ភារបរិក្ខារ ផែនការអភិវឌ្ឍន៍សាលា (ប្រសិនបើមាន) និងភស្តុតាងដែលគាំទ្រវិធីសាស្ត្របង្រៀនបែបស្ទែម។ ខាងក្រោមនេះបង្ហាញពីឈ្មោះសាលា និងចំនួននាយក និងគណៈគ្រប់គ្រង ដែលបានជ្រើសរើសក្នុងការសិក្សា។

**តារាងទី ៤៖** ចំនួននាយក និងគណៈគ្រប់គ្រងសាលាដែលបានចូលរួម

| ល.រ. | ឈ្មោះវិទ្យាល័យ | ទីតាំង | ចំនួននាយក និងគណៈគ្រប់គ្រង |
|---|---|---|---|
| ១. | វិទ្យាល័យឱរ៉ាល់ | ស្រុកឱរ៉ាល់ | ២ |
| ២. | វិទ្យាល័យកំពង់ស្ពឺ | ក្រុងច្បារមន | ២ |
| ៣. | វិទ្យាល័យស្លាបលែង | ស្រុកបសេដ្ឋ | ៤ |
| ៤. | វិទ្យាល័យចាន់ថ្នាល | ស្រុកឧត្តុង្គ | ៣ |
| ៥. | វិទ្យាល័យទ័ពមានជ័យ | ស្រុកគងពិសី | ៤ |

## ២.២. ការប្រមូលទិន្នន័យ

### ២.២.១. ការស្ទង់មតិដោយប៊ិក-ក្រដាស

ជាផ្នែកមួយនៃការប្រមូលព័ត៌មាន ការស្ទង់មតិដោយប៊ិក-ក្រដាសត្រូវបានរៀបចំក្នុងគោលបំណងដើម្បីស្វែងយល់ពីបរិបទផ្ទាល់ខ្លួន និងការអប់រំរបស់អ្នកឆ្លើយសំណួរទាក់ទងនឹងចំណេះដឹង និងជំនាញដែលពួកគេមានពាក់ព័ន្ធនឹងការអនុវត្តវិធីសាស្ត្រនៃការបង្រៀនស្ទែម ក៏ដូចជាបញ្ហាប្រឈមដែលពួកគេត្រូវជម្នះដើម្បីជានាភាពជោគជ័យក្នុងការអនុវត្តការអប់រំស្ទែម។

### ២.២.២. ការវិភាគគោលនយោបាយ និងឯកសារសិក្សាដែលមានស្រាប់

សម្រាប់ការពិនិត្យឯកសារដែលមានស្រាប់ ការសិក្សានេះបានមើលទៅលើគំរូអប់រំស្ទែមមានស្រាប់ដែលកំពុងដាក់អនុវត្តនៅកម្ពុជា ដូចជាគំរូរបស់សាលារៀនជំនាន់ថ្មី និងការជ្រើសរើសគំរូសាលារៀនជាប្រព័ន្ធដែលបានអនុវត្តទាំងកម្រិតតំបន់ និងអន្តរជាតិ។

### ២.២.៣. ការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ

ការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធជាមួយនាយក និងគណៈគ្រប់គ្រង ត្រូវបានធ្វើឡើងនៅក្នុងសាលានីមួយៗដែលបានជ្រើសរើសដើម្បីស្វែងយល់ពីប្រវត្តិរបស់សាលា កម្មវិធីពង្រឹងសមត្ថភាពដែលមាននៅក្នុងសាលានីមួយៗ, ដៃគូ/អ្នកសហការពាក់ព័ន្ធ, ដំណើរការជ្រើសរើស និងតែងតាំង, កាលវិភាគបណ្តុះបណ្តាលសម្រាប់បន្ទប់ពិសោធន៍ និងការអនុវត្តផ្ទាល់។ លើសពីនេះ សមត្ថភាព និងចំណេះដឹងរបស់គណៈគ្រប់គ្រងសាលា រួមទាំងភាពជាអ្នកដឹកនាំ ក្រុមរដ្ឋបាល និងក្រុមហិរញ្ញវត្ថុ ត្រូវបានសង្កេតបន្ថែមពីលើសកម្មភាពសិក្សាដែលមានផ្តល់ជូន ការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិក ការថែទាំសម្ភារបរិក្ខារ សេវាកម្ម សុវត្ថិភាព និងក្រមសីលធម៌វិជ្ជាជីវៈ ដែលជាតម្រូវការនៅតាមសាលារៀននីមួយៗ។ សំណួរជាច្រើនទៀតត្រូវបានសាកសួរ ដើម្បីទទួលបានព័ត៌មានជាច្រើនទៀតទាក់ទងនឹងការអនុវត្តកម្មវិធីសិក្សា ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ធនធានមនុស្ស អភិបាលកិច្ច ការរៀបចំផែនការ ការគ្រប់គ្រង និងហិរញ្ញវត្ថុ។ គួរបញ្ជាក់ផងដែរថា គោលបំណងសំខាន់មួយទៀតនៃការសម្ភាសន៍ជាមួយនាយកសាលា គឺដើម្បីស្វែងយល់ពីការយល់ឃើញរបស់ពួកគាត់ អំពីទិសដៅអនាគតឆ្ពោះទៅរកការអនុវត្តគំរូអប់រំស្វែមក្នុងការបង្រៀន និងរៀន ព្រមទាំងទស្សនៈរបស់ពួកគាត់អំពី (១) ចំណេះដឹងអំពីខ្លឹមសារ និងគរុកោសល្យក្នុងចំណោមគ្រូបង្រៀនដែលជាបុគ្គលិករបស់ពួកគាត់ និងអ្វីដែលជាចំណុចត្រូវកែលម្អ (២) ជំនាញក្នុងការវាយតម្លៃការសិក្សារបស់សិស្ស ការគ្រប់គ្រងថ្នាក់រៀន ដោយបង្វែរចំណាប់អារម្មណ៍ពីអាកប្បកិរិយា និងឥរិយាបថរបស់សិស្ស និង (៣) អ្វីដែលគួរជាកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់អនាគត ដើម្បីធានាថាគ្រូបង្រៀនទាំងអស់កាន់តែមានជំនាញវិជ្ជាជីវៈ។

### ២.២.៤. ការសង្កេតតាមរយៈការចុះដល់ទីតាំងផ្ទាល់

បញ្ជីសង្កេតដែលបានរៀបចំដោយក្រុមស្រាវជ្រាវ ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការកត់ត្រាអំពីភាពដែលអាចរកបាន និងលក្ខខណ្ឌនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ភាពដែលអាចចល័តបាន និងមិនអាចចល័តបាននៃសម្ភារដែលជាធនធានមានសក្តានុពលក្នុងការជួយដល់ការអនុវត្តគំរូអប់រំស្វែម។

## ២.៣. វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យបឋមរួមមានដូចជា កម្រងការស្ទង់មតិ ការថតសំឡេងបទសម្ភាសន៍ និងបញ្ជីសង្កេតទទួលបានពីវិទ្យាល័យដែលបានជ្រើសរើសទាំង០៥ នៅខេត្តកំពង់ស្ពឺ។ ការវិភាគលើការស្ទង់មតិ និងបញ្ជីសង្កេត ត្រូវបានធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រស្ថិតិបែបពណ៌នា។ ការថតសំឡេងដែលទទួលបានពីការសម្ភាសន៍នៅវិទ្យាល័យស្ថិតក្នុងសិក្សា ត្រូវបានដកស្រង់ និងបញ្ចូលក្នុងលទ្ធផលវិភាគ ដើម្បីប្រើប្រាស់ដោយផ្នែកសម្រាប់ការដាក់ស្នើគំរូអប់រំស្វែម។ ក្រៅពីលទ្ធផលទាំងនេះ ការវិភាគយ៉ាងស៊ីជម្រៅនៃឯកសារគន្លឹះៗដែលអាចរកបានពីតំណាងសាលារៀនជំនាន់ថ្មី ត្រូវបានធ្វើឡើង ហើយបន្ទាប់មកត្រូវ

បានប្រើប្រាស់ជាការរួមចំណែកមួយផ្នែកក្នុងអនុសាសន៍សម្រាប់ខេត្តកំពង់ស្ពឺ បន្ថែមពីលើលក្ខណៈវិនិច្ឆ័យសម្រាប់គំរូអប់រំស្នែមដែលមានស្រាប់។

## ៣. ការវាយតម្លៃលើវិទ្យាល័យដែលត្រូវបានជ្រើសរើសក្នុងខេត្តកំពង់ស្ពឺ

ផ្នែកបន្ទាប់ នឹងបង្ហាញអំពីស្ថានភាពនៃវិទ្យាល័យទាំង០៥ នៅក្នុងខេត្តកំពង់ស្ពឺ។ ការសិក្សាផ្តោតទៅលើ (១) រចនា-សម្ព័ន្ធជាមូលដ្ឋានដែលទ្រទ្រង់ដល់ការបង្រៀន និងរៀន (២) រចនាសម្ព័ន្ធជាមូលដ្ឋានដែលគាំទ្រដល់ទំនាក់ទំនងសាលារៀន-សហគមន៍ (៣) អភិបាលកិច្ច (៤) បុគ្គលិកផ្នែកគ្រប់គ្រង និងផ្នែកគាំទ្រ (៥) ធនធានហិរញ្ញប្បទាន/ហិរញ្ញវត្ថុ (៦) គ្រូបង្រៀនស្វែម និងគុណវុឌ្ឍិគ្រូបង្រៀន (៧) ចំណេះដឹង និងជំនាញរបស់គ្រូបង្រៀន។

### ៣.១. រចនាសម្ព័ន្ធជាមូលដ្ឋានដែលទ្រទ្រង់ដល់ការបង្រៀន និងរៀន

អនុផ្នែកនេះ បង្ហាញអំពីរចនាសម្ព័ន្ធជាមូលដ្ឋានដែលទ្រទ្រង់ដល់ការបង្រៀន និងរៀននៅវិទ្យា-ល័យទាំង០៥។ យោងតាមតារាងទី៥ ចំនួនអគារសិក្សានៅក្នុងវិទ្យាល័យទាំង០៥ នោះ មានចាប់ពី០២ ទៅ ០៥ អគារ ដែលក្នុងនោះ វិទ្យាល័យកំពង់ស្ពឺ និងវិទ្យាល័យទ័ពមានជ័យមានអគារសរុបចំនួន០៥ រៀងៗខ្លួន ប្រើប្រាស់សម្រាប់ថ្នាក់រៀន។ ផ្ទុយពីនេះ វិទ្យាល័យឱរ៉ាល់ និងវិទ្យាល័យស្លាបលែងមានតែ ០២ អគារប៉ុណ្ណោះ និងវិទ្យាល័យចាន់ថ្នាលមានចំនួន ០៣ អគារ។ នៅក្នុងចំណោមសាលាទាំងនេះ វិទ្យាល័យកំពង់ស្ពឺដែលមានទីតាំងនៅក្នុងក្រុង មានបន្ទប់រៀនរហូតដល់ ២៥ បន្ទប់ ខណៈវិទ្យាល័យឱរ៉ាល់ មានត្រឹមតែ ១០ បន្ទប់តែប៉ុណ្ណោះ។

នៅវិទ្យាល័យឱរ៉ាល់ ចំនួនសិស្សថ្នាក់ទី១០ ក្នុងមួយបន្ទប់មានជាមធ្យម ៣៦នាក់ និង ៦៨នាក់ សម្រាប់វិទ្យាល័យកំពង់ស្ពឺ ខណៈថ្នាក់ទី១១ មានសិស្សក្នុងមួយថ្នាក់ជាមធ្យម ៤១នាក់សម្រាប់វិទ្យាល័យស្លាបលែង និង៧០នាក់សម្រាប់វិទ្យាល័យកំពង់ស្ពឺ។ មិនខុសគ្នាពីថ្នាក់ទី១០ និងទី១១ ទេ ចំនួនសិស្សថ្នាក់ទី១២ ក្នុងមួយបន្ទប់គឺ ៣៧ នាក់ជាមធ្យមសម្រាប់វិទ្យាល័យឱរ៉ាល់ និង ៦០នាក់សម្រាប់វិទ្យាល័យកំពង់ស្ពឺ។

បណ្ណាល័យនៅក្នុងសាលារៀនទាំង០៥ មានសភាពប្រហាក់ប្រហែលគ្នា។ បណ្ណាល័យទាំងនោះ មានទំហំតូច សភាពចាស់ និងដំណើរការមិនបានពេញលេញ ដោយសៀវភៅសិក្សាមានកំណត់ និងហួសសម័យ។ លើសពីនេះទៅទៀត កន្លែងអង្គុយមានចំនួនតិចតួចប៉ុណ្ណោះដែលមានភាពរញ៉េរញ៉ៃ និងមិនមានការរៀបចំឱ្យបានត្រឹមត្រូវសម្រាប់អ្នកចូលអាន។ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រសម្រាប់មុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា នៅសាលារៀនចំនួន០៤ (លើកលែងវិទ្យាល័យឱរ៉ាល់ ដែលមិនមានបន្ទប់ពិសោធន៍) សុទ្ធសឹងតែមានស្ថានភាពមិនល្អ និងមិនអាចឆ្លើយតបទៅនឹងតម្រូវការសិក្សានាពេលបច្ចុប្បន្ននេះបានទេ ជាពិសេសប្រសិនបើការអប់រំស្វែមត្រូវបានដាក់អនុវត្ត។ បន្ទប់កុំព្យូទ័រ និងចំនួនកុំព្យូទ័របច្ចុប្បន្ន ព្រមទាំងសម្ភារបរិក្ខារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មិនទាន់មាន ឬមិនទាន់មានគ្រប់គ្រាន់សម្រាប់ឆ្លើយតបនឹងចំនួនសិស្សជាក់ស្តែងនៅក្នុងសាលារៀនទាំងនោះនៅឡើយទេ ក្នុងនោះមានដូចជា ការតភ្ជាប់អ៊ីនធឺណិត ឧបករណ៍ចាក់បញ្ចាំង (LCD) និងក្តារខៀនវៃឆ្លាតសម្រាប់ថ្នាក់រៀនវៃឆ្លាត។

ក្នុងចំណោមសាលារៀនដែលបានជ្រើសរើស មានតែសាលារៀនចំនួនពីរប៉ុណ្ណោះដែលមានបន្ទប់ប្រជុំ គឺវិទ្យាល័យកំពង់ស្ពឺ និងវិទ្យាល័យស្លាបលែង។ លើសពីនេះទៀត មិនមែនសាលារៀនទាំងអស់សុទ្ធតែមានបន្ទប់សិក្សា និងរោងជាងនោះទេ។

**តារាងទី ៥៖** ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាននៃវិទ្យាល័យទាំង០៥ នៅក្នុងខេត្តកំពង់ស្ពឺ (ថ្នាក់ទី១០-១២)

| ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ថ្នាក់ទី១០-១២) | | វិទ្យាល័យ ឱរ៉ាល់ | វិទ្យាល័យ កំពង់ស្ពឺ | វិទ្យាល័យ ស្លាបលែង | វិទ្យាល័យ ចាន់ថ្ពល | វិទ្យាល័យ ទំពមានជ័យ |
|---|---|---|---|---|---|---|
| ព័ត៌មានទូទៅ | | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន |
| អគារសិក្សា | | ២ | ៥ | ២ | ៣ | ៥ |
| បន្ទប់រៀន | | ១០ | ២៥ | ១០ | ១១ | ១៧ |
| ចំនួនសិស្សក្នុងមួយបន្ទប់ | ថ្នាក់ទី ១០ | ៣៦ | ៦៨ | ៤៩ | ៥១ | ៥០ |
| | ថ្នាក់ទី ១១ | ៥៩ | ៧០ | ៤១ | ៥៦ | ៤៦ |
| | ថ្នាក់ទី ១២ | ៣៧ | ៦០ | ៤០ | ៥៤ | ៤៣ |
| បន្ទប់ពិសោធន៍ | ជីវវិទ្យា | ០ | ១ (រួមបញ្ចូលគ្នា) | ១ | ១ (រួមបញ្ចូលគ្នា) | ១ |
| | គីមីវិទ្យា | ០ | | ១ | | ១ |
| | រូបវិទ្យា | ០ | ១ (រួមបញ្ចូលគ្នា) | ១ (រួមបញ្ចូលគ្នា) | | ១ (រួមបញ្ចូលគ្នា) |
| | ផែនដី និង បរិស្ថានវិទ្យា | | | | | |
| | កុំព្យូទ័រ | ០ | ២ | ១ | ១ | ១ |
| | ភាសាអង់គ្លេស | ០ | ០ | ០ | ០ | ០ |
| សម្ភារបរិក្ខារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន | អ៊ីនធឺណេត | ០ | ០ | ០ | ០ | ០ |
| | ម៉ាស៊ីនបញ្ចាំង (LCD) | ០ | ២ | ០ | ០ | ១ |
| | ក្តារខៀនវៃឆ្លាត | ០ | ០ | ០ | ០ | ០ |
| បណ្ណាល័យ | | ០ | ២ (ចំនួនសៀវភៅមានកម្រិត និងកង្វះការរៀបចំ) | ១ (ចំនួនសៀវភៅ មានកម្រិត និងកង្វះការរៀបចំ) | ១ | ១ |
| បន្ទប់រៀន | | ០ | ០ | ០ | ០ | ០ |
| បន្ទប់ប្រជុំ | | ០ | ១ (អតិបរមាសម្រាប់សិស្ស ១០០ នាក់) | ១ (អតិបរមាសម្រាប់សិស្ស ៨០ នាក់) | ០ | ០ |
| រោងជាង | | ០ | ០ | ០ | ០ | ០ |

## ៣.២. រចនាសម្ព័ន្ធជាមូលដ្ឋានដែលគាំទ្រដល់ទំនាក់ទំនងសាលារៀន-សហគមន៍

តារាងទី៦ បង្ហាញអំពីរចនាសម្ព័ន្ធមូលដ្ឋានដែលគាំទ្រដល់ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍។ យោងតាមតារាងនេះ សាលារៀននីមួយៗមានការិយាល័យសម្រាប់គណៈគ្រប់គ្រង បុគ្គលិកជាគ្រូបង្រៀន និងបុគ្គលិកមិនមែនគ្រូបង្រៀន ប៉ុន្តែមិនមានបន្ទប់សម្រាប់សន្និសុខ បន្ទប់អនាម័យ និងបន្ទប់ញ៉ាំអាហារនោះទេ។

ការិយាល័យសម្រាប់គណៈគ្រប់គ្រងនៃសាលាទាំងអស់ សុទ្ធតែមានសភាពល្អ។ ប៉ុន្តែ មានតែវិទ្យាល័យកំពង់ស្ពឺ និងវិទ្យាល័យស្លាបលែងប៉ុណ្ណោះដែលមានការរៀបចំបានល្អប្រសើរ សម្រាប់បុគ្គលិកមិនមែនគ្រូបង្រៀន បើទោះបីជា ការិយាល័យទាំងនោះមានទំហំតូច និងមិនមានបំពាក់ដោយសម្ភារបរិក្ខារចាំបាច់ពេញលេញក៏ដោយ។

សម្រាប់ហេដ្ឋារចនាសម្ព័ន្ធខាងក្រៅអគារសិក្សា មិនមានសួនដំណាំចម្រុះនៅក្នុងសាលារៀនដែលបានជ្រើសរើសនោះទេ លើកលែងតែវិទ្យាល័យចាន់ថ្នាល។ ប៉ុន្តែ សួនដំណាំចម្រុះនៅក្នុងវិទ្យាល័យចាន់ថ្នាលនោះ ត្រូវការការរៀបចំកែលម្អ ឬធ្វើឱ្យប្រសើរឡើងសម្រាប់គោលបំណងការអប់រំស្វែម។ ផ្ទុយទៅវិញ សាលារៀនដែលត្រូវបានជ្រើសរើសទាំងអស់មានអាហារដ្ឋាន លើកលែងតែវិទ្យាល័យចាន់ថ្នាល ទោះបីអាហារដ្ឋានទាំងនោះមិនមានសភាពល្អ និងអនាម័យក៏ដោយ។ សាលារៀនទាំងអស់ មានទីធ្លាសមស្របសម្រាប់សកម្មភាពកីឡា និងសួនច្បារ។ សាលារៀនទាំងអស់មានហេដ្ឋារចនាសម្ព័ន្ធប្រសើរ និងងាយស្រួលក្នុងប្រើប្រាស់ ដូចជាបង្គន់អនាម័យ និងកន្លែងលាងដៃ ទីតាំងចំណត ទីលានចាក់សំរាម ការផ្គត់ផ្គង់ទឹក និងអគ្គិសនី។ យ៉ាងណាក្តី ចំណតនៅវិទ្យាល័យស្លាបលែងមានទំហំតូចពេក។

ការសិក្សានេះក៏បានអញ្ជើញគ្រូបង្រៀន ដើម្បីចូលរួមវាយតម្លៃគុណភាពនៃបរិក្ខាររូបវ័ន្តសាលារៀនរបស់ពួកគាត់ផងដែរ រួមមានអគារសិក្សា ថ្នាក់បង្រៀន និងរៀន បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ប្រតិបត្តិការបណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់គ្រូបង្រៀន ការិយាល័យរដ្ឋបាល និងទីធ្លាសាលារៀន។ ជាទូទៅ អគារសិក្សា និងថ្នាក់រៀននៅវិទ្យាល័យកំពង់ស្ពឺ វិទ្យាល័យស្លាបលែង វិទ្យាល័យចាន់ថ្នាល និងវិទ្យាល័យទ័ពមានជ័យ សុទ្ធសឹងតែមានសភាពល្អប្រសើរ ប៉ុន្តែគុណភាពអគារសិក្សានៅវិទ្យាល័យឱរ៉ាល់មានសភាពមិនល្អនោះទេ។ តាមការសង្កេតដោយក្រុមស្រាវជ្រាវ និងគ្រូបង្រៀន សុទ្ធតែបង្ហាញថា អគារជនជានមានសភាពល្អបើប្រៀបធៀបទៅនឹងអគារផ្សេងៗទៀត នៅក្នុងសាលារៀន។ ក្រៅពីនេះ ក៏មានបន្ទប់ ដែលគ្រូបង្រៀនអាចប្រើប្រាស់បានផងដែរ។

សម្រាប់វិទ្យាល័យចាន់ថ្នាល ទោះបីជាមានបន្ទប់ពិសោធន៍ក៏ដោយ ប៉ុន្តែគុណភាពបន្ទប់ពិសោធន៍នៅមានកម្រិតទាប ខណៈវិទ្យាល័យឱរ៉ាល់ មិនមានបន្ទប់ពិសោធន៍ទាល់តែសោះ។ គុណភាពបន្ទប់ពិសោធន៍នៅវិទ្យាល័យកំពង់ស្ពឺ វិទ្យាល័យស្លាបលែង និងវិទ្យាល័យទ័ពមានជ័យ មានសភាពមធ្យម បើនិយាយពីទំហំ និងហេដ្ឋារចនាសម្ព័ន្ធបន្ទប់ពិសោធន៍ជាមូលដ្ឋាន។ យ៉ាងណាក៏ដោយ គុណភាពឧបករណ៍

និងសម្ភារពិសោធន៍ មិនល្អគ្រប់គ្រាន់ និងមិនអាចប្រើប្រាស់បានពេញលេញសម្រាប់ការបង្រៀន និងរៀនបែបស្វែមនោះទេ។

**តារាងទី ៦៖** ហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់វិទ្យាល័យនីមួយៗដែលបានជ្រើសរើសក្នុងខេត្តកំពង់ស្ពឺ

| ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ថ្នាក់ទី១០-១២) | វិទ្យាល័យ ឱរ៉ាល់ | វិទ្យាល័យ កំពង់ស្ពឺ | វិទ្យាល័យ ស្លាបលែង | វិទ្យាល័យ ចាន់ថ្នាល | វិទ្យាល័យ ទ័ពមានជ័យ |
|---|---|---|---|---|---|
| **ព័ត៌មានទូទៅ** | **ចំនួន** | **ចំនួន** | **ចំនួន** | **ចំនួន** | **ចំនួន** |
| **អគាររដ្ឋបាល** | | | | | |
| ការិយាល័យសម្រាប់គណៈគ្រប់គ្រង | ១ | ១ | ១ | ១ | ១ |
| ការិយាល័យសម្រាប់បុគ្គលិកមិនមែនគ្រូបង្រៀន | ១ | ១ | ១ | ០ | ០ |
| ការិយាល័យសម្រាប់បុគ្គលិកជាគ្រូបង្រៀន | ១ | ១ | ១ | ១ | ០ |
| បន្ទប់អាហារសម្រាប់បុគ្គលិក | ០ | ០ | ០ | ០ | ០ |
| បន្ទប់សម្រាប់សន្តិសុខ និងបុគ្គលិកអនាម័យ | ០ | ០ | ០ | ០ | ០ |
| **ព័ត៌មានទូទៅក្រៅអគារ** | | | | | |
| សួនដំណាំចម្រុះ | ០ | ០ | ០ | ១ | ០ |
| អាហារដ្ឋាន | ១ | ១ | ១ | ០ | ១ |
| ទីធ្លាសម្រាប់សកម្មភាពកីឡា | ១ | ១ | ១ | ១ (តារាងបាល់ទះ) | ១ |
| សួនច្បារ | ១ | ១ | ១ | ១ | ១ |
| បង្គន់អនាម័យ និងកន្លែងលាងដៃ | ១ | ១ | ១ | ៤ | ១ |
| ចំណត | ១ | ១ | ០ | ១ | ០ |
| ទីលានចាក់សំរាម | ១ | ១ | ១ | ១ | ១ |
| ការផ្គត់ផ្គង់ទឹកស្អាត | ១ | ១ | ១ | ១ | ១ |
| អគ្គិសនី | ១ | ១ | ១ | ១ | ១ |

លើសពីនេះទៀត ឧបករណ៍ និងសារធាតុពិសោធន៍វិទ្យាសាស្ត្រ មិនត្រូវបានរក្សាទុកត្រឹមត្រូវទេ ដោយសារតែលក្ខខណ្ឌរបស់បន្ទប់ពិសោធន៍។ ធនធានសិក្សា និងបណ្ណាល័យ នៅវិទ្យាល័យកំពង់ស្ពឺ វិទ្យាល័យស្លាបលែង និងវិទ្យាល័យចាន់ថ្នាលមានស្ថានភាពធម្មតា តែទោះជាយ៉ាងនេះក្តី សាលារៀនទាំងនោះ មិនទាន់មានប្រព័ន្ធគ្រប់គ្រងបណ្ណាល័យនៅឡើយទេ។ គុណភាពបណ្ណាល័យនៅវិទ្យាល័យឱរ៉ាល់ និងវិទ្យាល័យទ័ពមានជ័យ ស្ថិតនៅក្នុងកម្រិតទាបនៅឡើយ។

គុណភាពបន្ទប់កុំព្យូទ័រនៅវិទ្យាល័យកំពង់ស្ពឺ វិទ្យាល័យស្លាបលែង និងវិទ្យាល័យចាន់ថ្នាល មានកម្រិតធម្មតា ចំណែកឯ គុណភាពបន្ទប់កុំព្យូទ័រនៅក្នុងវិទ្យាល័យទ័ពមានជ័យ ស្ថិតក្នុងកម្រិតទាបនៅឡើយ។ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់វិទ្យាល័យទាំង០៥ នៅមានភាពខ្វះខាត រួមទាំងតំណភ្ជាប់អ៊ីនធឺណិតដែលមិនមានស្ថិរភាព។

## ៣.៣. អភិបាលកិច្ចសាលារៀន

អនុផ្នែកនេះ បង្ហាញព័ត៌មានអំពីអភិបាលកិច្ចសាលារៀន ដើម្បីឆ្លុះបញ្ចាំងលើរបៀបដែលវិទ្យាល័យទាំង០៥ ដំណើរការនៅក្នុងបរិបទអភិបាលកិច្ចទូទៅ ជាពិសេសដំណើរការរបស់ក្រុមប្រឹក្សាភិបាលសាលារៀន។ តាមរយៈការសង្កេត ឃើញថាមិនមែនគ្រប់វិទ្យាល័យទាំង០៥ មានក្រុមប្រឹក្សាភិបាលសាលារៀននោះទេ។ ទោះបីជាវិទ្យាល័យខ្លះមានក្រុមប្រឹក្សាភិបាលក៏ដោយ ក៏មិនមានភារកិច្ចច្បាស់លាស់ដែរ។ ហេតុនេះ ការសិក្សាបង្ហាញថា មានកង្វះខាតការចូលរួមពីតួអង្គសំខាន់ៗដែលធ្វើឱ្យសាលាដំណើការបានល្អប្រសើរ ជាពិសេសកង្វះការចូលរួមពីសហគមន៍ និងវិស័យឯកជន។ នេះក៏ឆ្លុះបញ្ចាំងពីអវត្តមានមុខងាររបស់គណៈកម្មការគ្រប់គ្រងសាលា ក្នុងការជំរុញសាលារៀនឱ្យមានស្វ័យភាព និងគណនេយ្យភាព ក្នុងបរិបទនៃកំណែទម្រង់វិស័យអប់រំបច្ចុប្បន្ន ដើម្បីឆ្ពោះទៅរកគំរូការគ្រប់គ្រងផ្អែកលើសាលារៀនប្រកបដោយប្រសិទ្ធភាព។

គ្រប់សាលារៀនទាំងអស់ សុទ្ធតែអះអាងថាមានផែនការយុទ្ធសាស្ត្រ ប៉ុន្តែចក្ខុវិស័យ បេសកកម្ម និងគោលដៅច្បាស់លាស់ មិនឃើញមាននោះទេ លើកលែងតែវិទ្យាល័យកំពង់ស្ពឺ និងវិទ្យាល័យស្លាបលែង (ដែលជាសាលារៀននៅក្រោមគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា [SEIP]) ដែលចក្ខុវិស័យ បេសកកម្ម និងគោលដៅត្រូវបានសរសេរ និងពន្យល់យ៉ាងច្បាស់លាស់នៅក្នុងផែនការយុទ្ធសាស្ត្រ និងឯកសារផ្សេងទៀត។ វិទ្យាល័យទាំង០៥ មានរចនាសម្ព័ន្ធសាលារៀនច្បាស់លាស់។ យ៉ាងណាក៏ដោយ ភស្តុតាងអំពីដំណើរការដែលប្រើក្នុងការអភិវឌ្ឍចំណុចទាំងនោះមិនអាចរកបានទេ ហើយសកម្មភាពស្នូលដើម្បីកែលម្អការគ្រប់គ្រងសាលារៀន ការបង្រៀន និងរៀន ព្រមទាំងយន្តការដើម្បីត្រួតពិនិត្យ និងវាយតម្លៃការសម្រេចបាននូវបេសកកម្ម និងគោលដៅ រួមទាំងដំណើរការស្របទៅតាមរចនាសម្ព័ន្ធមិនទាន់ត្រូវបានកំណត់ច្បាស់លាស់ទេ។ ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចការអប់រំ គឺជាធាតុផ្សំពីរដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ និងមានឥទ្ធិពលយ៉ាងសំខាន់លើប្រតិបត្តិការរបស់សាលា និងស្ថាប័នអប់រំផ្សេងទៀត។ ការរកឃើញដែលទទួលបានពីបទសម្ភាសន៍បង្ហាញថា ភាពដឹកនាំរបស់គណៈគ្រប់គ្រងនៅវិទ្យាល័យទាំង០៥ នៅមានកម្រិត បើទោះបីជាការប្តេជ្ញាចិត្តក្នុងការអនុវត្តការងាររបស់ពួកគេមានពិតប្រាកដក៏ដោយ។

## ៣.៤. បុគ្គលិកគ្រប់គ្រង និងគាំទ្រ

តារាងទី៧ បង្ហាញពីព័ត៌មានអំពីបុគ្គលិកគ្រប់គ្រង និងគាំទ្រ។ យោងតាមតារាងនេះ សាលានីមួយៗមាននាយកសាលា ០១រូប និងនាយករង ០២ ឬ ០៣រូប អាស្រ័យលើទំហំសាលា។ ទោះបីជាទិដ្ឋភាពរួមនៃគុណវុឌ្ឍិរបស់សាលាមិនមានពេញលេញក៏ដោយ ប៉ុន្តែតាមទិន្នន័យដែលក្រុមស្រាវជ្រាវប្រមូលបាន នាយកសាលា ០២រូប បញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រ (វិទ្យាល័យឱ៉ាល់ និងវិទ្យាល័យទ័ពមានជ័យ) ០១រូប បញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ (វិទ្យាល័យចាន់ថ្នាល)។ ចំណែកនាយករងសាលាចំនួន ០៤រូប បញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រ (វិទ្យាល័យឱ៉ាល់ វិទ្យាល័យកំពង់ស្ពឺ វិទ្យាល័យចាន់ថ្នាល

និងវិទ្យាល័យទ័ពមានជ័យ)។ ជារួម សាលានីមួយៗមានការប្រជុំម្តងមួយខែ ជាមួយបុគ្គលិករបស់ពួកគេ និងគណៈគ្រប់គ្រងផ្សេងទៀត។ យោងតាមបទសម្ភាសន៍ជាមួយនាយកសាលា កិច្ចប្រជុំផ្តោតសំខាន់លើផែនការអភិវឌ្ឍន៍សាលារៀន ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ហិរញ្ញវត្ថុ និងសកម្មភាពផ្សេងៗទាក់ទងនឹងការគ្រប់គ្រង ព្រមទាំងលើបញ្ហាការសិក្សាទូទៅផងដែរ។ ទោះជាយ៉ាងណាក៏ដោយ វិក្រឹតការមិនត្រូវបានរកឃើញថាបានដាក់អនុវត្តនៅក្នុងសាលាគោលដៅទាំងអស់នោះទេ។

សម្រាប់បុគ្គលិកផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ សាលារៀននីមួយៗជាធម្មតាមានចំនួន ០១ ឬ ០២ រូប លើកលែងតែវិទ្យាល័យចាន់ថ្នាល ដែលមានបុគ្គលិករដ្ឋបាលចំនួន ០៧រូប ឯវិទ្យាល័យឱរ៉ាល់ មិនមានបុគ្គលិកទទួលខុសត្រូវផ្នែករដ្ឋបាល និងហិរញ្ញវត្ថុទេ។ ម្យ៉ាងវិញទៀត សាលារៀនភាគច្រើនមិនបានយកចិត្តទុកដាក់អំពីការជ្រើសរើសបុគ្គលិកផ្នែកទំនាក់ទំនងសាធារណៈទេ លើកលែងតែវិទ្យាល័យទ័ពមានជ័យ ដែលបានបញ្ជាក់ថា មានបុគ្គលិកផ្នែកទំនាក់ទំនងសាធារណៈ។ គួរកត់សម្គាល់ដែរថា គ្មានវិទ្យាល័យគោលដៅណាមួយ មានបុគ្គលិកទទួលខុសត្រូវលើកិច្ចការសិក្សាធិការនោះទេ លើកលែងតែវិទ្យាល័យចាន់ថ្នាល ដែលចាត់តាំងបុគ្គលិក ០៣រូប សម្រាប់ទទួលបន្ទុកកិច្ចការសិក្សាធិការ។

ចំពោះជំនួយការបន្ទប់ពិសោធន៍ តារាងទី៧ បង្ហាញថា វិទ្យាល័យកំពង់ស្ពឺ មានជំនួយការ ០២រូប ចំណែកវិទ្យាល័យស្លាបលែង និងវិទ្យាល័យចាន់ថ្នាលមាន ០១រូប ហើយវិទ្យាល័យផ្សេងទៀតមិនមាននោះទេ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ រចនាសម្ព័ន្ធគណៈកម្មការប្រឹក្សាសាលាសម្រាប់កិច្ចការមិនមែនសិក្សាធិការរបស់សាលា មានសមាជិកដែលជាសិស្សចំនួន ០៧រូប។ ចំពោះគណៈកម្មការប្រឹក្សាសាលាលើកិច្ចការសិក្សាធិការវិញ មានសមាសភាពដូចជា នាយក នាយករង និងប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជានីមួយៗ ប៉ុន្តែមិនមែនគ្រប់សាលាទាំងអស់បានបង្កើតគណៈកម្មការប្រឹក្សាសាលាបែបនេះទេ គឺមានតែវិទ្យាល័យឱរ៉ាល់ វិទ្យាល័យកំពង់ស្ពឺ និង វិទ្យាល័យទ័ពមានជ័យប៉ុណ្ណោះ ចំណែកឯវិទ្យាល័យចាន់ថ្នាល និងវិទ្យាល័យស្លាបលែង មិនមានទេ។

តារាងទី៧ បង្ហាញបន្ថែមថា មិនមានវិទ្យាល័យណាមួយបានជ្រើសរើសគិលានុបដ្ឋាក មកធ្វើការនៅសាលារៀនទេ ដែលនេះអាចបណ្តាលមកពីថវិកាមានកំណត់ ឬជាការអនុវត្តទូទៅតាមសាលារៀននៅទូទាំងប្រទេស។ ចំពោះបុគ្គលិកអនាម័យវិញ មានតែវិទ្យាល័យកំពង់ស្ពឺប៉ុណ្ណោះ ដែលជ្រើសរើសបុគ្គលិកម្នាក់ ដើម្បីធ្វើការសម្អាតសាលាទាំងមូល ខណៈសាលាផ្សេងទៀតមិនមានទេ។ យោងតាមការសម្ភាសន៍ ការអនុវត្តជាទូទៅគឺ សិស្សានុសិស្សជាអ្នកសម្អាតថ្នាក់រៀនរបស់ពួកគេ ហើយទីតាំងផ្សេងទៀតត្រូវបានសម្អាតរៀងរាល់មួយសប្តាហ៍ម្តងដោយសិស្សានុសិស្សដូចគ្នា។ ជាចុងក្រោយ ទាក់ទងនឹងការបង្កើនជំនាញសម្រាប់បុគ្គលិក តំណាងរបស់សាលាស្ទើរតែទាំងអស់បង្ហាញថា ពួកគេមានសកម្មភាពជាប្រចាំ ដែលនាំទៅដល់ការបង្កើនជំនាញរបស់សមាជិកគណៈគ្រប់គ្រង និងបុគ្គលិក ប៉ុន្តែគេមិនបានបញ្ជាក់ពីជំនាញជាក់លាក់ណាមួយទេ។

**តារាងទី ៧៖** គណៈគ្រប់គ្រងសាលារៀន គុណវុឌ្ឍិ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត

| គុណវុឌ្ឍិគណៈគ្រប់គ្រង និងបុគ្គលិក | | វិទ្យាល័យ ឱរ៉ាល់ | | វិទ្យាល័យ កំពង់ស្ពឺ | | វិទ្យាល័យ ស្លាបលែង | | វិទ្យាល័យ ចាន់ថ្នាល | | វិទ្យាល័យ ទ័ពមានជ័យ | |
|---|---|---|---|---|---|---|---|---|---|---|---|
| គណៈគ្រប់គ្រង | | គុណវុឌ្ឍិ | ចំនួន | គុណវុឌ្ឍិ | ចំនួន | គុណវុឌ្ឍិ | ចំនួន | គុណវុឌ្ឍិ | ចំនួន | គុណវុឌ្ឍិ | ចំនួន |
| នាយក | | | ១ | - | ១ | | ១ | | ១ | | ១ |
| គុណវុឌ្ឍិនាយក | | បរិញ្ញាបត្រ | | - | | - | | អនុបណ្ឌិត | | បរិញ្ញាបត្រ | |
| នាយករង | | | ២ | - | ៣ | | ២ | | ៣ | | ២ |
| គុណវុឌ្ឍិនាយករង | | បរិញ្ញាបត្រ | - | បរិញ្ញាបត្រ | - | - | - | បរិញ្ញាបត្រ | | បរិញ្ញាបត្រ | |
| ការិយាល័យបុគ្គលិក | បុគ្គលិករដ្ឋបាល | - | - | - | ២ | - | ១ | - | ៧ | | ១ |
| | បុគ្គលិកហិរញ្ញវត្ថុ | - | - | - | ១ | - | ១ | - | ២ | | ១ |
| | បុគ្គលិកទំនាក់ទំនងសាធារណៈ | | ០ | | ០ | | ០ | | ០ | | ១ |
| | បុគ្គលិកកិច្ចការសិក្សាធិការ | | ០ | | ០ | | ១ | | ៣ | | ១ |
| | ជំនួយការ បន្ទប់ពិសោធន៍ | | ០ | | ២ | | ១ | | ១ | | ០ |
| | ផ្សេងៗ | លេខា | ១ | | ០ | | ០ | | ០ | | ០ |
| គណៈកម្មការប្រឹក្សាភិបាល | ផ្សេងៗ | សិស្ស ០៧ រូប | ៧ | សិស្ស ០៧ រូប | ៧ | | ០ | | ០ | សិស្ស ០៧ រូប | ៧ |
| | កិច្ចការសិក្សាធិការ | នាយក, នាយករង, | ៦ | | ០ | | ០ | | ១ | | ០ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជានីមួយៗនិងលេខា | | | | | | | | | |
| ចំនួនសន្តិសុខ | នៅក្នុងបរិវេណសាលារៀន | | | | ១ | | 0 | សន្តិសុខ | ១ | | 0 |
| | ច្រកចូល | ប្តូរវេនគ្នា (សិស្ស) | 0៦នាក់ ក្នុង១ថ្ងៃ | | 0 | | 0 | ប្តូរវេនគ្នា (សិស្ស) | 0៦នាក់ ក្នុង១ថ្ងៃ | | 0 |
| គិលានុបដ្ឋាក | | | 0 | | 0 | | 0 | | 0 | | 0 |
| បុគ្គលិកអនាម័យ | | | 0 | | ១ | | 0 | | 0 | | 0 |

## ៣.៥. ធនធានហិរញ្ញប្បទាន/ហិរញ្ញវត្ថុ

តារាងទី៨ បង្ហាញថា បន្ថែមពីលើថវិការបស់រដ្ឋាភិបាល សាលារៀនទាំង០៥ បានទទួលជំនួយមួយចំនួនពីប្រភពផ្សេងៗទៀត ដើម្បីគាំទ្រដល់ប្រតិបត្តិការរបស់សាលារៀន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងដំណើរការបង្រៀន និងរៀន។ លើកលែងតែវិទ្យាល័យកំពង់ស្ពឺ វិទ្យាល័យផ្សេងទៀតដូចជា វិទ្យាល័យឱរ៉ាល់ វិទ្យាល័យស្លាបលែង វិទ្យាល័យចាន់ថ្នាល និងវិទ្យាល័យទ័ពមានជ័យ បានទទួលជំនួយបន្ថែមពីដៃគូអភិវឌ្ឍន៍។ ព័ត៌មានឆ្នាំ២០២១ បានបញ្ជាក់ថា ក្នុងចំណោមសាលាដែលទទួលបានជំនួយហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ មានតែវិទ្យាល័យទ័ពមានជ័យប៉ុណ្ណោះ ដែលបានទទួលរហូតដល់ ១១ ៩១៦ ៩០០ រៀល។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ជាងនេះទៀតនោះគឺ វិទ្យាល័យកំពង់ស្ពឺ ទទួលបានជំនួយហិរញ្ញវត្ថុបន្ថែមពីមាតាបិតាសិស្សច្រើនជាងវិទ្យាល័យដ៏ទៃទៀត ដែលមានទំហំថវិកាប្រមាណ ៨ ០០០ ០០០ រៀល។ វាគឺជាឧទាហរណ៍ដ៏ល្អមួយនៃការចូលរួមរបស់មាតាបិតាសិស្ស ក្នុងការជួយគាំទ្រដល់ប្រតិបត្តិការរបស់សាលា និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ។ យោងតាមបទសម្ភាសន៍ជាមួយនាយកសាលា សហគមន៍ក៏បានចូលរួមដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងគោលបំណងផ្សេងទៀតដោយស្ម័គ្រចិត្ត មិនថាតាមរយៈការអំពាវនាវសុំជំនួយពីនាយកសាលា ឬសំណើសុំជំនួយពីវត្តអារាមនៅក្នុងស្រុកនោះទេ។

**តារាងទី៨៖** ថវិកាប្រចាំឆ្នាំ២០២០ ដែលទទួលបានពីរដ្ឋាភិបាល និងប្រភពផ្សេងទៀតនៅតាមវិទ្យាល័យនីមួយៗ ដែលបានជ្រើសរើស ក្នុងខេត្តកំពង់ស្ពឺ

| អភិបាលកិច្ច និងការគ្រប់គ្រង | | វិទ្យាល័យ ឱរ៉ាល់ | វិទ្យាល័យ កំពង់ស្ពឺ | វិទ្យាល័យ ស្លាបលែង | វិទ្យាល័យ ចាន់ថ្នាល | វិទ្យាល័យ ទ័ពមានជ័យ |
|---|---|---|---|---|---|---|
| ប្រភពថវិកាប្រចាំឆ្នាំ | | ចំនួន (រៀល) | ចំនួន (រៀល) | ចំនួន (រៀល) | ចំនួន (រៀល) | ចំនួន (រៀល) |
| រាជរដ្ឋាភិបាល | | ៣២ ៧២៤ ០០០ | ១១៦ ០០០ ០០០ | ៧៨ ៤៦៦ ៨០០ | ៦៥ ៩០០ ៦០០ | ៥៣ ០២២ ០០០ |
| ផ្សេងៗ | ដៃគូអភិវឌ្ឍន៍ | ៦១៦ ០០០ | ០ | ១០ ១៥០ ០០០ | ៤ ៩៥០ ៤០០ | ១១ ៩១៦ ៩០០ |
| | មាតាបិតាសិស្ស | ០ | ៨ ០០០ ០០០ | ០ | ០ | ០ |
| | សហគមន៍ | ០ | ០ | ១ ០០០ ០០០ | ២ ០០០ ០០០ | ០ |

## ៣.៦. គ្រូបង្រៀនស្វែម និងគុណវុឌ្ឍិរបស់គ្រូបង្រៀន

យោងតាមតារាងទី៩ ចំនួនគ្រូបង្រៀនដែលត្រូវបានចាត់តាំងតាមមុខវិជ្ជាដូចជា ជីវវិទ្យា គីមីវិទ្យា រូបវិទ្យា ផែនដីនិងបរិស្ថានវិទ្យា គណិតវិទ្យា កុំព្យូទ័រ មានចន្លោះពី ០១ ទៅ ០៤រូប ។ ឧទាហរណ៍ មានគ្រូបង្រៀនចំនួន ០៤រូប សម្រាប់មុខវិជ្ជាជីវវិទ្យា និងគីមីវិទ្យា នៅវិទ្យាល័យកំពង់ស្ពឺ និងវិទ្យាល័យចាន់ថ្នាល ខណៈវិទ្យាល័យឱរ៉ាល់ មានគ្រូតែម្នាក់គត់ សម្រាប់មុខវិជ្ជាមួយនៃមុខវិជ្ជាទាំងពីរនេះ។ ចំពោះមុខវិជ្ជារូបវិទ្យាវិញ មានតែវិទ្យាល័យចាន់ថ្នាលទេ ដែលមានគ្រូរហូតដល់ ០៤រូប ចំណែកវិទ្យាល័យឱរ៉ាល់ មានគ្រូ ០១ រូប ហើយវិទ្យាល័យស្លាបលែងមាន ០២រូប។ មានតែវិទ្យាល័យកំពង់ស្ពឺទេ ដែលមានគ្រូ ០៣

រូបសម្រាប់ផែនដី និងបរិស្ថានវិទ្យា ចំណែកសាលាផ្សេងទៀតមានតែ ០១ ឬ ០២រូបប៉ុណ្ណោះ អាស្រ័យទៅតាមចំនួនសិស្ស។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ វិទ្យាល័យកំពង់ស្ពឺ និងវិទ្យាល័យចាន់ថ្នាល មានគ្រូបង្រៀនចំនួន ០៧រូបសម្រាប់មុខវិជ្ជាគណិតវិទ្យា ខណៈវិទ្យាល័យឱរ៉ាល់ មានគ្រូតែ ០២រូបប៉ុណ្ណោះសម្រាប់មុខវិជ្ជានេះ។ គ្រប់សាលាដែលបានជ្រើសរើសទាំងអស់មានគ្រូ ០២រូបសម្រាប់មុខវិជ្ជាកុំព្យូទ័រ លើកលែងតែវិទ្យាល័យឱរ៉ាល់ ដែលមិនមាន។

គ្រូបង្រៀនភាគច្រើនដែលបង្រៀនថ្នាក់ទី១០-១២ មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ខណៈគ្រូបង្រៀនមួយចំនួនតូចមានសញ្ញាបត្រកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ឬអនុបណ្ឌិត។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ វិទ្យាល័យកំពង់ស្ពឺ មានបុគ្គលិកចំនួន ០៧រូប ដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដែលក្នុងនោះមានប្រធានក្រុមបច្ចេកទេសគណិតវិទ្យា និងរូបវិទ្យា។ គ្រូបង្រៀននៅសាលាដែលបានជ្រើសរើស ភាគច្រើនមានបទពិសោធន៍យូរក្នុងការបង្រៀន ដែលជាមធ្យមមានច្រើនជាង ១០ឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយ វិក្រឹតការសុទ្ធតែនៅមានកម្រិតសម្រាប់សាលាទាំងនេះ។

**តារាង ៩៖** ចំនួនគ្រូបង្រៀនមុខវិជ្ជាទាក់ទងនឹងស្ទែម និងគុណវុឌ្ឍិរបស់គ្រូបង្រៀន

| គ្រូបង្រៀន | | វិទ្យាល័យ ឱរ៉ាល់ | វិទ្យាល័យ កំពង់ស្ពឺ | វិទ្យាល័យ ស្លាបលែង | វិទ្យាល័យ ចាន់ថ្នាល | វិទ្យាល័យ ទ័ពមានជ័យ |
|---|---|---|---|---|---|---|
| | | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន |
| ចំនួន គ្រូ បង្រៀន | ជីវវិទ្យា | ១ | ៤ | ២ | ៤ | ២ |
| | គីមីវិទ្យា | ១ | ៤ | ២ | ៤ | ៤ |
| | រូបវិទ្យា | ១ | ៣ | ២ | ៤ | ៣ |
| | ផែនដី និង បរិស្ថានវិទ្យា | ១ | ៣ | ២ | ២ | ២ |
| | គណិតវិទ្យា | ២ | ៧ | ៤ | ៧ | ៣ |
| | កុំព្យូទ័រ | ០ | ២ | ២ | ២ | ២ |
| គុណវុឌ្ឍិ ប្រធានក្រុម បច្ចេកទេស តាមមុខវិជ្ជា | ជីវវិទ្យា | ០ | ១ (បរិញ្ញាបត្រ) | ០ | ១ (បរិញ្ញាបត្រ) | ១ (បរិញ្ញាបត្រ) |
| | គីមីវិទ្យា | ០ | ១ (បរិញ្ញាបត្រ) | ០ | ១ (បរិញ្ញាបត្រ) | ១ (បរិញ្ញាបត្រ) |
| | រូបវិទ្យា | ០ | ១ (អនុបណ្ឌិត) | ០ | ១ (បរិញ្ញាបត្រ) | ១ (បរិញ្ញាបត្រ) |
| | ផែនដី និង បរិស្ថានវិទ្យា | ០ | ១ (បរិញ្ញាបត្រ) | ០ | ១ (បរិញ្ញាបត្រ) | ១ (បរិញ្ញាបត្រ) |
| | គណិតវិទ្យា | ១ (បរិញ្ញា+១) | ១ (អនុបណ្ឌិត) | ១ (បរិញ្ញាបត្រ) | ១ (បរិញ្ញាបត្រ) | ១ (អនុបណ្ឌិត) |
| | កុំព្យូទ័រ | ០ | ១ (បរិញ្ញាបត្រ) | ០ | ១ (បរិញ្ញាបត្រ) | ២ (បរិញ្ញាបត្រ) |

ដោយសារតែ អនុបាតសិស្ស-គ្រូខ្ពស់ និងបុគ្គលិកជាគ្រូបង្រៀនមានចំនួនតិច ដូច្នេះម៉ោងបង្រៀនក្នុងមួយសប្តាហ៍ សម្រាប់បុគ្គលិកជាគ្រូបង្រៀនមានចំនួនច្រើនខ្លាំង ហើយក្នុងករណីខ្លះ លើសពីការណែនាំរបស់ក្រសួងទៀតផង។ យើងបានរកឃើញថា ម៉ោងបង្រៀនជាមធ្យមសម្រាប់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅវិទ្យាល័យស្លាបលែង វិទ្យាល័យចាន់ថ្នាល និងវិទ្យាល័យទ័ពមានជ័យមាន ១៤ម៉ោងក្នុង

មួយសប្តាហ៍ នៅវិទ្យាល័យកំពង់ស្ពឺ ១៨ម៉ោងក្នុងមួយសប្តាហ៍ និងនៅវិទ្យាល័យឱរ៉ាល់ ២៥ម៉ោងក្នុងមួយសប្តាហ៍។ យើងក៏រកឃើញថា ៦% នៃគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅវិទ្យាល័យកំពង់ស្ពឺ បង្រៀនរហូតដល់ ២៩ម៉ោងក្នុងមួយសប្តាហ៍ (តារាងទី១០)។ ដោយបូកបញ្ចូលកាតព្វកិច្ចផ្សេងទៀត ដូចជាការរៀបចំផែនការមេរៀន ការប្រជុំក្រុមបច្ចេកទេស និងសកម្មភាពផ្សេងទៀតទាក់ទងនឹងសាលា បន្ទុកការងាររបស់គ្រូបង្រៀននៅវិទ្យាល័យទាំងនោះ មានកម្រិតធ្ងន់ខ្លាំង។

**តារាងទី ១០៖** បន្ទុកការងាររបស់គ្រូបង្រៀន

| អថេរ | | វិទ្យាល័យ ឱរ៉ាល់ | វិទ្យាល័យ កំពង់ស្ពឺ | វិទ្យាល័យ ស្លាបលែង | វិទ្យាល័យ ចាន់ថ្មាល | វិទ្យាល័យ ទំពមានជ័យ |
|---|---|---|---|---|---|---|
| ការបង្រៀនក្នុងមួយសប្តាហ៍ | មធ្យម (ម៉ោង) | ២៥,២៧២៧៣ | ១៨ | ១៤ | ១៤ | ១៤,៥៧១៤៣ |
| | អប្បបរមា (ម៉ោង) | ២៣ | ១៦ | ៦ | ១២ | ៩ |
| | អតិបរមា (ម៉ោង) | ២៨ | ២៩ | ២០ | ១៦ | ១៨ |

## ៣.៧. ចំណេះដឹង និងជំនាញរបស់គ្រូបង្រៀន

ចំពោះគរុកោសល្យវិញ ការបង្រៀនមុខវិជ្ជាស្ទែមនៅតែជាបញ្ហា។ នៅកម្រិតម៉ាក្រូ ឬគោលនយោបាយ បញ្ហាប្រឈម គឺរវាងការរៀនដែលផ្តោតលើសិស្ស និងការរៀនដែលផ្តោតលើគ្រូ។ នៅក្នុងវិធីសាស្ត្រការអប់រំស្ទែម វិធីសាស្ត្របង្រៀនដូចជា គំរូ 5Es វិធីសាស្ត្រវិទ្យាសាស្ត្រ ការសិក្សាតាមបែបរិះរក (IBL) ការបង្រៀនផ្អែកលើទស្សនាទាន ការបង្រៀនផ្អែកលើគម្រោង និងការបង្រៀនតាមបែបដោះស្រាយបញ្ហា គឺជាគន្លឹះសម្រាប់ភាពជោគជ័យនៃការអនុវត្តការអប់រំស្ទែម ដែលក្នុងនោះវិធីសាស្ត្ររៀនដែលផ្តោតលើសិស្ស ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងថ្នាក់រៀន។ វិធីសាស្ត្រនេះនឹងជួយផ្លាស់ប្តូរពី ការបង្រៀនផ្អែកលើខ្លឹមសារ ដែលពឹងផ្អែកលើវិធីសាស្ត្ររៀនដែលផ្តោតលើគ្រូ ទៅជាការបង្រៀនផ្អែកលើសមត្ថភាព ដែលផ្តោតជាមូលដ្ឋានលើលទ្ធផលដែលអាចកំណត់បានក្នុងទិដ្ឋភាព ៣ គឺចំណេះដឹង ជំនាញ និងអាកប្បកិរិយា ដែលពឹងផ្អែកលើការរៀនដែលផ្តោតលើសិស្ស។

នៅក្នុងការស្រាវជ្រាវនេះ រង្វាស់ខ្នាត Likert ៥កម្រិត ត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃទៅលើចំណេះដឹង និងជំនាញរបស់គ្រូបង្រៀនមុខវិជ្ជាស្ទែមទាក់ទងនឹងវិធីសាស្ត្រ/អភិក្រមទាំងនោះ។ ខាងក្រោមនេះជាសេចក្តីសង្ខេបនៃអ្វីដែលលោកគ្រូ-អ្នកគ្រូរៀបរាប់អំពីចំណេះដឹង និងជំនាញរបស់ពួកគាត់ទាក់ទងនឹងមុខវិជ្ជាស្ទែម ព្រមទាំង ការបង្រៀន និងរៀនបែបស្ទែម៖

- គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រទាំងអស់ អះអាងថាមានចំណេះដឹងច្រើនអំពីមេរៀនដែលពួកគាត់បង្រៀន។

- គ្រូបង្រៀនភាគច្រើន មានការយល់ដឹងពី មធ្យម ទៅច្រើន អំពីសិស្សដែលពួកគាត់បង្រៀន និងជំនាញគ្រប់គ្រងថ្នាក់រៀន។
- គ្រូបង្រៀន អះអាងថា ពួកគាត់មានជំនាញមធ្យម ក្នុងការរៀបចំផែនការមេរៀន។
- គ្រូបង្រៀនភាគច្រើន អះអាងថាពួកគាត់មានយុទ្ធសាស្ត្រល្អក្នុងការបង្រៀនសិស្សឱ្យក្លាយជាអ្នកសិក្សាឯករាជ្យ។

យ៉ាងណាក៏ដោយ ការស្រាវជ្រាវបានរកឃើញថា គ្រូបង្រៀនភាគច្រើនមានជំនាញពីកម្រិតទាបទៅមធ្យម នៅក្នុងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ជាពិសេស ការប្រើប្រាស់អ៊ីនធឺណិត) ភាសាអង់គ្លេស ការសិក្សាផ្អែកលើគម្រោង ការបង្កើតសកម្មភាពនវានុវត្តន៍នានាសម្រាប់សិស្ស ការប្រើប្រាស់កម្មវិធីសិក្សា ការប្រឹក្សាយោបល់ ការអភិវឌ្ឍសម្ភារបង្រៀន ការសរសេរអត្ថបទ និងជំនាញបន្ទប់ពិសោធន៍។

ទោះបីជា គ្រូបង្រៀនអះអាងថា ពួកគាត់ដឹងអំពីវិធីសាស្ត្របង្រៀន និងរៀនទាំងនេះ ប៉ុន្តែនៅក្នុងការអនុវត្ត ពួកគាត់មិនធ្លាប់បានធ្វើវានោះទេ ដោយសារតែកង្វះសម្ភារបង្រៀន និងរៀនសមរម្យ ក៏ដូចជាបន្ទប់ពិសោធន៍ ដែលគាំទ្រដល់ការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនថ្មីៗទាំងនោះ។ កត្តាផ្សេងៗទៀតរាប់បញ្ចូលទាំងអវត្តមានវប្បធម៌ដ៏រឹងមាំរបស់សាលារៀន ដើម្បីឱ្យមានការបង្រៀន ការរៀន និងការវាយតម្លៃដែលលើកកម្ពស់ដល់ការអប់រំស្នែម និងការគ្រប់គ្រងសាលាដែលមានលក្ខណៈគាំទ្រ សំដៅលើកកម្ពស់បរិយាកាសធ្វើការឱ្យមានភាពសកម្ម ដែលទាំងនេះគឺសុទ្ធសឹងតែជាឧបសគ្គសម្រាប់គ្រូបង្រៀនក្នុងការបង្កើនចំណេះដឹង និងជំនាញលើការបង្រៀនស្នែម និងប្រើវាក្នុងការអនុវត្តប្រចាំថ្ងៃនៅក្នុងថ្នាក់រៀន។ ហេតុដូច្នេះ លទ្ធផលនៃការសិក្សាខាងលើដែលទទួលបានពីគ្រូបង្រៀន ហាក់បីដូចជាបង្ហាញថា គ្រូបង្រៀនត្រូវការការបំពាក់បំប៉នបន្ថែមអំពីរបៀបប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មីៗដូចជា ការបង្រៀនតាមបែបរិះរក ការបង្រៀនផ្អែកលើគម្រោង ព្រមទាំងរបៀបអនុវត្តសកម្មភាពផ្អែកលើបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងការធ្វើពិសោធន៍ នៅក្នុងការបង្រៀន និងរៀនប្រចាំថ្ងៃ។

## ៣.៨. កម្មវិធីសិក្សា

កម្មវិធីសិក្សានៅក្នុងសាលាដែលបានជ្រើសរើសទាំងអស់នៅក្នុងខេត្តកំពង់ស្ពឺ បានអនុលោមទៅតាមក្របខ័ណ្ឌគោលនយោបាយកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ដូចដែលបានបង្ហាញនៅក្នុងតារាងទី១១។ ក្នុងនោះយើងឃើញមានចរន្តចំនួន ០២ គឺចរន្តវិទ្យាសាស្ត្រពិត និងចរន្តវិទ្យាសាស្ត្រសង្គម ហើយខ្លឹមសារដែលបង្រៀនក្នុងចរន្តទាំង ២ គឺខុសគ្នា។ ចរន្តវិទ្យាសាស្ត្រពិត មានកម្រិតខ្ពស់ជាងចរន្តវិទ្យាសាស្ត្រសង្គមផ្នែកការអប់រំស្នែម ប៉ុន្តែចរន្តទាំង ០២ អនុលោមទៅតាមសៀវភៅសិក្សាគោលដែលបានអភិវឌ្ឍដោយក្រសួងតែមួយ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នៅក្នុងចំណោមសាលាទាំង០៥ នោះគឺ មានតែវិទ្យាល័យកំពង់ស្ពឺប៉ុណ្ណោះ ដែលមានថ្នាក់វិទ្យាសាស្ត្រពិសេស (ថ្នាក់ទី១២ មួយថ្នាក់) សម្រាប់សិស្សដែលមានទេពកោសល្យដើម្បីត្រៀមយកនិទ្ទេស A នៅក្នុងការប្រឡងថ្នាក់ជាតិ។ ក្រុមសិស្សទាំង

នេះមានសក្តានុពលក្នុងការផ្ទេរទៅក្នុងថ្នាក់អប់រំស្នែមនៅពេលអនាគត ដែលនឹងត្រូវពិភាក្សាបន្ថែមនៅក្នុងផ្នែកអនុសាសន៍ផ្នែកខាងក្រោម។

ក្រៅពីកម្មវិធីសិក្សាដែលកំពុងដាក់អនុវត្តបច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍកម្មវិធីសិក្សាថ្មីក្នុងឆ្នាំ២០១៥ ដើម្បីបំពាក់បំប៉នសិស្សជាមួយនឹងចំណេះដឹង ជំនាញ និងអាកប្បកិរិយា ដើម្បីទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ និងការសិក្សាបន្ថែម។ សំខាន់ជាងនេះទៅទៀត ក្របខ័ណ្ឌកម្មវិធីសិក្សាថ្មីនេះ មានគោលបំណងកែលម្អគុណភាពអប់រំ ដើម្បីឆ្លើយតបទៅនឹងពិភពលោកដែលកំពុងផ្លាស់ប្តូរ រួមទាំងតម្រូវការនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានគោលបំណងជំរុញប្រទេសកម្ពុជា ឱ្យក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ក្របខ័ណ្ឌកម្មវិធីសិក្សាថ្មី ក៏បានកំណត់បរិបទថ្មី សម្រាប់ឱ្យក្រសួងអប់រំ យុវជន និងកីឡា ផ្តោតលើគុណភាព និងភាពពាក់ព័ន្ធនៃការអប់រំដែលផ្តល់ឱ្យសិស្ស ដើម្បីធានាថាមានកម្លាំងពលកម្មដែលមានសមត្ថភាពគ្រប់គ្រាន់សម្រាប់បម្រើឱ្យកំណើនសេដ្ឋកិច្ច និងដើម្បីពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់ខ្លួនដើម្បីត្រៀមខ្លួនចូលទៅកាន់ទីផ្សារសាកល។ នេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ តាមរយៈការបន្ថែមម៉ោងបង្រៀនសម្រាប់មុខវិជ្ជាស្នូលដូចជា អក្សរសាស្ត្រខ្មែរ គណិតវិទ្យា រូបវិទ្យា និងភាសាបរទេស ដើម្បីកសាងមូលដ្ឋានគ្រឹះនៃការអប់រំស្នែម។ យ៉ាងណាក្តី កម្មវិធីសិក្សាថ្មីនេះនៅមិនទាន់ត្រូវបានអនុវត្តនៅកម្រិតសាលានៅឡើយទេ។

**តារាងទី ១១៖** កម្មវិធីសិក្សាថ្នាក់ទី១០-១២

| ចំនួន | មុខវិជ្ជា | កម្មវិធីសិក្សាថ្មី (ថ្នាក់ទី ១០-១២) | កម្មវិធីសិក្សាបច្ចុប្បន្ន (ថ្នាក់ទី ១០-១២) |
|---|---|---|---|
| ១ | អក្សរសាស្ត្រខ្មែរ | ៥ | ៣ |
| ២ | គណិតវិទ្យា | ៦ | ៥ |
| ៣ | ភាសាបរទេស | ៦ | ២ |
| ៤ | អប់រំកាយ និងកីឡា | ២ | ១ |
| ៥ | គេហវិទ្យា | ១ | ២ |
| ៦ | រូបវិទ្យា | ៤ | ៣ |
| ៧ | ផែនដី និងបរិស្ថានវិទ្យា | ២ | ២ |
| ៨ | គីមីវិទ្យា | ៣ | ៣ |
| ៩ | ជីវវិទ្យា | ៣ | ៣ |
| ១០ | ប្រវត្តិវិទ្យា | ២ | ២ |
| ១១ | ភូមិវិទ្យា | ២ | ២ |
| ១២ | សីលធម៌-ពលរដ្ឋ | ២ | ២ |
| ១៣ | បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន | ១ | ០ |
| ១៤ | អប់រំសុខភាព | ១ | ០ |
| ១៥ | អប់រំបច្ចេកទេស (មុខវិជ្ជាជម្រើស) | ០ | ២ |
| **ម៉ោងសរុបប្រចាំសប្តាហ៍** | | **៤០** | **៣២** |

## ៤. គំរូវិទ្យាល័យស្ទែម

ចំពោះកម្មវិធីសិក្សា គំរូវិទ្យាល័យស្ទែម ដែលបានស្នើឡើងនេះ គឺអនុលោមទៅតាមក្របខ័ណ្ឌកម្មវិធីសិក្សាថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការអប់រំចំណេះទូទៅ និងការអប់រំបច្ចេកទេស ដែលបានបង្កើតឡើងក្នុងឆ្នាំ២០១៥ ដែលជាទិសដៅដ៏ត្រឹមត្រូវមួយ ដូចបានរៀបរាប់ខាងលើ។ វិធីសាស្ត្រសម្រាប់ការអនុវត្តកម្មវិធីសិក្សាស្ទែម ដែលបានស្នើឡើងនេះ ត្រូវបានឱ្យឈ្មោះថា វិធីសាស្ត្រការអប់រំស្ទែមបែបរួមបញ្ចូល ហើយវាផ្តោតលើវិធីសាស្ត្រ និងខ្លឹមសារបង្រៀន និងរៀន។ លើសពីនេះ ខ្លឹមសារនៃវិធីសាស្ត្រទាំងនេះ គឺជាការរួមបញ្ចូលការអប់រំស្ទែម ជាពិសេសខ្លឹមសារ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដោយផ្អែកលើបរិបទក្នុងស្រុក និងធនធានដែលអាចរកបាន ទៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា។ យ៉ាងណាក៏ដោយ វាមានសារៈសំខាន់ ក្នុងការកត់សម្គាល់ថាគំរូដែលបានស្នើឡើងនេះ រក្សាការបែងចែកមុខវិជ្ជា និងម៉ោងសិក្សាឱ្យបានគ្រប់គ្រាន់ ដូចមានបង្ហាញក្នុងតារាងទី១២។

**តារាងទី១២៖** ការបែងចែកមុខវិជ្ជា និងម៉ោងសិក្សា (ថ្នាក់ទី១០-១២)

| ចំនួន | មុខវិជ្ជា | កម្មវិធីសិក្សាថ្មី (ថ្នាក់ទី ១០-១២) | កម្មវិធីសិក្សាបច្ចុប្បន្ន (ថ្នាក់ទី ១០-១២) |
|---|---|---|---|
| ១ | អក្សរសាស្ត្រខ្មែរ | ៤ | ៣ |
| ២ | គណិតវិទ្យា | ៦ | ៥ |
| ៣ | ភាសាបរទេស | ៦ | ២ |
| ៤ | អប់រំកាយ និងកីឡា | ២ | ១ |
| ៥ | គេហវិទ្យា | ១ | ២ |
| ៦ | រូបវិទ្យា | ៥ | ៣ |
| ៧ | ផែនដី និងបរិស្ថានវិទ្យា | ២ | ២ |
| ៨ | គីមីវិទ្យា | ៣ | ៣ |
| ៩ | ជីវវិទ្យា | ៣ | ៣ |
| ១០ | ប្រវត្តិវិទ្យា | ២ | ២ |
| ១១ | ភូមិវិទ្យា | ២ | ២ |
| ១២ | សីលធម៌-ពលរដ្ឋ | ២ | ២ |
| ១៣ | បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន | ១ | ០ |
| ១៤ | អប់រំសុខភាព | ១ | ០ |
| ១៥ | អប់រំបច្ចេកទេស (មុខវិជ្ជាជម្រើស) | ០ | ២ |
| **ម៉ោងសរុបប្រចាំសប្តាហ៍** | | **៤០** | **៣២** |

<u>**ចំណាំ៖**</u> *ផែនការម៉ោងសិក្សាដែលបានស្នើឡើងនេះ គឺមានចំនួន ៦ថ្ងៃ ក្នុងមួយសប្តាហ៍ ហើយម៉ោងសិក្សាក្នុងមួយថ្ងៃមានចន្លោះពី ៤-៧ ម៉ោង ដោយម៉ោងសិក្សានីមួយៗ មានរយៈពេល ៥០នាទី។*

ក្នុងការស្វែងរកគំរូសមស្របមួយប្រកបដោយស័ក្តិសិទ្ធិភាពផ្នែកចំណាយ និងប្រសិទ្ធភាពចំណាយ ដោយមិនផ្តោតតែលើការធ្វើឱ្យប្រសើរឡើងខាងផ្នែកចំណេះដឹង និងការយល់ដឹងផ្នែកស្ទែមទេ ប៉ុន្តែក៏ផ្សារភ្ជាប់ការអប់រំស្ទែម ទៅនឹងបរិបទក្នុងស្រុក និងការដោះស្រាយបញ្ហាក្នុងស្រុក ព្រមទាំងនិន្នាការសាកលផងដែរ ដោយគំរូអប់រំស្ទែមដែលបានស្នើឡើងនេះ នឹងផ្តោតលើការផ្លាស់ប្តូរវិធីសាស្ត្របង្រៀន និងរៀន ដើម្បីផ្សារភ្ជាប់ការបង្រៀន និងរៀនអំពីស្ទែម ទៅនឹងជីវិតប្រចាំថ្ងៃ និងនវានុវត្តន៍ក្នុងវិស័យឧស្សាហកម្មនាពេលអនាគត។ ក្នុងន័យនេះ គំរូអប់រំថ្មីនេះ នឹងសង្កត់ធ្ងន់លើ គំរូអប់រំផ្អែកលើគម្រោង និងការពិសោធន៍ទាំងនៅក្នុង និងក្រៅថ្នាក់រៀន ដែលអនុញ្ញាតឱ្យសិស្សធ្វើការលើកិច្ចការដែលបានដាក់ដោយគ្រូ ឬដោយការរិះរកខ្លួនឯងផ្ទាល់ តាមរយៈការដោះស្រាយបញ្ហា ឬគម្រោងដែលពួកគេចាប់អារម្មណ៍ ស្របពេលជាមួយគ្នានេះ សិស្សនឹងត្រូវបានបង្រៀនដោយប្រើវិធីសាស្ត្រ រួមបញ្ចូលការប្រើប្រាស់បច្ចេកវិទ្យា ដែលបម្រើឱ្យការអប់រំនៅក្នុងដំណើរការនៃការសិក្សារបស់ពួកគេ។

ដើម្បីអនុវត្តគំរូថ្មីដែលបានស្នើឡើងនេះ វិធីសាស្ត្រអប់រំស្ទែមចំនួន ០៣ ត្រូវបានដាក់បញ្ចូល ក្នុងនោះរួមមាន វិធីសាស្ត្រអន្តរវិស័យ វិធីសាស្ត្រពហុវិស័យ និងវិធីសាស្ត្រឆ្លងវិស័យ ជាមួយនឹងយុទ្ធសាស្ត្របង្រៀនចំនួន ០៣ ដូចជា៖ ១). យុទ្ធសាស្ត្រសិក្សាតាមបែបរិះរក[9] ២). យុទ្ធសាស្ត្រសិក្សាតាមបែបដោះស្រាយបញ្ហា[10] ៣). យុទ្ធសាស្ត្រសិក្សាផ្អែកលើគម្រោង[11] ដើម្បីសម្រេចបានលទ្ធផលសិក្សាដូចបានបង្ហាញក្នុងតារាងទី១៣។

[9] ការសិក្សាជាមួយចម្ងល់ និងបញ្ហា និងបន្ទាប់មកទាក់ទាញអ្នកសិក្សារៀនសូត្រក្នុងការកសាងចំណេះដឹង និងការយល់ដឹងថ្មីៗ។

[10] បញ្ហាកើតឡើងជាក់ស្តែង ត្រូវបានប្រើប្រាស់ជាយានក្នុងការលើកម្ពស់ការរៀនសូត្ររបស់សិស្សទៅលើបញ្ញត្តិ និងគោលការណ៍។

[11] សិស្សធ្វើការសិក្សាទៅលើគម្រោងក្នុងរយៈពេលកំណត់មួយ ដែលការសិក្សានេះអាចទាញការចាប់អារម្មណ៍របស់ពួកគេក្នុងការដោះស្រាយបញ្ហាជាក់ស្តែង។

## តារាងទី១៣៖ យុទ្ធសាស្រ្ត និងលទ្ធផលសិក្សា

| ខ្លឹមសារ | យុទ្ធសាស្រ្តសិក្សាស្ទែម | លទ្ធផលសិក្សា |
|---|---|---|
| ៦០% សម្រាប់ការបង្រៀន មុខវិជ្ជាវិទ្យាសាស្រ្ត និងគណិតវិទ្យាជាការរិះរកតាមបែបវិទ្យាសាស្រ្ត | យុទ្ធសាស្រ្តសិក្សាតាមបែបរិះរក ឬការសិក្សាផ្អែកលើការពិសោធន៍ [ប្រើវិធីសាស្រ្តសិក្សាលាយបញ្ចូលគ្នា] | ចំណេះដឹងវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងការធ្វើ<br><br>ជំនាញទទួលបាន ដែលឆ្លើយតបទៅនឹងតម្រូវការសង្គម និងក្លាយជាពលរដ្ឋសតវត្សរ៍ទី ២១ និងលើសពីនេះ |
| ១០% សម្រាប់ការបង្រៀនមុខវិជ្ជាវិទ្យាសាស្រ្ត និងគណិត វិទ្យា ជាមុខវិជ្ជារួមបញ្ចូលគ្នារួមទាំងខ្លឹមសារវិស្វកម្ម និង បច្ចេកវិទ្យា | - យុទ្ធសាស្រ្តសិក្សាតាមបែបរិះរក<br>- យុទ្ធសាស្រ្តសិក្សាផ្អែកលើគម្រោង | ចំណេះដឹងខ្លឹមសារ<br><br>ប្រធានបទអន្តរវិស័យនៃសតវត្សរ៍ទី ២១<br><br>ចំណេះដឹងបែបអនុវត្តន៍<br><br>ជំនាញសតវត្សរ៍ទី ២១ |
| ១០% សម្រាប់ការអប់រំ ផ្អែកលើការពិសោធន៍ | យុទ្ធសាស្រ្តសិក្សាតាមបែបរិះរក ដែលមានការបញ្ចូលគ្នារវាងវិន័យ និងរចនាសម្ព័ន្ធ ធនធានមនុស្ស និងសម្ភារបរិក្ខារនានា ត្រូវបានរៀបចំឡើង | - ចំណេះដឹង ត្រូវបានបណ្តុះបណ្តាលក្នុងគោលបំណងដោះស្រាយបញ្ហាជាក់លាក់ណាមួយដែលកើតឡើងនៅក្នុងមូលដ្ឋាន ឬសហគមន៍<br>- ជំនាញត្រូវបានបំពាក់បំប៉ន តាមរយៈការសហការគ្នា ការប្រាស្រ័យទាក់ទងគ្នា ការត្រិះរិះពិចារណា ការងារជាក្រុម និងការស្រាវជ្រាវ<br>- ឥរិយាបថត្រូវបានអប់រំតាមរយៈការស្រឡាញ់ ការចង់ចេះចង់យល់ ប្រព័ន្ធដែលបានកសាងរួច (built-system) ការគោរព សុជីវធម៌ និងសីលធម៌ |
| ២០% សម្រាប់សកម្មភាពក្រៅកម្មវិធីសិក្សា៖<br>- ពិព័រណ៍វិទ្យាសាស្រ្ត<br>-ទស្សនកិច្ចសិក្សាតាមរោងចក្រឧស្សាហកម្ម<br>- កម្មវិធីសមធម៌<br>- ការប្រកួតប្រជែងផ្នែកវិទ្យាសាស្រ្ត<br>- កម្មវិធីហាត់ការ<br>- ពានរង្វាន់ឧត្តមភាពស្ទែម<br>- ការរៀនសូត្របែបស្វ័យដឹកនាំ<br>- ក្លឹបសិក្សា<br>-គម្រោងសហគ្រិន ឬបញ្ហា/ដំណោះស្រាយក្នុងស្រុក, គម្រោងតម្រង់ទិសផ្អែកលើឧស្សាហកម្ម | -យុទ្ធសាស្រ្តសិក្សាតាមបែបដោះស្រាយបញ្ហា<br>- យុទ្ធសាស្រ្តសិក្សាផ្អែកលើគម្រោង<br>- កម្មវិធីផ្សព្វផ្សាយ<br>- សាបព្រោះសិល្បៈសេរី | ចំណេះដឹងខ្លឹមសារ<br><br>ប្រធានបទអន្តរវិស័យនៃសតវត្សរ៍ទី ២១<br><br>ចំណេះដឹងបែបអនុវត្តន៍<br><br>ជំនាញសតវត្សរ៍ទី ២១ |

ការអនុវត្តយុទ្ធសាស្ត្របង្រៀន និងរៀនខុសៗគ្នាទាំងនេះ ត្រូវបានហៅថា វិធីសាស្ត្រអប់រំស្ទែមបែបរួមបញ្ចូល ដែលសកម្មភាពទាំងឡាយ ត្រូវបានផ្សារភ្ជាប់ទៅនឹងខ្លឹមសារពហុវិស័យ និងជីវិតប្រចាំថ្ងៃ។ វាផ្តោតលើជំនាញសតវត្សរ៍ទី ២១ និងការប្រើប្រាស់វិធីសាស្ត្របែបវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការបង្រៀន និងរៀន។ ចំណុចស្នូលនៃវិធីសាស្ត្រអប់រំស្ទែមបែបរួមបញ្ចូលនេះ គឺយុទ្ធសាស្ត្រសិក្សាតាមបែបរិះរក ដែលត្រូវបានកំណត់ក្នុងរូបភាពទី៤។ ដូចដែលបានរៀបរាប់នៅផ្នែកមុន ប្រហែល ៣០% នៃសហគ្រាសធុនតូច និងមធ្យមក្នុងខេត្តកំពង់ស្ពឺ ត្រូវការកម្លាំងពលកម្មដែលផ្អែកលើស្ទែមក្នុងជំនាញផ្នែកវិស្វកម្ម និងវិទ្យាសាស្ត្រ រួមទាំងសំណង់ បច្ចេកវិទ្យាវេចខ្ចប់ សម្ភារវិទ្យាសាស្ត្រ ការកែច្នៃចំណីអាហារ អគ្គិសនី អេឡិចត្រូនិក និងវិស្វកម្មមេកានិច។ ឧស្សាហកម្មទាំងនេះ មានភាពទាក់ទងយ៉ាងខ្លាំងទៅនឹងជំនាញគណិតវិទ្យា និងរូបវិទ្យា។ ដូច្នេះ ចំនួនកាន់តែច្រើននៃការសិក្សាផ្អែកលើគម្រោងនឹងត្រូវបានផ្សារភ្ជាប់ទៅនឹងរូបវិទ្យាអនុវត្តន៍ ជាងគីមីវិទ្យា និងជីវវិទ្យាអនុវត្តន៍។




**រូបភាពទី៤៖** ការបង្ហាញអំពីដំណើរការនៃសកម្មភាពបែបរិះរក ត្រូវបានបញ្ចូលគ្នាឱ្យទៅជាដំណាក់កាលទាំង០៥នៃការរិះរកទូទៅ (Margus Pedaste et al., 2015)

ផ្អែកលើគំនូសបំព្រួញខាងលើ ទោះបីជាវិធីសាស្ត្រអប់រំស្ទែមបែបរួមបញ្ចូល មិនតម្រូវឱ្យមានការផ្លាស់ប្តូរកម្មវិធីសិក្សាច្រើនក៏ដោយ ក៏គំរូនេះចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើសកម្មភាពគន្លឹះៗ ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព ក៏ដូចជាធានាថាគំរូនេះបានបន្ថែមគុណតម្លៃទៅលើគំរូសាលាស្ទែមផ្សេងទៀតដែលមានស្រាប់នៅកម្ពុជា។ ក្នុងនោះរួមមានៈ

- កម្មវិធីសិក្សាទាំងមូល លើកកម្ពស់គំរូនៃការអប់រំផ្អែកលើការពិសោធន៍ ដែលទាមទារឱ្យសិស្សធ្វើការដោយផ្ទាល់លើបញ្ហាក្នុងស្រុក ឬគម្រោងស្ទែមដែលផ្សារភ្ជាប់ទៅនឹងជីវិតប្រចាំថ្ងៃ ឬការអនុវត្តក្នុងឧស្សាហកម្មដែលមានសក្តានុពល (ឧ. ជំនាញបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដូចជាការសរសេរកូដកុំព្យូទ័រ ការបង្កើតគេហទំព័រ/កម្មវិធីទូរសព្ទ ការរចនាក្រាហ្វិក/ឌីជីថល ការកែច្នៃចំណីអាហារ ជំនាញកសិកម្ម បច្ចេកវិទ្យាវេចខ្ចប់ ឬអគ្គិសនី អេឡិចត្រូនិក និងការរចនាវិស្វកម្មមេកានិច);
- ការបង្រៀនផ្តោតលើសកម្មភាពដោះស្រាយបញ្ហា តាមបែបរិះរក និងផ្អែកលើគម្រោង;
- ការរៀនសូត្របែបស្វ័យដឹកនាំ រួមជាមួយក្លឹបសិក្សាស្ទែម ត្រូវបានលើកកម្ពស់ជាសកម្មភាពក្រៅកម្មវិធីសិក្សា;
- របៀបក្នុងការវាយតម្លៃសិស្ស ត្រូវអនុវត្តតាមវិធីសាស្ត្រផ្សេងៗគ្នា។ ជាមូលដ្ឋាន ការវាយតម្លៃផ្អែកលើការសិក្សារបស់សិស្ស គឺត្រូវអនុវត្តទន្ទឹមគ្នានឹងការវាយតម្លៃលទ្ធផលបញ្ចប់ការសិក្សា (Summative Assesment) ដែលត្រូវបានបង្កើតឡើងសម្រាប់ជំនាញក្នុងការគិតកម្រិតខ្ពស់ ដោយប្រើវិធីសាស្ត្រ Bloom's Taxonomy កម្រិតទី៣ ឬខ្ពស់ជាងនេះ នៅក្នុងការរៀបចំការសិក្សាប្រចាំថ្ងៃ;
- ព្រឹត្តិការណ៍ ឬការប្រកួតប្រជែងផ្អែកលើស្ទែមនៅតាមសាលារៀន ត្រូវបានបង្កើតឡើង;
- ការធ្វើស្ថាប័ននីយកម្មលើគម្រោងស្ទែមដែលរៀបចំដោយសិស្សផ្ទាល់ ដោយមានការត្រួតពិនិត្យពីគ្រូបង្រៀន និង/ឬនិស្សិតបញ្ចប់ការសិក្សាស្ទែម ដើម្បីរកចំណូលដល់សាលា។

ដើម្បីអនុវត្តវិធីសាស្ត្រអប់រំស្ទែមបែបរួមបញ្ចូលនេះប្រកបដោយស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព ក្រុមស្រាវជ្រាវបានស្នើឱ្យមានគោលការណ៍ណែនាំទាក់ទងនឹងធនធានរូបវន្តនិងធនធានមនុស្ស និងអង្គការស្ថាប័ន ទាក់ទងទៅនឹងអភិបាលកិច្ច និងការគ្រប់គ្រង។

## ៤.១. គ្រូបង្រៀនស្ទែម គុណវុឌ្ឍិ និងទំហំការងាររបស់គ្រូបង្រៀន

**តារាងទី១៤៖** អនុបាតសិស្ស-គ្រូ និងគុណវុឌ្ឍិរបស់គ្រូបង្រៀនតាមមុខវិជ្ជា (ថ្នាក់ទី១០-១២)

| គ្រូបង្រៀន | | អនុបាតសិស្ស/គ្រូ | បរិយាយ |
|---|---|---|---|
| មុខវិជ្ជាស្ទែម | ជីវវិទ្យា | ៣០:១ | តាមរយៈធនធានដែលមានស្រាប់ទាំងសម្ភារបរិក្ខារ និងធនធានមនុស្សបាននាំឱ្យវិធីសាស្ត្រនេះត្រូវកំណត់អនុបាត សិស្ស-គ្រូ ត្រឹម៣០:១។ ជាគោលការណ៍ សាលាអាចបត់បែនទៅតាមកាលៈទេសៈដើម្បីកាត់បន្ថយចំនួនសិស្សត្រឹមក្នុងរង្វង់ ១៦ នាក់ សម្រាប់ករណីល្អបំផុត។ ជាមួយនឹងសិស្សចំនួន ៣០ នាក់ ក្នុងមួយថ្នាក់ គ្រូបង្រៀនអាចបែងចែកសិស្សដើម្បីធ្វើការងារជាក្រុម អនុវត្តមេរៀននៅក្នុងថ្នាក់រៀន សិក្សាផ្អែកលើគម្រោង និងសកម្មភាពផ្សេងៗទៀត។ |
| | គីមីវិទ្យា | ៣០:១ | |
| | រូបវិទ្យា | ៣០:១ | |
| | ផែនដី និង បរិស្ថានវិទ្យា | ៣០:១ | |
| | គណិតវិទ្យា | ៣០:១ | |
| | កុំព្យូទ័រ | ៣០:១ | |
| **គ្រូបង្រៀន** | | **គុណវុឌ្ឍិ** | **បរិយាយ** |
| មុខវិជ្ជាស្ទែម | ជីវវិទ្យា | បរិញ្ញាបត្រជីវវិទ្យា + ១ | គ្រូបង្រៀនស្ទែម ត្រូវមានគុណវុឌ្ឍិអប្បបរមាត្រឹមកម្រិតបរិញ្ញាបត្រវិទ្យាសាស្ត្រក្នុងជំនាញដែលពាក់ព័ន្ធនឹងស្ទែម បូករួមនឹងសញ្ញាបត្រគរុកោសល្យ (វ.ជ.អ.) ហើយត្រូវចូលរួមក្នុងការអភិវឌ្ឍជំនាញវិជ្ជាជីវៈជាប្រចាំលើចំណេះដឹងខ្លឹមសារ និងវិធីសាស្ត្រការបង្រៀនថ្មីៗដូចជា វិធីសាស្ត្រតាមបែបរិះរកវិធីសាស្ត្រ ដោះស្រាយបញ្ហាវិធីសាស្ត្រ ផ្អែកលើគម្រោង ការសិក្សាផ្អែកលើការពិសោធន៍ ការគ្រប់គ្រងថ្នាក់រៀន និងការបន្តកសាងសមត្ថភាព ស្វែងដឹងអំពីតម្រូវការបច្ចេកវិទ្យានាពេលអនាគត។ |
| | គីមីវិទ្យា | បរិញ្ញាបត្រគីមីវិទ្យា + ១ | |
| | រូបវិទ្យា | បរិញ្ញាបត្ររូបវិទ្យា + ១ | |
| | ផែនដី និង បរិស្ថានវិទ្យា | បរិញ្ញាបត្រផែនដីវិទ្យា/ រូបវិទ្យា/ភូមិវិទ្យា + ១ | |
| | គណិតវិទ្យា | បរិញ្ញាបត្រគណិតវិទ្យា + ១ | |
| | កុំព្យូទ័រ | បរិញ្ញាបត្រវិទ្យាសាស្ត្រកុំព្យូទ័រ/ បច្ចេកវិទ្យាព័ត៌មាន-វិស្វកម្ម + ១ | |

**តារាងទី១៥៖** ទំហំការងាររបស់គ្រូបង្រៀន (ថ្នាក់ទី១០-១២)

| ទំហំការងាររបស់គ្រូបង្រៀន | ចំនួនម៉ោងក្នុងមួយសប្តាហ៍ | បរិយាយ |
|---|---|---|
| ការបង្រៀន | ១៥-១៨ | បង្រៀន ៣ ម៉ោងក្នុងមួយថ្ងៃ |
| ការរៀបចំការបង្រៀន និងសម្ភារសិក្សា | ១០-១២ | រៀបចំការបង្រៀន និងសម្ភារសិក្សា ២ ម៉ោងក្នុងមួយថ្ងៃ |
| ការអភិវឌ្ឍផ្តោតខ្លឹមសារ និងការអភិវឌ្ឍជំនាញពិសោធន៍ | ៥-៦ | ការអភិវឌ្ឍខ្លួន៖ ចំណេះដឹងខ្លឹមសារ ជំនាញពិសោធន៍ និងការស្រាវជ្រាវបែបអនុវត្តន៍ ព្រមទាំងចូលរួមការពិភាក្សាជាមួយគ្រូបង្រៀនដ៏ទៃទៀតអំពីវិធីសាស្ត្រ ក្នុងការបង្រៀន និងរៀន រួមទាំងការចែករំលែកចំណេះដឹង |
| ចូលរួមក្នុងក្រៅកម្មវិធីសិក្សា និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈអំពីវិធីសាស្ត្រអប់រំស្ទែមបែបរួមបញ្ចូល | ៥-៦ | ចូលរួមក្នុងសកម្មភាពសិក្សាផ្អែកលើគម្រោង ត្រួតពិនិត្យសកម្មភាពផ្សារភ្ជាប់សិស្សទៅនឹងរោងចក្រឧស្សាហកម្ម បញ្ហា/ដំណោះស្រាយក្នុងស្រុក ការផ្លាស់ប្តូរបច្ចេកវិទ្យា និងតម្រូវការផ្នែកបច្ចេកវិទ្យាពីរោងចក្រឧស្សាហកម្ម |
| **ម៉ោងធ្វើការសរុបក្នុងមួយសប្តាហ៍** | ៣៥-៤២ | ម៉ោងធ្វើការសរុប ៧-៨ ម៉ោងក្នុងមួយថ្ងៃ |

## ៤.២. ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលគាំទ្រដល់ការបង្រៀន និងរៀនស្ទែម

តាមរយៈការពិចារណាលើភាពអាចរកបាននៃធនធានដែលមាននៅក្នុងសាលារៀនគំរូនេះ ណែនាំឱ្យមានសិស្ស ចំនួន ៣០ នាក់ក្នុងមួយថ្នាក់ សម្រាប់បន្ទប់ពិសោធន៍។

**តារាងទី១៦៖** ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលគាំទ្រដល់ដំណើរការបង្រៀន និងរៀនស្ទែម

| ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ថ្នាក់ទី១០-១២) | | គំរូ | |
|---|---|---|---|
| ព័ត៌មានទូទៅ | | ចំនួន | បរិយាយ/សេចក្ដីលម្អិតអំពីឧបករណ៍/តម្រូវការ |
| អនុបាតសិស្សក្នុងថ្នាក់រៀន | ថ្នាក់ទី១០ | ៣០ | សិស្សចំនួន ៣០ នាក់ក្នុងមួយថ្នាក់ គឺជាចំនួនកំណត់ដ៏ល្អប្រសើរបំផុតក្នុងការអនុវត្តការអប់រំស្ទែម |
| | ថ្នាក់ទី១១ | ៣០ | |
| | ថ្នាក់ទី១២ | ៣០ | |
| បន្ទប់ពិសោធន៍ | ជីវវិទ្យា | ១ | បន្ទប់ពិសោធន៍ជីវវិទ្យាទូទៅ បំពាក់ទៅដោយសម្ភារពិសោធន៍ដូចជា ទូរក្សាគ្រឿងកែវ ទូរក្សាសារធាតុគីមី កន្លែងសម្រាប់រៀបចំសំណាក និងកន្លែងពិសោធន៍ ទូទឹកកក ឧបករណ៍ពិសោធន៍មូលដ្ឋានសម្រាប់ការធ្វើពិសោធន៍ មីក្រូទស្សន៍ និងឧបករណ៍មូលដ្ឋានសម្រាប់ថ្នាក់ជីវវិទ្យា ចាប់ពីថ្នាក់ទី១០-១២ |
| | គីមីវិទ្យា | ១ | មន្ទីរពិសោធន៍គីមីវិទ្យាទូទៅ បំពាក់ដោយសម្ភារពិសោធន៍ ដូចជាទូរក្សា គ្រឿងកែវ សារធាតុគីមីមូលដ្ឋានសម្រាប់ការធ្វើពិសោធន៍ ឧ. បាស ឬអាស៊ីត ធម្មជាតិ សម្ភារកែវសម្រាប់ការពិសោធន៍គីមីមូលដ្ឋានមន្ទីរពិសោធន៍ច្នៃបង្កើត (Fab-lab) សម្រាប់ការសិក្សាផ្អែកលើគម្រោង និងឧបករណ៍គីមីមូលដ្ឋានផ្សេងទៀតសម្រាប់ថ្នាក់ទី១០-១២ |
| | រូបវិទ្យា | ១ | មន្ទីរពិសោធន៍រូបវិទ្យា និងផែនដីវិទ្យាទូទៅ បំពាក់ដោយសម្ភារពិសោធន៍ និងឧបករណ៍មូលដ្ឋានសម្រាប់រូបវិទ្យា និងផែនដី និងបរិស្ថានវិទ្យា សម្រាប់ថ្នាក់ទី១០-១២។ ឧបករណ៍មូលដ្ឋានមួយចំនួនអាចជា អេក្រង់សម្រាប់ ការសង្កេតបែបនិម្មិត ហើយខ្លឹមសារអាចយកចេញពីយូធូប ឬប្រព័ន្ធអនឡាញ ដទៃទៀត។<br><br>ឧបករណ៍រូបវិទ្យាមូលដ្ឋានសម្រាប់ការសង្កេតផែនដី ឧបករណ៍សង្កេតធម្មជាតិការបកស្រាយអំពីធម្មជាតិតាមរយៈបច្ចេកវិទ្យា និងមធ្យោបាយផ្សេងៗទៀត |
| | ផែនដី និងបរិស្ថានវិទ្យា | | |
| | កុំព្យូទ័រ | ២ | បន្ទប់ពិសោធន៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ចំនួន ០១ សម្រាប់ការបណ្ដុះបណ្ដាលគ្រូបង្រៀន និងសិស្ស ហើយបន្ទប់កុំព្យូទ័រមួយទៀតសម្រាប់ ការអនុវត្តនៅក្នុងថ្នាក់ |
| | ភាសាអង់គ្លេស | ១ | បន្ទប់ភាសាអង់គ្លេស សម្រាប់សិស្ស និងគ្រូ |

| | | | |
|---|---|---|---|
| សម្ភារបរិក្ខារ | អ៊ីនធឺណេត | ១ | ប្រព័ន្ធអ៊ីនធឺណិតមួយ សម្រាប់ការប្រើប្រាស់ទូទាំងសាលា |
| | ទូរទស្សន៍វៃឆ្លាត | ៣ | ត្រូវការទូរទស្សន៍វៃឆ្លាត ចំនួន ០៧ គ្រឿងសម្រាប់គ្រប់បន្ទប់រៀន បន្ទប់ប្រជុំ និងបន្ទប់សិក្សាទាំងអស់ |
| បណ្ណាល័យ | | ១ | ដាក់បញ្ចូលសៀវភៅទាក់ទងនឹងស្ទែម និងដំឡើងប្រព័ន្ធគ្រប់គ្រងបណ្ណាល័យ និងបំពាក់ប្រព័ន្ធសំឡេងបណ្ណាល័យ ដើម្បីបង្កើតបរិយាកាសអំណោយផលដល់សិស្ស ក្នុងការធ្វើការស្រាវជ្រាវឬស្វ័យសិក្សា។ បណ្ណារក្សគួរទទួលបាន ការបណ្ដុះបណ្ដាល ជាបន្តបន្ទាប់ពីអ្នកជំនាញ |
| បន្ទប់សិក្សា | | ២ | បន្ទប់ស្វ័យសិក្សា (មួយសម្រាប់គ្រូ និងមួយទៀតសម្រាប់សិស្ស) |
| បន្ទប់ពហុបំណង | | ៣ | បន្ទប់ប្រជុំចំនួន ០៣ សម្រាប់ការពិភាក្សា ការពិគ្រោះយោបល់ជាមួយមាតាបិតាសិស្ស កិច្ចប្រជុំវាយតម្លៃការងារ ការងារគម្រោង និងកិច្ចប្រជុំនានាជាដើម |
| រោងជាង | | ១ | រោងជាង សម្រាប់ការអភិវឌ្ឍផ្នែកវិស្វកម្ម និងបច្ចេកវិទ្យា |

## ៤.៣. ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលជំរុញបរិយាកាសសាលារៀនមួយដែលមានលក្ខណៈគាំទ្រ

**តារាងទី ១៧៖** ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលជំរុញបរិយាកាសសាលារៀនមួយដែលមានលក្ខណៈគាំទ្រ

| ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត (ថ្នាក់ទី១០-១២) | | |
|---|---|---|
| **ព័ត៌មានទូទៅ** | **ចំនួន** | **បរិយាយ/សេចក្ដីលម្អិតអំពីឧបករណ៍/តម្រូវការ** |
| **អគាររដ្ឋបាល** | | |
| ការិយាល័យ សម្រាប់គណៈគ្រប់គ្រង | ១ | ការិយាល័យសម្រាប់នាយកសាលា ០១ រូប និងនាយករង ០២ រូប |
| ការិយាល័យសម្រាប់បុគ្គលិក មិនមែនគ្រូបង្រៀន | ១ | ការិយាល័យសម្រាប់បុគ្គលិករដ្ឋបាល បុគ្គលិកហិរញ្ញវត្ថុ បុគ្គលិកទំនាក់ទំនងសាធារណៈ បុគ្គលិកគ្រប់គ្រងផ្នែកវិន័យ និងអ្នកទទួលបន្ទុកផ្នែកសិក្សាធិការ |
| ការិយាល័យសម្រាប់បុគ្គលិកជាគ្រូបង្រៀន | ១ | បន្ទប់សម្រាប់បុគ្គលិកជាគ្រូបង្រៀន ប្រើអំឡុងពេលសម្រាកជាមួយនឹងសម្ភារបរិក្ខារមូលដ្ឋាននានា ដើម្បីបង្កើតបរិយាកាសអំណោយផល |
| បន្ទប់អាហារសម្រាប់បុគ្គលិក | ១ | បន្ទប់៖ អាហារពេលព្រឹក តែ កាហ្វេ និងអាហារថ្ងៃត្រង់ សម្រាប់បុគ្គលិក និងសម្រាប់ភ្ញៀវ |
| បន្ទប់សម្រាប់សន្តិសុខ និងបុគ្គលិកអនាម័យ | ១ | បន្ទប់សម្រាប់បុគ្គលិកសន្តិសុខ និងបុគ្គលិកអនាម័យ |

| ទីធ្លាក្រៅអគារ | | |
|---|---|---|
| សួនជីវៈ | ១ | សួនជីវៈ គឺជាទីពិសោធន៍វិទ្យាសាស្ត្រចំហ ដែលសិស្ស និងគ្រូអាចប្រើប្រាស់សម្រាប់មុខវិជ្ជាជីវវិទ្យា គីមីវិទ្យា រូបវិទ្យា និងសម្រាប់ការស្រាវជ្រាវ និងសកម្មភាពគម្រោង ស្ទែម។ លើសពីនេះទៀត ការធ្វើឱ្យអារម្មណ៍ស្រស់ស្រាយឡើងវិញ អាចដើរតួនាទីជាការ សិក្សាផ្អែកលើគម្រោង សម្រាប់សិស្សដែលអនុវត្តមុខវិជ្ជាជីវវិទ្យា។ |
| អាហារដ្ឋានដែលមានអនាម័យ | ១ | អាហារដ្ឋានដែលមានអនាម័យទូទៅសម្រាប់សាលារៀន ដែលសិស្ស គ្រូ និងគណៈគ្រប់គ្រងអាចទទួលទានអាហារពេលព្រឹក អាហារថ្ងៃត្រង់ និងកាហ្វេ។ អ្នកអនាម័យ និងអ្នកផ្គត់ផ្គង់សេវាកម្មអាហារ ត្រូវបានបង្កើតឱ្យមាននៅក្នុងអាហារដ្ឋាននេះផ្ទាល់។ |
| ទីធ្លាកីឡា | ១ | ទីធ្លាកីឡាអាចត្រូវបានប្រើប្រាស់ ជាទីធ្លាពហុបំណងសម្រាប់ សកម្មភាពកីឡានិងសកម្មភាពក្រៅថ្នាក់ផ្សេងៗ។ សកម្មភាពកីឡាសាមញ្ញមួយចំនួនត្រូវបានណែនាំសម្រាប់ការពង្រឹងសុខភាព ការប្រាស្រ័យទាក់ទង និងការពង្រឹងឥរិយាបថ។ កីឡាជាគោល អាចជាបាល់ទាត់ វាយកូនបាល់លើតុ បាល់ទះ ការប្រកួតរត់ប្រណាំង ។ល។ |
| សួនច្បារ | ១ | សួនច្បារនេះត្រូវដំឡើងប្រព័ន្ធបង្ហូរទឹក សម្រាប់ការតាមដានបែបវៃឆ្លាត និងទស្សនាទានឧស្សាហកម្ម ៤.០ ជាមួយនឹងបច្ចេកវិទ្យាអ៊ីនធឺណិតនៃវត្ថុ (IoT) សម្រាប់បរិវេណស្អាត និងបៃតង និងការអប់រំស្ទែម។ |
| ការគ្រប់គ្រងកាកសំណល់ បង្គន់អនាម័យ និងកន្លែងលាងដៃ | ២ | បន្ថែមពីលើបង្គន់អនាម័យនៅក្នុងអាគារ ក៏មានបង្គន់ ០២ ដាច់ដោយឡែកពីគ្នាផងដែរ (មួយសម្រាប់បុរស និងមួយសម្រាប់ស្ត្រី) និងកន្លែងលាងដៃចំនួន ២ នៅក្នុងបរិវេណសាលាសម្រាប់សិស្ស បុគ្គលិក និងភ្ញៀវ សម្រាប់សកម្មភាពក្រៅថ្នាក់។ ជាគោលការណ៍ មិនគួរមានកាកសំណល់នៅក្នុងសាលារៀនទេ។ ប្លាស្ទិក ឬកាកសំណល់ផ្សេងទៀត មិនត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់នៅអាហារដ្ឋាន ឬកន្លែងផ្សេងទៀតនោះទេ។ ការគ្រប់គ្រងកាកសំណល់ គួរតែត្រូវបានធ្វើឡើង និងបែងចែកកាកសំណល់ (ធុង ១ សម្រាប់ប្លាស្ទិក និងសំរាមស្ងួត និងមួយទៀតសម្រាប់កាកសំណល់សើម)។ លើសពីនេះទៀត ត្រូវតែមានទីលានគ្រប់គ្រងកាកសំណល់ សម្រាប់ការដុត ឬសេវាគ្រប់គ្រងកាកសំណល់ |
| ចំណត | ១ | ចំណត សម្រាប់កង់ ម៉ូតូ និងរថយន្ត |
| ការផ្គត់ផ្គង់ទឹកស្អាត | ១ | ទឹកស្អាត ផ្គត់ផ្គង់ដោយអ្នកផ្គត់ផ្គង់ផ្លូវការ |
| អគ្គិសនី | ១ | ប្រព័ន្ធអគ្គិសនីមានស្ថិរភាព ដែលត្រូវបានភ្ជាប់ទៅនឹង ប្រព័ន្ធបណ្តាញអគ្គិសនីជាតិ |

## ៤.៤. បុគ្គលិកផ្នែកគ្រប់គ្រង និងគាំទ្រ

**តារាងទី១៨៖** បុគ្គលិកផ្នែកគ្រប់គ្រង និងគាំទ្រ

| គណៈគ្រប់គ្រង | | ចំនួន | បរិយាយ/សេចក្ដីលម្អិតអំពីឧបករណ៍/តម្រូវការ |
|---|---|---|---|
| នាយក | | ១ | កម្រិតសិក្សាអប្បបរមា គឺបរិញ្ញាបត្រ (មានបទពិសោធន៍យ៉ាងតិច ០៥ឆ្នាំនៅក្នុងសាលា និងមានសាវតារផ្នែកស្ទែម កាន់តែប្រសើរ) និងទទួលបានបណ្ដុះបណ្ដាល ពីការគ្រប់គ្រងសាលា និងមានបទពិសោធន៍នៅក្នុងកម្រិតវិទ្យាល័យ |
| នាយករង | | ២ | កម្រិតសិក្សាអប្បបរមា គឺបរិញ្ញាបត្រ (មានបទពិសោធន៍យ៉ាងតិច ០៥ឆ្នាំនៅក្នុងសាលា) និងទទួលបានបណ្ដុះបណ្ដាលពីការគ្រប់គ្រងសាលា និងមានបទពិសោធន៍នៅក្នុងកម្រិតវិទ្យាល័យ |
| កិច្ចប្រជុំរបស់គណៈគ្រប់គ្រងក្នុងរយៈពេលមួយឆ្នាំ | | ១២ | រៀបចំកិច្ចប្រជុំប្រចាំសប្ដាហ៍ សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ លើសកម្មភាពការងារប្រចាំថ្ងៃដែលនឹងត្រូវដឹកនាំដោយនាយក |
| ការកសាងសមត្ថភាពរបស់គណៈគ្រប់គ្រងក្នុងមួយឆ្នាំ | | ១ | វគ្គសិក្សាប្រព័ន្ធគ្រប់គ្រងសាលារៀន ហិរញ្ញវត្ថុ រដ្ឋបាល និងទំនាក់ទំនងសាធារណៈ |
| ការបង្កើនជំនាញរបស់គ្រូបង្រៀនស្ទែម | | ១ | បង្កើតការកសាងសមត្ថភាពផ្ដោតលើជំនាញ ដល់គ្រូបង្រៀនស្ទែម ទាក់ទងនឹងការសិក្សាតាមបែបរិះរក ការសិក្សាផ្អែកលើគម្រោង ឬការសិក្សាផ្អែកលើការពិសោធន៍ និងក្លឹបសិក្សាវិទ្យាសាស្ត្រ |
| កិច្ចប្រជុំរវាងគណៈគ្រប់គ្រង និងបុគ្គលិកសិក្សាក្នុងមួយឆ្នាំ | | ៤ | កិច្ចប្រជុំប្រចាំត្រីមាសស្ដីពីសមិទ្ធផល រៀបចំផែនការអនាគត យន្តការដើម្បីសម្រេចគោលដៅ និងការតម្រង់ទិសផ្អែកលើជាតុចេញ |
| បុគ្គលិក ការិយាល័យ | បុគ្គលិករដ្ឋបាល | ១ | កម្រិតសិក្សាអប្បបរមា គឺបរិញ្ញាបត្រ ជំនាញការគ្រប់គ្រងផ្នែកអប់រំ ដែលអាចទទួលខុសត្រូវរាល់កិច្ចការរដ្ឋបាលនៅក្នុងសាលា |
| | បុគ្គលិកហិរញ្ញវត្ថុ | ១ | កម្រិតសិក្សាអប្បបរមា គឺបរិញ្ញាបត្រ ជំនាញគណនេយ្យ ដែលអាចទទួលបន្ទុកទាំងហិរញ្ញវត្ថុ គណនេយ្យ និងផ្នែកបេឡា |
| | បុគ្គលិកទំនាក់ទំនងសាធារណៈ | ២ | កម្រិតសិក្សាអប្បបរមា គឺបរិញ្ញាបត្រ ជំនាញទំនាក់ទំនងសាធារណៈ ដែលអាចទទួលបន្ទុកលើការប្រាស្រ័យទាក់ទង និងភ្ជាប់បណ្ដាញទំនាក់ទំនងទៅកាន់អ្នកខាងក្រៅ ដូចជា សហគមន៍ មាតាបិតា រោងចក្រ ឧស្សាហកម្ម និងដៃគូអភិវឌ្ឍន៍ |
| | បុគ្គលិកកិច្ចការសិក្សាធិការ | ១ | កម្រិតសិក្សាអប្បបរមា គឺបរិញ្ញាបត្រ ព្រមជាមួយនឹងការបណ្ដុះបណ្ដាលស្ដីពីការប្រឹក្សាផ្នែកអប់រំ ដែលអាចទទួលខុសត្រូវលើការសិក្សា ព្រឹត្តិបត្រពិន្ទុ និងសកម្មភាពសិក្សាផ្សេងៗទៀតរបស់សិស្សទាំងអស់ |
| | ជំនួយការនៅបន្ទប់ពិសោធន៍ | ៤ | កម្រិតសិក្សាអប្បបរមា គឺបរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រ ឬវិស្វកម្ម ដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្រូបង្រៀនស្ទែម ដើម្បីជួយសិស្សធ្វើការពិសោធន៍នៅបន្ទប់ពិសោធន៍ និងសកម្មភាពផ្នែកវិទ្យាសាស្ត្រផ្សេងទៀត |

| | | | |
|---|---|---|---|
| គណៈកម្មាធិការប្រឹក្សាយោបល់ | កិច្ចការមិនមែនសិក្សាធិការ | ១ | បញ្ហារបស់សិស្សនានាដូចជាមាត៌អាជីពការងារ ការរស់នៅ ការស្នាក់នៅ សុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្ត |
| | កិច្ចការសិក្សាធិការ | ៧ | គ្រប់គ្រង និងរៀបចំសកម្មភាពក្លឹបសិក្សារបស់សិស្សទាំងអស់ |
| ចំនួនសន្តិសុខ | ក្នុងទីធ្លាសាលា | ២ | ម្នាក់ទទួលបន្ទុកនៅខាងក្រៅអគារ និងម្នាក់នៅខាងក្នុងអគារ និងទស្សនកិច្ច សិក្សាពីអ្នកខាងក្រៅ |
| | ច្រកទ្វារខាងមុខ | ១ | ទទួលបន្ទុកនៅច្រកទ្វារខាងមុខ |
| គិលានុបដ្ឋាក | | ១ | កិច្ចការសង្គ្រោះបឋមគួរតែមានសិស្ស ឬបុគ្គលិកជាអ្នកទទួលខុសត្រូវ និងគួរសហការជាមួយកាកបាទក្រហម ឬមណ្ឌលសុខភាព |
| អ្នកសម្អាត | | ២ | ម្នាក់ទទួលបន្ទុកនៅក្រៅអគារសិក្សា និងម្នាក់ទៀតនៅក្នុងអគារសិក្សា។ លើសពីនេះទៀត វាជាការសំខាន់ក្នុងការមានប្រតិទិនសម្រាប់ បុគ្គលិក គ្រូបង្រៀន និងសិស្សានុសិស្សទាំងអស់ រួមទាំងកម្រិតគ្រប់គ្រង ដើម្បីមានកាលវិភាគផ្ទាល់ខ្លួនសម្រាប់ការសម្អាតសាលា ឧ. ទិវាបរិស្ថាន ទិវាសង្គ្រោះផែនដីចំនួន ១ ដងក្នុងមួយឆ្នាំ ដើម្បីសម្អាតប្លាស្ទិក ឬកាកសំណល់នានានៅក្នុង ឬក្រៅបរិវេណសាលារៀន ឬក្នុងសហគមន៍ |
| កិច្ចប្រជុំទៀងទាត់រវាងគណៈគ្រប់គ្រង និងបុគ្គលិកផ្នែកគាំទ្ររៀងរាល់ ៦ ខែម្តង | | ១២ | កិច្ចប្រជុំប្រចាំខែ ដើម្បីពិនិត្យតាមដាន និងវាយតម្លៃទៅលើការងារប្រចាំថ្ងៃ |
| ការបង្កើនជំនាញទៀងទាត់សម្រាប់បុគ្គលិក ផ្នែកគាំទ្រក្នុងមួយឆ្នាំ | | ១ | ចំនួន ១ លើក ក្នុងមួយឆ្នាំក្នុងអំឡុងពេលវិស្សមកាល |

## ៤.៥. អភិបាលកិច្ច និងភារកិច្ចសម្រាប់ក្រុមប្រឹក្សាភិបាលសាលារៀន

**តារាងទី១៩៖** អភិបាលកិច្ច និងលក្ខខណ្ឌយោងសម្រាប់ក្រុមប្រឹក្សាភិបាលសាលារៀន

| អភិបាលកិច្ច | | ចំនួនសមាជិក | បរិយាយ |
|---|---|---|---|
| ក្រុមប្រឹក្សា-ភិបាលសាលារៀន | ចំនួនសមាជិក | ៧ | ក្រសួងអប់រំ មន្ត្រីមូលដ្ឋាន គណៈគ្រប់គ្រងសាលារៀន វិស័យឯកជន តំណាងសហគមន៍ មាតាបិតាសិស្ស និងអ្នកតំណាងវត្ត (ព្រះសង្ឃ) |
| | ចំនួនកិច្ចប្រជុំក្នុងមួយឆ្នាំ | ៤ | ការប្រជុំប្រចាំត្រីមាស |
| លក្ខខណ្ឌយោង | | - | ការត្រួតពិនិត្យលើថវិកា ការអង្គាសមូលនិធិ ទំនាក់ទំនងសាធារណៈ ដំណោះស្រាយ ផ្អែកលើបរិបទសម្រាប់បញ្ហាជាក់ស្តែង ការផ្លាស់ប្តូរព័ត៌មានអំពីដំណើរការរបស់សាលារៀន ផែនការយុទ្ធសាស្ត្រ និងការវាយតម្លៃលើដំណើរការរបស់សាលារៀន |

## ៤.៦. ធនធានហិរញ្ញប្បទាន/ហិរញ្ញវត្ថុ

**តារាងទី២០៖** ធនធានហិរញ្ញប្បទាន/ហិរញ្ញវត្ថុ

| ប្រភពថវិកាប្រចាំឆ្នាំ | | ចំនួន | បរិយាយ |
|---|---|---|---|
| ប្រភពផ្សេងៗទៀត | រដ្ឋាភិបាល | ១ | ការគាំទ្រដែលមានស្រាប់ពីរដ្ឋាភិបាល ជាមួយនឹងការបើកចំហលទ្ធភាពសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្មីៗ |
| | ដៃគូអភិវឌ្ឍន៍ | ១ | អាចជួយគាំទ្រទៅលើហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ក៏ដូចជាកម្មវិធីអភិវឌ្ឍន៍សមត្ថភាព ជាពិសេសតាមរយៈទស្សនកិច្ចសិក្សា និងកម្មវិធីផ្លាស់ប្តូរគ្រូបង្រៀន |
| | មាតាបិតាសិស្ស | ១ | គាំទ្របន្ថែមសម្រាប់ប្រតិបត្តិការក្នុងសាលា រួមទាំងការចំណាយជាប្រចាំ និងប្រាក់ខែបន្ថែម |
| | សហគមន៍ | ១ | គាំទ្របន្ថែមសម្រាប់ប្រតិបត្តិការក្នុងសាលា រួមទាំងការចំណាយជាប្រចាំ និងប្រាក់ខែបន្ថែម |
| ការគាំទ្របន្ថែមសម្រាប់បុគ្គលិកដើម្បីអនុវត្តគំរូថ្មីដែលបានស្នើឡើងនេះ | គណៈគ្រប់គ្រង | ៣ | នាយកសាលា ០១ រូប និងនាយករង ០២ រូប |
| | បុគ្គលិក | ៩ | បុគ្គលិករដ្ឋបាល បុគ្គលិកហិរញ្ញវត្ថុ បុគ្គលិកទំនាក់ទំនងសាធារណៈ បុគ្គលិកសិក្សាធិការ និងជំនួយការបន្ទប់ពិសោធន៍ |
| | បុគ្គលិកជាគ្រូបង្រៀន | - | គ្រូបង្រៀនទាំងអស់ដែលមាននៅក្នុងចរន្តវិទ្យាសាស្ត្រពិត |
| | គិលានុបដ្ឋាក | ១ | ទាក់ទងស្នើសុំពីមណ្ឌលសុខភាព |
| | សន្តិសុខ | ៣ | សន្តិសុខពីក្រុមហ៊ុនឯកជន |
| | អ្នកសម្អាត | ២ | អ្នកអនាម័យអាជីព |
| | ក្រុមប្រឹក្សាភិបាល | ៧ | សិស្សស្ម័គ្រចិត្តដោយមានការឧបត្ថម្ភបន្តិចបន្តួចពីសាលា |

# ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការអភិវឌ្ឍការអប់រំស្ទែមនៅកម្ពុជា ត្រូវបានមើលឃើញថាកំពុងមានកិច្ចខិតខំប្រឹងប្រែង និងទស្សនៈជាវិជ្ជមាននៅទូទាំងប្រទេស។ យ៉ាងណាក៏ដោយ និយមន័យនៃការអប់រំស្ទែមដែលមានភាពរួមគ្នា និងឯកភាពគ្នា គួរតែត្រូវបានកំណត់ ជាពិសេសលើវិធីសាស្ត្រអប់រំស្ទែម។ អ្វីដែលគួរឱ្យចាប់អារម្មណ៍បំផុតនោះ គឺសំណួរថាតើយុទ្ធសាស្ត្រក្នុងការកៀរគរធនធានប្រភេទណា ដែលសមស្របក្នុងការអនុវត្តការអប់រំស្ទែម នៅតែមិនទាន់មានចម្លើយ។ តាមរយៈការពិនិត្យឡើងវិញនូវគំរូអប់រំរបស់វិទ្យាល័យមួយចំនួនដែលអះអាងថាបានលើកកម្ពស់ការអប់រំស្ទែមនោះ យើងអាចសន្និដ្ឋានបានថា គំរូស្ទែមដែលមានស្រាប់នោះ ត្រូវការការចំណាយយ៉ាងច្រើន ហើយយើងក៏បានរកឃើញថា ការផ្សារភ្ជាប់ខ្លឹមសាររបស់ការអប់រំស្ទែមទៅនឹងបរិបទក្នុងស្រុក នៅមានកម្រិតមធ្យមនៅឡើយ។ បើទោះបីជាគំរូវិទ្យាល័យស្ទែមភាគច្រើនមានខិតខំប្រឹងប្រែងផ្តោតលើសកម្មភាពអនុវត្តជាក់ស្តែង និងការកែលម្អគុណភាពក្តី ការផ្សារភ្ជាប់រវាងកម្មវិធីអប់រំស្ទែមរបស់សាលាទាំងនោះទៅនឹងឧស្សាហកម្ម ឬការដោះស្រាយបញ្ហាក្នុងស្រុក នៅតែមិនមានភាពច្បាស់លាស់ ដោយសារតែមិនមានការកែទម្រង់ច្រើនលើកម្មវិធីសិក្សា និងយុទ្ធសាស្ត្របង្រៀន (បង្រៀន ដើម្បីប្រឡងជាប់) និងកង្វះសកម្មភាពក្រៅកម្មវិធីសិក្សា ដែលសកម្មភាពទាំងនេះបង្ហាញពីគុណតម្លៃបន្ថែមនៃការអប់រំស្ទែម សម្រាប់អាជីពការងាររបស់សិស្សនាពេលអនាគត។ លើសពីនេះទៀត ការចំណាយខ្ពស់របស់វាប្រហែលជាមិនអំណោយផល ក្នុងការពង្រីកការអប់រំស្ទែមឱ្យបានទូទាំងប្រទេស ក្នុងគោលបំណងផលិតអក្ខរកម្មស្ទែមដ៏មានសារៈសំខាន់ សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម និងសេដ្ឋកិច្ចកម្ពុជានាពេលអនាគតនោះទេ។

## ៥.១. សនិទានចម្បងសម្រាប់ការជ្រើសរើសវិទ្យាល័យដើម្បីអនុវត្តគំរូស្ទែមដែលស្នើឡើងថ្មី

នៅក្នុងបរិបទនេះ ក្រុមស្រាវជ្រាវស្នើការប្រែក្លាយវិទ្យាល័យកំពង់ស្ពឺសម្រាប់អនុវត្តគំរូអប់រំស្ទែមថ្មីដែលបានមកពីការសិក្សានេះ ដោយស្នើបន្ថែមចរន្តវិទ្យាសាស្ត្រពិតសម្រាប់សិស្សចាប់ពីថ្នាក់ទី១០ឡើងទៅ។ បន្ថែមពីលើនេះ ក្រុមស្រាវជ្រាវស្នើសុំជ្រើសរើសសិស្សត្រឹមតែ ៩០នាក់ប៉ុណ្ណោះសម្រាប់ថ្នាក់រៀនចំនួន ០៣។ សនិទានរបស់យើងក្នុងការជ្រើសរើសវិទ្យាល័យកំពង់ស្ពឺក្នុងចំណោមវិទ្យាល័យចំនួន ០៥ ដែលត្រូវបានជ្រើសរើស ដើម្បីប្រែក្លាយជាវិទ្យាល័យស្ទែម គឺដោយសារសាលានេះមានលទ្ធភាពខ្ពស់បំផុតក្នុងការអនុវត្ត ដោយជោគជ័យដោយផ្អែកលើហេតុផលដូចខាងក្រោម៖

១. ការមានរួចជាស្រេចនៃហេដ្ឋារចនាសម្ព័ន្ធ (តម្រូវការការវិនិយោគបន្ថែម ពីកម្រិតទាបទៅមធ្យម)

២. លទ្ធភាពតភ្ជាប់ទៅនឹងអគ្គិសនី ទឹក និងអ៊ីនធឺណិត

៣. ចម្ងាយទីតាំងរបស់សាលា ទៅកាន់តំបន់ឧស្សាហកម្មផ្សេងៗ

៤. គ្រូបង្រៀន គុណវុឌ្ឍិ និងសមត្ថភាពគ្រូបង្រៀន ជាពិសេសការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅក្នុងការអប់រំ និងជីវិតប្រចាំថ្ងៃ
៥. ការត្រៀមលក្ខណៈរួចរាល់ និងសមត្ថភាពរបស់គណៈគ្រប់គ្រងសាលា
៦. ការចូលរួមពីសហគមន៍ និងមាតាបិតាសិស្សដែលមានស្រាប់
៧. ទីតាំងរបស់សាលាមានភាពងាយស្រួលសម្រាប់សិស្សទាំងអស់នៅក្នុងខេត្តកំពង់ស្ពឺ
៨. មានវប្បធម៌សាលាដ៏រឹងមាំ ដែលស័ក្តិសមសម្រាប់ការបង្រៀន និងរៀនស្ទែម

## ៥.២. អនុសាសន៍ដើម្បីប្រែក្លាយវិទ្យាល័យកំពង់ស្ពឺទៅជាវិទ្យាល័យស្ទែម

### ៥.២.១. ដំណាក់កាលការរៀបចំ

ការវិនិយោគ និងការកសាងសមត្ថភាព ដើម្បីផ្តល់នូវយន្តការគាំទ្រឱ្យបានប្រសើរ សម្រាប់ការអនុវត្តការអប់រំស្ទែមឱ្យកាន់តែល្អជាងនេះនៅក្នុងសាលាដែលបានជ្រើសរើសក្រុមស្រាវជ្រាវ សូមផ្តល់អនុសាសន៍ដូចខាងក្រោម៖

១. រៀបចំមាតិកាឡើងវិញ ឱ្យស្របទៅតាមកម្មវិធីសិក្សាស្តង់ដារ ដោយគិតគូរពីស្តង់ដារដែលបានកំណត់រួច ធនធានដែលអាចប្រើប្រាស់បាន និងទស្សនាទានគន្លឹះ ព្រមទាំងអភិវឌ្ឍស្តង់ដារបង្រៀន និងរៀន សម្រាប់ការវាយតម្លៃការបង្រៀន និងរៀន ក៏ដូចជាសៀវភៅណែនាំគ្រូបង្រៀនសម្រាប់ការសិក្សាតាមបែះរិះរកជាទូទៅ ឱ្យបានច្បាស់លាស់។

២. ផ្តល់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ ផ្អែកលើតម្រូវការរបស់គ្រូបង្រៀនម្នាក់ៗ និងផ្តល់សម្ភារបង្រៀន និងរៀនដែលចាំបាច់ទាំងអស់ ដោយផ្អែកលើស្តង់ដារមាតិកាដែលត្រូវបានរៀបចំថ្មីខាងលើ។

៣. ប្រែក្លាយការអនុវត្តគរុកោសល្យដែលមានស្រាប់ ឱ្យទៅជាការសិក្សាតាមបែបរិះរកដូចជា គំរូណែនាំការសិក្សាតាមបែបរិះរកសម្រាប់ ការបង្រៀននិងរៀន និងកម្មវិធីសិក្សាផ្អែកលើសមត្ថ-ភាព។ ជាការឆ្លើយតប គ្រូបង្រៀនក៏ត្រូវបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងវេទិកាមួយ ដូច្នេះសមិទ្ធផលក្នុងការអនុវត្តការសិក្សាតាមបែបរិះរករបស់ពួកគាត់ អាចត្រូវបានចែករំលែកនៅក្នុងវេទិកា/សន្និសីទនានា ដោយផ្ទាល់/តាមអេឡិចត្រូនិក។

៤. ធ្វើឱ្យបរិយាកាសបង្រៀន និងរៀនកាន់តែប្រសើរឡើងដូចជា សម្ភារបរិក្ខារបន្ទប់រៀន ហេដ្ឋា-រចនាសម្ព័ន្ធបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ជាមួយនឹងសម្ភារដែលអាចប្រើប្រាស់បានផ្សេងៗ បរិយាកាសអំណោយផលសម្រាប់ការអភិវឌ្ឍន៍ជំនាញ និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។ សម្ភារបរិក្ខារទាំងនេះ នឹងអនុញ្ញាតឱ្យគ្រូបង្រៀន និងសិស្សអាច

ធ្វើសកម្មភាពពិសោធន៍ជាមុន ដើម្បីលើកកម្ពស់ការរៀនសូត្រសកម្ម និងរៀបចំសកម្មភាព ក្រោយការពិសោធន៍ ដើម្បីជំរុញជំនាញសតវត្សរ៍ទី ២១។

៥. បង្កើតកម្មវិធីសិក្សាបន្ថែមសម្រាប់សិស្សដូចជា កម្មវិធីអ្នកសិក្សានិងឧស្សាហកម្ម ពិព័រណ៍វិទ្យាសាស្ត្រ សកម្មភាពទស្សនកិច្ចសិក្សាទាក់ទងនឹងស្ទែម ការផ្សារភ្ជាប់ទៅនិស្សិតបញ្ចប់ឧត្តមសិក្សា កម្មវិធីទេពកោសល្យពិសេស គម្រោងអំពីស្ទែម ក៏ដូចជាការប្រកួតប្រជែងអំពីវិទ្យាសាស្ត្រ ក្នុងគោលបំណងផ្តល់ឱកាសបន្ថែមសម្រាប់សិស្ស និងគ្រូបង្រៀន ក្នុងការរៀនសូត្រ និងប្រើប្រាស់ចំណេះដឹង និងជំនាញរបស់ពួកគេនៅក្នុងការអនុវត្តជាក់ស្តែងតាមរយៈការសង្កេតតាមបែបវិទ្យាសាស្ត្រ ការពិភាក្សា ការសរសេររបាយការណ៍ ការធ្វើបទបង្ហាញ និងការជញ្ជឹងគិតនានា។ ការរៀនសូត្របែបស្វ័យដឹកនាំ និងក្លឹបសិក្សាស្ទែមលើមុខវិជ្ជាវិទ្យាសាស្ត្រសំខាន់ៗ និងអំណាន ចាំបាច់ត្រូវអនុវត្តដើម្បីបង្កើនឱកាសសិក្សាសម្រាប់សិស្ស និងលើកកម្ពស់សមត្ថភាពសិស្សក្នុងជំនាញសតវត្សរ៍ទី២១ និងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បន្ថែមពីលើការអនុវត្តក្នុងថ្នាក់រៀនធម្មតា។

**តារាងទី២១៖** អនុសាសន៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទូទៅក្នុងសាលារៀន (ថ្នាក់ទី១០-១២)

| ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ថ្នាក់ទី១០-១២) | | ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នៅក្នុងវិទ្យាល័យកំពង់ស្ពឺ | ហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិទ្យាល័យស្វែម | អ្វីដែលត្រូវធ្វើ |
|---|---|---|---|---|
| ព័ត៌មានទូទៅ | | ចំនួន | ចំនួន | បរិយាយ |
| បន្ទប់ពិសោធន៍ | ជីវវិទ្យា | ១ | ១ | ត្រូវការជួសជុល និងបំពាក់សម្ភារពិសោធន៍ និងឧបករណ៍នានាឆ្លើយតបនឹងតម្រូវការ |
| | គីមីវិទ្យា | ១ | ១ | ត្រូវការជួសជុល និងបំពាក់សម្ភារពិសោធន៍ និងឧបករណ៍នានាឆ្លើយតបនឹងតម្រូវការ |
| | រូបវិទ្យា<br>ផែនដី និងបរិស្ថានវិទ្យា | ១ | ១ | ត្រូវការជួសជុល និងបំពាក់សម្ភារពិសោធន៍ និងឧបករណ៍នានា ឆ្លើយតបនឹងតម្រូវការ |
| | កុំព្យូទ័រ | ១ | ២ | បន្ទប់កុំព្យូទ័រ និងបរិក្ខារនានា ពេលបច្ចុប្បន្នត្រូវការធ្វើបច្ចុប្បន្នភាព រួមមាន កុំព្យូទ័រ ការតភ្ជាប់អ៊ីនធឺណិត និងសុសវែរពាក់ព័ន្ធនានា ព្រមទាំងត្រូវការបន្ទប់កុំព្យូទ័រមួយបន្ថែមទៀត |
| | ភាសាអង់គ្លេស | ០ | ១ | ត្រូវការបង្កើតបន្ទប់មួយបន្ថែមសម្រាប់ភាសាអង់គ្លេស |
| សម្ភារបរិក្ខារ ICT | អ៊ីនធឺណេត | ០ | ១ | ត្រូវការប្រព័ន្ធអ៊ីធឺណិតមួយសម្រាប់ការប្រើប្រាស់ទូទាំងសាលា |
| | ទូរទស្សន៍វៃឆ្លាត | ០ | ១៣ | ទូរទស្សន៍វៃឆ្លាតចំនួន ០៩ សម្រាប់ថ្នាក់រៀនទាំងអស់ និងបន្ទប់ប្រជុំចំនួន ០៤ |
| បណ្ណាល័យ | | ១ | ១ | បណ្ណាល័យបច្ចុប្បន្នល្អប្រសើរ ប៉ុន្តែត្រូវបន្ថែមសៀវភៅថ្មី ទាក់ទងនឹងស្វែម និងពង្រីកបន្ថែម |
| បន្ទប់សិក្សា | | ០ | ២ | បន្ទប់ស្វ័យសិក្សាចំនួន ០២ (០១ សម្រាប់គ្រូ និង ០១ សម្រាប់ សិស្ស) |
| បន្ទប់ប្រជុំ | | ០ | ៤ | បន្ទប់ប្រជុំចំនួន ០៤ សម្រាប់ការពិភាក្សា គម្រោងការងារ និងកិច្ចប្រជុំ |
| មន្ទីរពិសោធន៍ច្នៃបង្កើត | | ០ | ១ | បង្កើតរោងជាងចំនួន ០១សម្រាប់ការអភិវឌ្ឍវិស្វកម្មនិងបច្ចេកវិទ្យា |

**តារាងទី២២៖** អនុសាសន៍សម្រាប់ធនធានមនុស្ស

| ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ថ្នាក់ទី១០-១២) | ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នៅក្នុងវិទ្យាល័យកំពង់ស្ពឺ | ហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិទ្យាល័យស្វែម | អ្វីដែលត្រូវធ្វើ |
|---|---|---|---|
| **អគាររដ្ឋបាល** | **ចំនួន** | **ចំនួន** | **បរិយាយ** |
| ការិយាល័យសម្រាប់គណៈគ្រប់គ្រង | ១ | ១ | រៀបចំកន្លែងធ្វើការ និងលក្ខខណ្ឌការងារឡើងវិញ |
| ការិយាល័យសម្រាប់បុគ្គលិកមិនមែនគ្រូបង្រៀន | ១ | ១ | រៀបចំគ្រឿងសង្ហារិមការិយាល័យ និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឱ្យប្រសើរជាងមុន |
| ការិយាល័យសម្រាប់បុគ្គលិកជា<br>គ្រូបង្រៀន | ១ | ១ | រៀបចំគ្រឿងសង្ហារិមការិយាល័យ និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឱ្យប្រសើរជាងមុន |
| បន្ទប់អាហារសម្រាប់បុគ្គលិក | ០ | ១ | បង្កើតបន្ទប់ទទួលទានអាហារមួយសម្រាប់បុគ្គលិក |
| បន្ទប់សម្រាប់សន្តិសុខ& បុគ្គលិកអនាម័យ | ០ | ១ | បង្កើតបន្ទប់មួយសម្រាប់សន្តិសុខ និងអ្នកសម្អាត |
| **ទីធ្លាក្រៅអគារ** | **ចំនួន** | **ចំនួន** | **បរិយាយ** |
| សួនជីវៈ | ០ | ១ | បង្កើតសួនដំណាំចម្រុះមួយសម្រាប់ការសិក្សា និងការពិសោធន៍ក្រៅបន្ទប់ពិសោធន៍ |
| អាហារដ្ឋានអនាម័យ | ១ | ១ | ត្រូវការបង្កើតគោលការណ៍អនាម័យ |
| ទីធ្លាសម្រាប់កីឡា | ១ | ១ | មានលក្ខខណ្ឌល្អស្រាប់ |
| សួនច្បារ | ១ | ១ | មានលក្ខខណ្ឌល្អស្រាប់ |
| ការគ្រប់គ្រងសំរាម បង្គន់អនាម័យ និងកន្លែងលាងដៃ | ១ | ២ | មានលក្ខខណ្ឌល្អស្រាប់ |
| ចំណត | ១ | ១ | មានលក្ខខណ្ឌល្អស្រាប់ |
| ការរៀបចំតុ កៅអី និងសោភណភាពទូទៅ | ១ | ១០ | មានលក្ខខណ្ឌល្អស្រាប់ |
| ការផ្គត់ផ្គង់ទឹក | ១ | ១ | ត្រូវបានតភ្ជាប់រួចរាល់ |
| អគ្គិសនី | ១ | ១ | ត្រូវបានតភ្ជាប់រួចរាល់ ប៉ុន្តែត្រូវការរៀបចំឱ្យប្រសើរជាងមុនស្របទៅនឹងតម្រូវការថ្មី |

នៅក្នុងដំណាក់កាលចាប់ផ្តើមដំបូង ការអភិវឌ្ឍក្នុងកម្រិតតិចតួចត្រូវបានណែនាំ។ ដូចដែលបានបង្ហាញខាងលើ ក្រុមស្រាវជ្រាវ បានស្នើឱ្យមានការផ្តោតចំណាប់អារម្មណ៍ទៅលើចរន្តវិទ្យាសាស្ត្រ ដោយមានថ្នាក់ចំនួន ០៣ ដូចដែលបញ្ចូលក្នុងផែនការ។ ទាំងហេដ្ឋារចនាសម្ព័ន្ធរឹង និងទន់សម្រាប់ការអភិវឌ្ឍ និងការអនុវត្តកម្មវិធីស្ទែម ដែលបានស្នើឡើង ចាំបាច់ត្រូវមានការយកចិត្តទុកដាក់ដូចគ្នា។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាមូលដ្ឋាន និងសម្ភារបរិក្ខារបន្ទប់រៀន ដើម្បីគាំទ្រគំរូថ្មីនៃការបង្រៀន និងរៀន ជាពិសេសការរៀនសូត្របែបស្វ័យដឹកនាំ និងក្លឹបសិក្សាស្ទែម ដែលអាចធ្វើឱ្យការអនុវត្តគម្រោងស្ទែមអាចបង្កើតប្រាក់ចំណូលបាន ដែលដឹកនាំមុខដោយសិស្ស និងការប្រកួតប្រជែងស្ទែម គឺជាអ្វីដែលគួរវិនិយោគនៅក្នុងដំណាក់កាលដំបូង។ ការផ្តោតអារម្មណ៍កាន់តែខ្លាំងលើចរន្តវិទ្យាសាស្ត្រ គឺជារឿងសមហេតុផល សម្រាប់ស្ថានភាពថវិកាបច្ចុប្បន្នសម្រាប់សាលានៅតាមបណ្តាខេត្តនានានៅកម្ពុជា។ ម្យ៉ាងទៀត វានឹងមានភាពងាយស្រួលក្នុងការវាយតម្លៃពីស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពរបស់វា ព្រមទាំងលទ្ធភាពក្នុងការពង្រីកទូទាំងខេត្ត ឬលើសនេះ។

ការកសាងសមត្ថភាពក្នុងរយៈពេលខ្លី និងមធ្យម សម្រាប់គ្រូបង្រៀន គឺត្រូវការចាំបាច់ក្នុងអំឡុងពេលចាប់ផ្តើមដំបូង។ គ្រូបង្រៀនត្រូវការការបណ្តុះបណ្តាលជំនាញខ្លះៗ ដើម្បីអាចផ្តល់ការអប់រំស្ទែមប្រកបដោយគុណភាពខ្ពស់ទាំងក្នុង និងក្រៅថ្នាក់រៀន។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញអាចផ្តល់ការបណ្តុះបណ្តាល និងបន្តផ្តល់ការណែនាំដល់គ្រូទាំងនោះ ដើម្បីអនុវត្តការសិក្សាផ្អែកលើបញ្ហា គម្រោង និងការសិក្សាតាមបែបរិះរក នៅក្នុងថ្នាក់រៀន និងជាពិសេសដើម្បីអនុវត្តក្លឹបសិក្សាស្ទែម និងគម្រោងស្ទែម ដែលមានលទ្ធភាពនាំទៅរកការបង្កើតប្រាក់ចំណូល។ ដូច្នេះហើយ បន្ថែមពីលើការវិនិយោគលើសម្ភារបរិក្ខារសាលា និងថ្នាក់រៀន ដែលគាំទ្រដល់ការបង្រៀន និងរៀន ការវិនិយោគលើការបណ្តុះបណ្តាលគ្រូ គឺពិតជាមានសារៈសំខាន់ក្នុងដំណាក់កាលដំបូង និងចាំបាច់ក្នុងអំឡុងពេលសាកល្បង និងបន្តមានសារៈសំខាន់ក្នុងដំណាក់កាលអនុវត្ត។

**តារាងទី២៣៖** អនុសាសន៍សម្រាប់គ្រូបង្រៀនក្នុងមុខវិជ្ជាស្ទែម

| គ្រូបង្រៀនក្នុងមុខវិជ្ជាស្ទែម | | គ្រូបង្រៀនស្ទែមនៅក្នុងវិទ្យាល័យកំពង់ស្ពឺ | | បុគ្គលិកសម្រាប់វិទ្យាល័យស្ទែម | តម្រូវការ |
|---|---|---|---|---|---|
| | | គុណវុឌ្ឍិ | ចំនួន | ចំនួន | បរិយាយ |
| គ្រូបង្រៀន | ជីវវិទ្យា | បរិញ្ញាបត្រ<br>និង<br>ពីររូបមាន<br>បរិញ្ញាបត្រ<br>ជាន់ខ្ពស់ | ៤ | ២ | ចំនួនម៉ោងបង្រៀនសរុបសម្រាប់ ០៩ ថ្នាក់ (ថ្នាក់ទី១០-១២) តាមមុខវិជ្ជាគឺ គណិតវិទ្យា ៥៤ ម៉ោង រូបវិទ្យា ៣៦ ម៉ោង គីមីវិទ្យា ២៧ ម៉ោង ជីវវិទ្យា ២៧ ម៉ោង និង ១៨ ម៉ោង សម្រាប់ផែនដី និងបរិស្ថានវិទ្យា។ ដោយសារតែចំនួនម៉ោងបង្រៀនសម្រាប់គ្រូម្នាក់ ក្នុងមួយសប្តាហ៍គឺ ១៥ ម៉ោង គ្រូបង្រៀនស្ទែមដែលត្រូវការមាន៖<br>គ្រូបង្រៀនគណិតវិទ្យា = ០៤ រូប<br>គ្រូបង្រៀនរូបវិទ្យា = ០៣ រូប<br>គ្រូបង្រៀនគីមីវិទ្យា = ០២ រូប<br>គ្រូបង្រៀនជីវវិទ្យា = ០២ រូប<br>គ្រូបង្រៀនផែនដី និងបរិស្ថានវិទ្យា = ០២ រូប<br><br>គ្រប់គ្រូបង្រៀនទាំងអស់ត្រូវការអភិវឌ្ឍជំនាញវិជ្ជាជីវៈអំពីចំណេះដឹងខ្លឹមសារ និងវិធីសាស្ត្របង្រៀនថ្មីៗ ជាពិសេស មធ្យោបាយក្នុងការធ្វើសមាហរណកម្មវិស្វកម្ម និងបច្ចេកវិទ្យា ទៅក្នុងវិទ្យាសាស្ត្រ និងគណិតវិទ្យា។ ការផ្សារភ្ជាប់គម្រោង ឬបញ្ហាទៅនឹងបរិបទក្នុងស្រុក គឺចាំបាច់សម្រាប់ជាករណីសិក្សាសម្រាប់សិស្ស ដើម្បីឱ្យពួកគេប្រើប្រាស់ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដើម្បីដោះស្រាយបញ្ហាជាក់ស្តែងនោះ។ |
| | គីមីវិទ្យា | | ៤ | ២ | |
| | រូបវិទ្យា | | ៣ | ៣ | |
| | ផែនដី និងបរិស្ថានវិទ្យា | | ៣ | ២ | |
| | គណិតវិទ្យា | | ៧ | ៤ | |
| | កុំព្យូទ័រ | | ២ | ២ | |
| គុណវុឌ្ឍិនៃប្រធានក្រុម | ជីវវិទ្យា | | ១ | ១ | បញ្ជូនប្រធានក្រុមបច្ចេកទេស ដើម្បីទទួលបានសញ្ញាបត្រ |
| | គីមីវិទ្យា | | ១ | ១ | |

| | | | | | |
|---|---|---|---|---|---|
| បច្ចេកទេសតាមមុខវិជ្ជា | រូបវិទ្យា | | ១ | ១ | ជាន់ខ្ពស់នៅក្នុងស្រុកក្នុងគោលបំណងដើម្បីទទួលបានចំណេះដឹង និងជំនាញបន្ថែម |
| | ផែនដី និងបរិស្ថានវិទ្យា | | ១ | ១ | |
| | គណិតវិទ្យា | | ១ | ១ | |
| | កុំព្យូទ័រ | | ១ | ១ | |

## ***អភិបាលកិច្ច និងការគ្រប់គ្រង***

រចនាសម្ព័ន្ធអភិបាលកិច្ច អនុញ្ញាតឱ្យមានដំណើរការពាក់កណ្ដាលស្វ័យភាពដល់ នាយក និងគណៈគ្រប់គ្រងសាលា ក្នុងការរៀបចំ និងធានាការអនុវត្តកម្មវិធីសិក្សាប្រកបដោយជំនាញវិជ្ជាជីវៈខ្ពស់ ស្របតាមវិធីសាស្ត្រ និងគុណភាពបែបនវានុវត្តន៍នៃការបង្រៀន និងការសិក្សា។

**តារាងទី២៤៖** អនុសាសន៍សម្រាប់ក្រុមប្រឹក្សាភិបាលសាលារៀន និងលក្ខខណ្ឌយោង

| អភិបាលកិច្ច | | មានស្រាប់នៅវិទ្យាល័យកំពង់ស្ពឺ | ចំនួន | បរិយាយ |
|---|---|---|---|---|
| ក្រុមប្រឹក្សាភិបាលសាលា | ចំនួនសមាជិកក្រុមប្រឹក្សាភិបាល | ៧ | ៧ | សមាជិកភាពនៃក្រុមប្រឹក្សាភិបាល គួរតែមានភាពចម្រុះ និងមានតំណាងគ្រូបង្រៀនម្នាក់ជាសមាជិកក្រុមប្រឹក្សា |
| | ចំនួនកិច្ចប្រជុំក្នុងមួយឆ្នាំ | ១២ | ៤ | ចំនួនកិច្ចប្រជុំត្រូវបានកាត់បន្ថយ ប៉ុន្តែត្រូវការការកែលម្អទៅលើរបៀបវារៈ និងកំណត់ត្រាប្រជុំឱ្យបានច្បាស់លាស់ |
| លក្ខខណ្ឌយោង | | ១ | ១ | ត្រូវធ្វើឱ្យប្រសើរឡើង នៃជំនាញពិនិត្យតាមដាន និងវាយតម្លៃ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល ដើម្បីមើលខុសត្រូវកញ្ចប់ថវិកា ផែនការយុទ្ធសាស្ត្រ និងការបំពេញការងាររបស់សាលា |

**តារាងទី២៥៖** អនុសាសន៍សម្រាប់គណៈគ្រប់គ្រង និងបុគ្គលិកពាក់ព័ន្ធ

| គណៈគ្រប់គ្រងសាលា | | មានស្រាប់នៅវិទ្យាល័យកំពង់ស្ពឺ | ចំនួន | បរិយាយ/សម្ភារ/តម្រូវការ |
|---|---|---|---|---|
| នាយក | | ១ | ១ | នាយកសាលាទទួលបានការបណ្ដុះបណ្ដាលពីយុទ្ធសាស្រ្តដឹកនាំ ជាពិសេសការបណ្ដុះបណ្ដាលក្នុងជំនាញរៃអង្គាសមូលនិធិ |
| នាយករង | | ៣ | ២ | ការចាត់ចែងកាតព្វកិច្ចច្បាស់លាស់ក្នុងចំណោមនាយករងគួរតែត្រូវ បានរៀបចំ |
| កិច្ចប្រជុំគណៈគ្រប់គ្រងក្នុងមួយឆ្នាំ | | ១២ | ១២ | ត្រូវការការកែលម្អលើរបៀបវារៈ និងកំណត់ត្រាកិច្ចប្រជុំឱ្យបានច្បាស់ លាស់ដំណើរការផ្លាស់ប្តូរព័ត៌មាន ដើម្បីធ្វើឱ្យប្រព័ន្ធល្អប្រសើរ កត់ត្រានូវអ្វីដែលបានពិភាក្សា និងពិភាក្សានូវអ្វី ដែលបានកត់ត្រា |
| ការបង្កើនជំនាញរបស់គណៈគ្រប់គ្រងក្នុងមួយឆ្នាំ | | ០ | ១ | ការបណ្ដុះបណ្ដាលគួរផ្ដោតលើប្រព័ន្ធគ្រប់គ្រងសាលា វគ្គសិក្សាហិរញ្ញវត្ថុ រដ្ឋបាលវិន័យ និងទំនាក់ទំនងសាធារណៈ |
| កិច្ចប្រជុំរវាងគណៈគ្រប់គ្រង និងបុគ្គលិកសិក្សាធិការក្នុងមួយឆ្នាំ | | ១២ | ៤ | ចំនួនកិច្ចប្រជុំអាចកាត់បន្ថយ ប៉ុន្តែត្រូវការការកែលម្អទៅលើរបៀបវារៈ និងកំណត់ត្រាប្រជុំឱ្យមានភាពច្បាស់លាស់ |
| ការិយាល័យបុគ្គលិក | បុគ្គលិករដ្ឋបាល | ២ | ១ | ការបែងចែកតួនាទីច្បាស់លាស់ក្នុងចំណោមនាយករងគួរត្រូវបានរៀបចំ |
| | បុគ្គលិកហិរញ្ញវត្ថុ | ១ | ១ | កម្រិតបញ្ញាបត្រក្នុងជំនាញគណនេយ្យ ដែលអាចទទួលបន្ទុកហិរញ្ញវត្ថុ គណនេយ្យ និងកិច្ចការបេឡា |
| | បុគ្គលិកទំនាក់ទំនងសារធារណៈ | ០ | ២ | គួរជ្រើសរើសបុគ្គលិក ០២ រូប មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ក្នុងជំនាញទំនាក់ទំនងសាធារណៈ ដែលអាចទទួលបន្ទុកការងារប្រាស្រ័យ ទាក់ទង និងភ្ជាប់ទំនាក់ទំនងជាមួយអ្នកខាងក្រៅដូចជាសហគមន៍ មាតាបិតា ឧស្សាហកម្ម និងដៃគូអភិវឌ្ឍន៍ |
| | បុគ្គលិកកិច្ចការសិក្សាធិការ | ០ | ១ | គួរជ្រើសរើសបុគ្គលិក ០១ រូប មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ដែលទទួលបានការបណ្ដុះបណ្ដាលអំពីការប្រឹក្សាផ្នែកវិស័យអប់រំ ដែលអាចទទួលបន្ទុកលើការរៀនសូត្ររបស់សិស្ស ព្រឹត្តិបត្រពិន្ទុ និងសកម្មភាព ពាក់ព័ន្ធនឹងការសិក្សាផ្សេងទៀត |
| | ជំនួយការបន្ទប់ពិសោធន៍ | ២ | ៤ | គួរជ្រើសរើសជំនួយការបន្ទប់ពិសោធន៍ចំនួន ០២ រូបជាមួយនឹងកម្រិត អប្បបរមាឌីប្លូម៉ាផ្នែកគ្រប់គ្រង និងប្រើប្រាស់បន្ទប់ពិសោធន៍ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្រូបង្រៀនស្ទែម ដើម្បីជួយដល់សិស្សលើ ការងារពិសោធន៍ និងសកម្ម ភាពវិទ្យាសាស្ត្រផ្សេងៗ |

| | | | | |
|---|---|---|---|---|
| គណៈកម្មការប្រឹក្សាសាលារៀន | កិច្ចការមិនមែនសិក្សាធិការ | ៧ (សិស្ស) | ១ | អ្នកប្រឹក្សាដែលមានជំនាញវិជ្ជាជីវៈគួរតែត្រូវបានជ្រើសរើស ដើម្បីធ្វើការលើបញ្ហាទាំងនេះ |
| | កិច្ចការសិក្សាធិការ | ០ | ១ | គ្រូបង្រៀនដែលត្រូវបានបណ្តុះបណ្តាលនៅក្នុងជំនាញប្រឹក្សាផ្នែកសិក្សាធិការ គួរតែត្រូវបានតែងតាំង |
| ចំនួនសន្តិសុខ | ក្នុងបរិវេណសាលា | ០ | ២ | សន្តិសុខ ០២ រូប គួរតែត្រូវបានជ្រើសរើស ដើម្បីធានាសុវត្ថិភាពនៅក្នុងសាលា ជាពិសេសនៅពេលយប់ |
| | ច្រកចូល | ០ | ១ | សន្តិសុខ ០១ រូប គួរត្រូវបានជ្រើសរើស ដើម្បីទទួលខុសត្រូវនៅច្រកចូលសាលា |
| គិលានុបដ្ឋាក | | ០ | ១ | គិលានុបដ្ឋាក ០១ រូប គួរត្រូវបានជ្រើសរើស ដើម្បីទទួលខុសត្រូវលើការសង្គ្រោះបឋម |
| បុគ្គលិកអនាម័យ | | ១ | ២ | អ្នកសម្អាត ០១ រូប គួរត្រូវបានជ្រើសរើសដើម្បីធានាថាទីធ្លាសាលាត្រូវបានសម្អាត |
| កិច្ចប្រជុំទៀងទាត់រវាងគណៈគ្រប់គ្រងសាលា និងបុគ្គលិកគាំទ្រ ក្នុងមួយឆ្នាំ | | ១២ | ១២ | ត្រូវការការកែលម្អទៅលើរបៀបវារៈ និងកំណត់ត្រាកិច្ចប្រជុំឱ្យមានភាពច្បាស់លាស់ |
| ការបង្កើនជំនាញទៀងទាត់របស់បុគ្គលិកគាំទ្រក្នុងមួយឆ្នាំ | | ០ | ១ | វិក្រឹតការលើកិច្ចការជំនាញវិជ្ជាជីវៈនានា គួរត្រូវបានរៀបចំ |

ដើម្បីអនុវត្តគំរូអប់រំស្ទែមបែបបូរណាការបញ្ចូលដែលបានស្នើនេះបាន វិទ្យាល័យកំពង់ស្ពឺត្រូវតែមានការព្រមព្រៀងភាពជាដៃគូជាមួយសាកលវិទ្យាល័យដែលមានបទពិសោធន៍រឹងមាំ នៅក្នុងការបណ្តុះបណ្តាលសិស្សនៅក្នុងមុខវិជ្ជាទាក់ទងនឹងស្ទែម សំដៅផ្តល់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈអំពី ចំណេះដឹងខ្លឹមសារ និងវិធីសាស្ត្របង្រៀនថ្មី ព្រមទាំងរបៀបក្នុងការធ្វើសមាហរណកម្មវិស្វកម្ម និងបច្ចេកវិទ្យាទៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា ក៏ដូចជាការចែករំលែកធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវនៅក្នុងវិស័យស្ទែម។ ភាពជាដៃគូនេះ ក៏ជួយក្នុងការបង្កើនសមត្ថភាពប្រធានក្រុមបច្ចេកទេសបន្តសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដើម្បីទទួលបាននូវជំនាញ និងចំណេះដឹងបន្ថែម ក៏ដូចជាទទួលបាននូវកម្មវិធីមគ្គុទេសក៍ណែនាំ។ យុទ្ធសាស្ត្រធ្វើការថ្មីនេះ នឹងផ្តល់ការភ្ជាប់ទំនាក់ទំនងដ៏ល្អមួយសម្រាប់ថ្នាក់សិក្សាចំណេះដឹងទូទៅ និងឧត្តមសិក្សា ដើម្បីសហការគ្នាក្នុងគោលបំណងផលិតធនធានមនុស្សដែលមានជំនាញ និងចំណេះដឹងត្រូវគោលដៅសម្រាប់ថ្នាក់ឧត្តមសិក្សារបស់ពួកគេ និងបណ្តាញទំនាក់ទំនងក្នុងការចូលទីផ្សារការងារជំនាញ។ ប្រសិនបើត្រូវបានអនុវត្តប្រកបដោយជោគជ័យ មេរៀនអំពីភាពជាដៃគូនេះ អាចធ្វើការពង្រីកទៅទូទាំងប្រទេស។

ក្រុមប្រឹក្សាភិបាលសាលាដែលមានវិសាលភាពទូលំទូលាយមួយ គួរតែត្រូវបានបង្កើតឡើងដោយមានការចូលរួមពីសាកលវិទ្យាល័យ អាជ្ញាធរមូលដ្ឋាន តំណាងសហគមន៍ និងវិស័យឯកជន ជាពិសេសតំបន់សេដ្ឋកិច្ចពិសេសក្នុងខេត្ត ឬនៅក្នុងតំបន់ក្បែរនោះ។ ក្រុមប្រឹក្សាភិបាលរបស់សាលានេះ នឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងការតម្រង់ទិសសម្រាប់ការអភិវឌ្ឍ និងការគាំទ្រសាលារៀនផ្សារភ្ជាប់ទំនាក់ទំនងជាមួយឧស្សាហកម្មក្នុងស្រុក និងលើសពីនេះ។

ការបែងចែកតួនាទី និងកាតព្វកិច្ចច្បាស់លាស់របស់គណៈគ្រប់គ្រងសាលា ដែលជាអ្នកទទួលបន្ទុកលើការអនុវត្តកម្មវិធីស្ទែម គឺត្រូវការជាចាំបាច់។ ទន្ទឹមនឹងនេះ ការជ្រើសរើស គ្រូបង្រៀនស្ទែម ដែលមានបទពិសោធន៍ និងការផ្តល់ការលើកទឹកចិត្ត ក៏សំខាន់ដូចគ្នា ប្រសិនបើលទ្ធផលនៃការសិក្សារបស់សិស្សត្រូវបានបង្ហាញឱ្យឃើញពីការអន្តរាគមន៍របស់កម្មវិធីអប់រំស្ទែមនេះ។

## ៥.២.២. ដំណាក់កាលអនុវត្ត

ដើម្បីអនុវត្តគំរូអប់រំស្ទែមបែបរួមបញ្ចូលនេះប្រកបដោយជោគជ័យបាន ភាគីពាក់ព័ន្ធទាំងអស់ (រួមមានក្រសួងអប់រំ យុវជន និងកីឡា មន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្ត គណៈគ្រប់គ្រងសាលានិងគ្រូបង្រៀន និងសហគមន៍ ។ល។) ត្រូវយល់ស្របទៅលើសកម្មភាពដែលបានស្នើ និងរចនាសម្ព័ន្ធអភិបាលកិច្ច ព្រមទាំងការប្តេជ្ញាពេញទំហឹងក្នុងការអនុវត្ត និងគាំទ្រសកម្មភាពទាំងនេះ។ ហេតុដូច្នេះហើយ ដំណាក់កាលសម្រាប់ការអនុវត្តបន្ទាប់ មានដូចខាងក្រោមៈ

១. ការអប់រំស្ទែមនឹងដាក់អនុវត្តសម្រាប់តែចន្លវិទ្យាសាស្ត្រតែប៉ុណ្ណោះ ដោយចាប់ផ្តើមពីថ្នាក់ទី១០
២. ការបង្កើតឱ្យមាននូវក្រុមប្រឹក្សាភិបាលត្រួតពិនិត្យ និងលក្ខខណ្ឌយោង
៣. បែងចែកតួនាទី និងកាតព្វកិច្ចគណៈគ្រប់គ្រងសាលា និងក្រុមការងារស្ទែម
៤. ការអភិវឌ្ឍផែនការយុទ្ធសាស្ត្រ សម្រាប់ការវិនិយោគក្នុងការអភិវឌ្ឍខ្លឹមសារ និងការអនុវត្តកម្មវិធីសិក្សា
៥. គ្រូឧទ្ទេសដែលពោរពេញដោយបទពិសោធន៍ នឹងចូលរួមផ្តល់កម្មវិធីអភិវឌ្ឍជំនាញវិជ្ជាជីវៈ
៦. ការអភិវឌ្ឍនីតិវិធីប្រតិបត្តិស្តង់ដារ សម្រាប់យន្តការពិនិត្យតាមដាន និងគាំទ្រដែលរាប់បញ្ចូលៈ
- ក. សៀវភៅណែនាំអំពីការចូលរៀន និងការចុះឈ្មោះចូលរៀន
- ខ. ស្តង់ដារបង្រៀន និងរៀន
- គ. នីតិវិធីប្រើប្រាស់បន្ទប់ពិសោធន៍
- ឃ. សៀវភៅណែនាំអំពីក្លឹបសិក្សាស្ទែម
- ង. សៀវភៅណែនាំអំពីការអភិវឌ្ឍផ្អែកលើគម្រោង
- ច. នីតិវិធីសម្រាប់ការទទួលស្គាល់គុណភាពអប់រំ (ការធានាគុណភាពផ្ទៃក្នុង)
- ឆ. យុទ្ធសាស្ត្រអែង្គាសមូលនិធិ និងគណនេយ្យភាពថវិកា
- ជ. ការគ្រប់គ្រងផែនការលើកទឹកចិត្ត និងធនធានលើកទឹកចិត្ត
- ឈ. ឧបករណ៍ពិនិត្យតាមដានដំណើរការសាលា

# ឯកសារយោង

*(សូមមើលនៅផ្នែកភាសាអង់គ្លេស)*